CrossConnect MINISTRIES

# ភាពស្មោះត្រង់នៃព្រះជាម្ចាស់
# សេចក្ដីសង្ឃឹមរបស់យើង

ដែកឃី អ៊ូស

## ព្រះជាម្ចាស់បានបើកសម្ដែងព្រះហឫទ័យនៅក្នុងជីវិតរបស់
## អ៊ីសាក់ និង យ៉ាកុប

"ព្រះហស្ដនៃទ្រង់បានបង្កើត ហើយតាំងទូលបង្គំឡើងសូមប្រោសឲ្យទូលបង្គំមានយោបល់
ដើម្បីនឹងរៀនឲ្យបានស្គាល់សេចក្ដីបង្គាប់របស់ទ្រង់"
ទំនុកដំកើង ១១៩:១១

គ្រប់បទគម្ពីរ ត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ រក្សាសិទ្ធិ© ឆ្នាំ១៩៥៤ និង © ឆ្នាំ១៩៦២
ដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើប្រាស់ដោយមានការអនុញ្ញាតិ និងរក្សាសិទ្ធគ្រប់យ៉ាង

# មេរៀនទី ១

## មេរៀនទី ១ - ផ្នែកទី ១

## សេចក្តីណែនាំ:

នៅក្នុងព្រះគម្ពីរលោកុប្បត្តិមិនសូវមាននិយាយច្រើនអំពី អ៊ីសាក់ ជាកូនប្រុសរបស់លោក អប្រាហាំ និង លោកស្រីសារ៉ា ប៉ុន្មាននោះទេ! អ្វីដែលយើងបានសិក្សាអំពីជីវិតរបស់អ៊ីសាក គឺតាមរយៈការបើកសំដែង នៅក្នុងសាច់រឿងអំពីក្រុមគ្រួសារគាត់មានគឺ រេបេកាជាភរិយារបស់គាត់ និង កូនប្រុសទាំងពីររបស់គាត់ យ៉ាកុប និង អេសាវតែប៉ុណ្ណោះ។ អ៊ីសាក់ គឺជាកូនប្រុសនៃសេចក្តីសន្យា និង ជាអ្នកត្រូវទទួលគ្រង មរតក នៃសម្ព័ន្ធមេត្រីដែលបានចងឡើងដោយព្រះជាម្ចាស់ជាមួយនឹងលោក អប្រាហាំ។ ដូចយើងបានសិក្សារួច កន្លងមកនៅភាគទៅលេ ៣ "សេចក្តីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង" អំពីសម្ព័ន្ធមេត្រីដែលមាន ពេញដោយសេចក្តីស្រលាញ់ឥតលក្ខ័ណ្ឌរបស់ព្រះជាម្ចាស់ ព្រមទាំងសេចក្តីសន្យាអំពី ទឹកដី ទ្រព្យសម្បត្តិ និង កូនចៅ ប៉ុន្តែលោក អប្រាហាំ និង លោកស្រីសារ៉ា ពួកគាត់ទាំងពីរនាក់គ្មានកូននឹងគេសោះ ហើយពួក គាត់ជាមនុស្សរស់នៅលើទឹកដីនៃសាសន៍ដទៃទៀតផង។ ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ទៅលោក អប្រាហាំ ថាគាត់បានក្លាយទៅជាឪពុកនៃជាតិសាសន៍មួយដោយធំ។ សេចក្តីសង្ឃឹមរបស់គាត់គឺមានទៅលើ ព្រះជាម្ចាស់ទាំងស្រុង គាត់ជឿជាក់ថាអ្វីដែលព្រះជាម្ចាស់ទ្រង់បានសន្យា គឺប្រាកដជានឹងបានសម្រេច។

ការសិក្សាព្រះគម្ពីរនូវចំណេងជើងក្នុងភាគ "សេចក្តីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង" គឺត្រូវបាន បញ្ចប់ត្រឹមមរណៈភាពរបស់លោក អប្រាហាំ (លោកុប្បត្តិ ២៥)។ ទោះជាយ៉ាងណាក៏ដោយ គឺនៅពេល ដែលលោក អប្រាហាំ បានស្លាប់ទៅគាត់មានបំណងចង់រកនារីម្នាក់មកធ្វើប្រពន្ធរបស់អ៊ីសាក់។ នៅក្នុងព្រះ គម្ពីរលោកុប្បត្តិ ២៤ នឹងប្រាប់ឲ្យបានដឹងថាតើនាង រេបេកា ត្រូវបានជ្រើសរើសយ៉ាងដូចម្តេច។ នៅជំពូក ដំបូងគេគឺត្រូវបានចាប់ផ្តើមដោយការសន្ទនារវាងលោក អប្រាហាំ និង អ្នកបម្រើរបស់គាត់ ប៉ុន្តែនៅក្នុង ព្រះគម្ពីរមិនបានប្រាប់យើងថាអ្នកបម្រើរូបនោះមានឈ្មោះអ្វីនោះទេ គ្រាន់តែបានដឹងថាគាត់គឺជាបុរសម្នាក់ ដែលបម្រើនៅក្នុងគ្រួសាររបស់លោក អប្រាហាំប៉ុណ្ណោះ។

សូមរំលឹងឡើងវិញបន្តិចសិនមុននឹងយើងបន្តទៅមុខទៀត! ក្នុងខណៈពេលលោកអ្នកកំពុងសិក្សាមេរៀន នេះ និង មេរៀនខាងមុខៗទៀតលោកអ្នកត្រូវនឹកចាំអំពីសំនួរបំផុសគំនិតទាំង ៣ សិន។ សំនួរសួថា: ១. តើ អ្វីទៅជាអង្គហេតុនៅក្នុងសាច់រឿងនេះ? ២. តើអ្វីទៅជាសេចក្តីពិតរបស់ព្រះជាម្ចាស់ និង សេចក្តីពិតរបស់ មនុស្ស? ៣. តើមានអ្វីខ្លះជាចំណុចសំខាន់ក្នុងរឿងដែលត្រូវយកទៅអនុវត្តសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ?

## កិច្ចការៈ

ចូរយើងចាប់ផ្តើមដោយការសង្កេតមើលអំពីអ្វីដែលសាច់បានប្រាប់យើងៈ

- នៅក្នុងខ ១ ឯអ័ប្រាហាំគាត់ចាស់ណាស់ហើយ "មានអាយុវែង" ហើយព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់គាត់ក្នុងគ្រប់ការទាំងអស់។ យើងបានដឹងថាគាត់មានអាយុ ១៣៧ ឆ្នាំនៅពេលភរិយារបស់គាត់ទទួលមរណៈភាព ហើយគាត់ក៏ស្លាប់នៅពេលគាត់មានអាយុ ១៧៥ ឆ្នាំ។ ចូរយើងមើលទៅត្រង់លោកុប្បត្តិ ២៤:៣៥ ហើយកត់ត្រាអំពីអ្វីបានបង្ហាញថាព្រះជាម្ចាស់បានប្រទានពរដល់គាត់។ ____

  ______________________________

  ______________________________

- នៅក្នុងខ ២-៤ លោកអប្រាហាំ បានហៅអ្នកបម្រើរបស់គាត់ឲ្យជួប តើនៅពេលនោះគាត់បានប្រាប់ឲ្យអ្នកបម្រើរបស់គាត់ធ្វើអ្វី? ______________________________

  ______________________________

  តើលោក អប្រាហាំ បានឲ្យអ្នកបម្រើស្បថដូចម្តេច? ______________________________

  ______________________________

  ______________________________

## សេចក្តីបង្រៀនៈ

លោកអ្នកត្រូវតែសួរសំនួរមួយថាៈ ហេតុអ្វីបានជាលោក អប្រាហាំទុកជារឿងសំខាន់ក្នុងការដែលមិនកូនប្រុសរបស់ទៅយកប្រពន្ធជាសាសន៏កាណាន? តើសាសន៏កាណានគឺជានរណា? តើយើងបានដឹងអ្វីខ្លះអំពីពួកគេ? ដើម្បីស្រាវជ្រាវសារឡើងវិញ ដើម្បីឲ្យបានដឹងថាពួកគេគឺជានរណា យើងត្រូវមើលទៅលើខយោងដែលបានប្រាប់យើងនៅក្នុងខ ៣ គឺជាការរៀបរាប់អំពីសាសន៏កាណាន។ តើខយោងបាននិយាយ ដូចម្តេចខ្លះ? ______________________________

______________________________

រំលឹកកាលពីយើងសិក្សានៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១០:១៥-១៩ គឺជាពូជពង្សខ្សែលោហិតកូនប្រុសរបស់លោក ណូអេ ឈ្មោះ ហាំ ហើយពូជពង្សខ្សែស្រឡាយរបស់ ហាំ គឺត្រូវបានជាប់បណ្តាសារ ព្រោះរឿងបានមើលកេរ្តិ៍ខ្មាសរបស់ឪពុក (លោកុប្បត្តិ ៩:២៥-២៧) ដូច្នេះហើយ នៅក្នុងខ ៤ បានប្រាប់ឲ្យដឹងថាអ្នកបម្រើលោក អប្រាហាំ នឹងត្រូវទៅទីណា? ______________________________

______________________________

______________________________

យើងក៏ត្រូវតែដឹងនូវចំណុចយ៉ាងសំខាន់បំផុតមួយទៀតដែរ! ព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីនៃសេចក្តីសន្យាជាមួយនឹងលោក អប្រាហាំ! ពូជពង្សនៃខ្សែលោហិតដែលបានកើតមកពី សឹម តមក អប្រាហាំ ហើយក៏បន្តមកដល់ អ៊ីសាក់។ សម្ព័ន្ធមេត្រីដ៏តាំងនៅអស់កល្បត្រូវបានបញ្ជាក់យ៉ាងម្តងទៀតជាមួយ អប្រាហាំ និងពូជពង្សគ្រប់ជំនាន់ដែលកើតក្រោយៗមកទៀត (លោកុប្បត្តិ ១៧) ។ នេះគឺជាការសម្រេចចិត្តមួយតាមបែបសាសនារបស់លោក អប្រាហាំ គឺមិនគាត់មិនអនុញ្ញាត្តិឲ្យ អ៊ីសាក់ ជាកូនទៅយកកូនស្រីនៃខ្សែលោហិតដែលមានជាប់បណ្តាសារមកធ្វើជាប្រពន្ធ ឬ ជាស្រីដែលមិនបានជាប់នៅក្នុងសម្ព័ន្ធមេត្រីនៃព្រះហេតុដូចនេះហើយទើបបានជាលោក អប្រាហាំ បង្គាប់ឲ្យអ្នកបម្រើរបស់គាត់ទៅរកនារីនៅឯស្រុកកំណើតរបស់គាត់គឺ ស្រុក ហារ៉ាន ដើម្បីមកធ្វើជាប្រពន្ធរបស់អ៊ីសាក់វិញ។ អ្នកបម្រើរបស់លោក អប្រាហាំ បានធ្វើតាមបង្គាប់ ក៏ធ្វើដំណើរទៅដល់ស្រុក ហារ៉ាន គាត់បានស៊ើបសួរតាមរយៈសាច់ញាត្តិរបស់គាត់អំពីការដែលម្ចាស់របស់គាត់បានបង្គាប់មក។ នៅជំនាន់នោះ ទោះបីជាកូនស្រី ឬ កូនប្រុសក្តី គឺត្រូវបានឳពុកម្តាយជាអ្នករៀបចំផ្សំផ្គុំឲ្យ នេះបើតាមប្រពៃណីនៃវប្បធម៌របស់ពួកគេនាសម័យនោះ។

## មេរៀនទី ១ - ផ្នែកទី ២

មកដល់ត្រឹមនេះយើងប្រហែលជាបានដឹងអំពីការទទួលខុសត្រូវយ៉ាងធ្ងន់ធ្ងររបស់អ្នកបម្រើហើយ! ជាការពិតមិននឹងយើងព្រមពោលពាក្យសម្បថក្នុងរឿងអ្វីមួយ នោះយើងត្រូវមានការពិភាក្សាគ្នាជាមុនសិន។

## លំហាត់បន្ទះ

- នៅក្នុងខ ៥-៦ តើអ្នកបម្រើរបស់លោក អប្រាហាំបានសួរសំនួរដូចម្តេច (ខ៥)? ____________

  ____________________________________________

  ហើយតើលោក អប្រាហាំ បានឆ្លើយតបវិញយ៉ាងដូចម្តេច? ____________

  ____________________________________________

- នៅក្នុងខ ៧ តើលោក អប្រាហាំ មានហេតុផលយ៉ាងដូចម្តេច? ចូររំលឹកសារឡើងវិញនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១២:១-៣ ____________

  ____________________________________________

  ____________________________________________

  ____________________________________________

## សេចក្ដីបង្រៀនៈ

ព្រះជាម្ចាស់បានត្រាស់លោក អប្រាហាំ ឲ្យចាកចេញពីស្រុក ហារ៉ាន រួចទ្រង់បាននាំគាត់ទៅកាន់ទឹកដីនៃស្រុកកាណាន។ នៅពេលព្រះជាម្ចាស់បានត្រាស់ហៅគាត់ចេញពីស្រុក ហារ៉ាន នោះទ្រង់បានសន្យានឹងគាត់ និង កូនចៅគ្រប់ជំនាន់ក្រោយៗគាត់ថា នឹងប្រទាន ទឹកដី ទ្រព្យសម្បត្តិយ៉ាងសំបូរសប្បាយដល់ពួកគេ។ ជាការពិតជាកស្តែងព្រះជាម្ចាស់ទ្រង់បានធ្វើសម្រេចតាមអ្វីៗគ្រប់យ៉ាងដែលទ្រង់បានសន្យា គឺទ្រង់បានប្រទានអចលនទ្រព្យ (ទឹកដី) កូនចៅ (ពូជពង្សជំនាន់ក្រោយ) ទ្រព្យសម្បត្តិ (សំបូរសប្បាយ) យ៉ាងនោះមែន។

លុះមកដល់ត្រឹមនេះលោក អប្រាហាំបានបង្គាប់ទៅអ្នកបម្រើរបស់គាត់ គឺដូចគ្នាទៅនឹងអ្វីដែលព្រះជាម្ចាស់បានបង្គាប់មកគាត់ឲ្យចាកចេញពីទឹកដីនៃស្រុក ហារ៉ាន ដែរ។ ប៉ុន្តែ ពេលលោក អប្រាហាំ ត្រូវបានព្រះជាម្ចាស់ត្រាស់ហៅឲ្យចាកចេញពីទឹកដីស្រុកកំណើតនោះ កូនប្រុសរបស់គាត់មិនទាន់ជាប់ក្នុងសម្ព័ន្ធមេត្រីនៅឡើយទេ គឺគាត់ត្រូវបានព្រះបង្គាប់ឲ្យរូបគាត់ និង ក្រុមគ្រួសារចាកចេញពីទឹកដីចាស់ ដោយតម្រូវឲ្យគាត់ធ្វើដំណើរទៅកាន់ទឹកដីថ្មីមួយទៀត។ រូបគាត់ផ្ទាល់ និង ពួកគ្រួសារ ត្រូវបានទទួលសេចក្ដីសន្យានៃសម្ព័ន្ធមេត្រីថ្មីពីព្រះ ជាម្ចាស់ ហើយទ្រង់នឹងដៅចំណាំសម្ព័ន្ធមេត្រីនេះទៀតសោតនឹងត្រូវតាំងនៅរហូតអស់កល្បជានិច្ចទៀតផង។ បើនិយាយឲ្យងាយស្ដាប់គឺថា គាត់ត្រូវបានព្រះជាម្ចាស់ត្រាស់ឲ្យចាកចេញ ដើម្បីធ្វើដំណើរទៅរកលោកុប្បត្តិ (ដើមកំណើតនៃអ្វីគ្រប់យ៉ាង) ថ្មីមួយទៀត។

មកដល់ត្រង់ចំណុចនេះ នឹងមានបញ្ហាមួយចំនួនផុសចេញក្នុងគំនិត។ យើងនឹងបានលើកយកបញ្ហាទាំងអស់នោះមកបកស្រាយឲ្យបានលំអិតនោះទេ ប៉ុន្តែ យើងនឹងចាប់ផ្ដើមដោយប្រើការស្រមើស្រមៃក្នុងខណៈពេលដែលលោកអ្នកកំពុងតែគិតពិចារណាអំពីបញ្ហានេះ។

- តើលោកអ្នកគិតថាលោក អប្រាហាំ បានប្រព្រឹត្តិចំពោះកូនប្រុសរបស់គាត់ដូចជា មហាក្សត្របានប្រព្រឹត្តិចំពោះក្សត្រដែលត្រូវគ្រងរាជ្យដែរឬទេ? លោក អប្រាហាំ ធ្លាប់មានបទពិសោធន៍អំពីសកម្មភាពរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់គាត់ផ្ទាល់។ ព្រះជាម្ចាស់បានប្រទានពរដល់គាត់នូវអ្វីៗគ្រប់បែបយ៉ាងមកតាមរយៈ អ៊ីសាក់ គឺចាប់តាំងពីកំណើតមក ហើយបន្តទៅដល់ការរួមដំណើរទៅកាន់ភ្នំ ម៉ូរីយ៉ា ដែលជាទីកន្លែងត្រូវថ្វាយយញ្ញបូជា។ លោក អប្រាហាំ បានដឹងថា ព្រះហស្តរបស់ព្រះជាម្ចាស់តែមួយដដែលនោះនឹងតាមថែរក្សាការពារ និង ប្រទានដល់កូនប្រុសរបស់គាត់ជាក់ជាមិនខាន។ លុះដល់ ពេលគាត់មានវ័យកាន់តែចាស់ទៅ តែគាត់នៅតែជាក់លើព្រះជាម្ចាស់ថាទ្រង់ប្រាកដជានឹងរៀបចំគូរស្រករសម្រាប់កូនប្រុសរបស់គាត់ជាមិនខានឡើយ។ គឺព្រះជាម្ចាស់ដដែលនោះហើយដែលបានសន្យាថានឹង "ចាត់ទេវត្តារបស់ទ្រង់ ______________________

______________________________________________

______________________________________________

(លោកុប្បត្តិ ២៤:៧) បើសិនជាគ្មានស្ត្រីណាម្នាក់មានចន្ទៈក្នុងការវិលត្រឡប់មកវិញជាមួយនឹង អ្នកបម្រើរបស់គាត់ ដូច្នេះ ទើបអ្នកបំប្រើរូបនោះបានរួចពីសម្បថរបស់ពួកគេវិញ។

- នៅមានការពិចារណាមួយផ្សេងទៀត! ក្នុងនាមជាសមាជិកនៃគ្រួសាររបស់លោក អប្រាហាំ បើពិតដូច្នេះមានន័យថា អ្នកបម្រើម្នាក់ក៏ត្រូវបានទទួលពិធីកាត់ស្បែករួចហើយជាមិនខាន អញ្ចឹងគាត់ក៏មានចំណែកនៅក្នុងសម្ព័ន្ធមេត្រីដែលចងឡើងដោយព្រះជាម្ចាស់ផងដែរ ដូចបានប្រាប់យើងនៅក្នុងលោកុប្បត្តិ ១៧ ស្រាប់។ ដោយសារតែគាត់បានទទួលព្រះគុណមកពីព្រះជាម្ចាស់តាមរយៈលោកអប្រាហាំ ដូច្នេះគឺត្រូវបានត្រឡប់ដូចជាម្ចាស់របស់គាត់ ដូចនេះហើយគាត់ក៏នឹងមានបទពិសោធន៍ធ្លាប់បានទទួលការការពារពីព្រះជាម្ចាស់ដូចដែលលោក អប្រាហាំបានទទួលពីមុនមកដែរ។ អ្នកបម្រើបានដឹងអំពីការនេះដោយសារលោក អប្រាហាំបានបញ្ជាក់ប្រាប់គ្រប់ៗគ្នាបែបនោះ អ្នកបម្រើក៏បានជ្រាបទៀតថា អ៊ីសាក់ ក៏មានចំណែកនៅក្នុងសម្ព័ន្ធមេត្រីនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ផងដែរ។ និយាយជារួមទៅគឺថា ព្រះជាម្ចាស់បានគង់នៅជាមួយនឹងលោក អប្រាហាំ ហើយដោយសារលោក អប្រាហាំព្រះជាម្ចាស់បានស្មោះត្រង់នឹងគាត់ ទោះបីជាយ៉ាងនេះក៏ពិតមែន តែអ្នកបម្រើរូបនេះនៅតែព្រមពោលពាក្យសម្បថជាមួយម្ចាស់របស់គាត់ចំពោះបញ្ហានេះដដែល (១៩)។ ចូរកត់ត្រានូវអ្វីដែលជាគំនិតរបស់លោកអ្នក _____________________________________________________________________________________________________________________________________________________________________________________________________

## មេរៀនទី ១ - ផ្នែកទី ៣
## សេចក្តីណែនាំៈ

បាវនោះក៏យកអូដ្ឋ១០ពីហ្វូងអូដ្ឋរបស់ចៅហ្វាយខ្លួនចេញទៅពីព្រោះទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់ចៅហ្វាយគាត់ ក៏នៅក្រោមអំណាចគាត់ទាំងអស់ គាត់ក្រោកឡើងទៅឯស្រុកអើរ៉ាមដែលនៅកណ្តាលទន្លេទាំង ២ គឺដល់ទីក្រុងរបស់ណាឃរ។ បើលោកអ្នកគឺជាអ្នកជ្រើសរើសវិញ ម្លេះសមលោកអ្នកជ្រើសរើសទៅកាន់អើរ៉ាម គឺមាននៅលើផែនទីដំបូងគេបង្អស់នៃព្រះគម្ពីររបស់លោកអ្នក។ តែតំបន់ប្រហែលជាគ្មាននៅលើផែនទីឡើយ បើដូច្នេះ ចូរស្វែងរកស្រុកម៉ូអាប់ រួចឆ្លងកាត់ទៅទិសខាងជើងត្រង់ភ្នំ គឺប្រហែលជាស្ថិតនៅម្តុំតំបន់នេះបើតាមការសន្និដ្ឋាន (អើរ៉ាមមានទីតាំងស្ថិតនៅខាងខាងជើងនៃប្រទេស ម៉ីសូប៉ូតាមី)។

**សំហាត់បន្ថែម:**

- លោក អប្រាហាំបានប្រគល់សត្វអូដ្ឋ ១០ ក្បាល និង ទ្រព្យសម្បត្តិមួយចំនួនទៀតទៅអ្នកបម្រើរបស់គាត់ក្នុងការធ្វើដំណើរ។ អ្នកបម្រើក៏បានមកដល់ អើរ៉ាម ដោយជិះសត្វអូដ្ឋរបស់គាត់យ៉ាងប្រសើរ។ វេលាដែលគាត់បានទៅដល់នោះគឺជាពេលល្ងាច ចំជាពេលស្រ្តីៗនៅតំបន់នោះចុះមកដងទឹកយកទៅប្រើប្រាស់។
- នៅក្នុងខ ១២-១៤ ចូរសរសេរសេចក្តីអធិស្ឋានរបស់គាត់ទៅតាមភាសា តំបន់របស់លោកអ្នកផ្ទាល់

________________________________________

________________________________________

________________________________________

________________________________________

អ្នកបម្រើនោះបានអធិស្ឋានទៅកាន់ព្រះជាម្ចាស់ថា សូមឲ្យព្រះអង្គបង្ហាញសេចក្តីសប្បុរស់ទ្រង់ដល់លោក អប្រាហាំ ដោយជួយសម្រេចតាមគោលបំណងរបស់គាត់។ តើអ្នកបម្រើនោះអាចដឹងពីសញ្ញាដែលព្រះជាម្ចាស់បង្ហាញថាជាស្រ្តីរូបណាត្រូវទៅធ្វើជាប្រពន្ធរបស់អ៊ីសាក់? __________

________________________________________

- នៅក្នុងខ ១៥ នៅមុនពេលគាត់បញ្ចប់សេចក្តីអធិស្ឋានរបស់គាត់តើមានអ្វីកើតឡើង? ________

________________________________________

តើនៅក្នុងខ ១៥ បានប្រាប់យើងអ្វីខ្លះអំពីនាង រេបេកា? ____________________

________________________________________

________________________________________

តើនាងមានទំនាក់ទំនងដូចម្តេចជាមួយនឹងលោក អប្រាហាំ? តើឪពុករបស់នាងគឺជានរណា? ___

________________________________________

________________________________________

សូមលោកអ្នកព្រះគម្ពីរលោកុប្បត្តិ ១១:២៧-២៩, ២២:២៣

- នៅក្នុងខ ១៦ តើនាងបានបរិយាយយ៉ាងដូចម្តេច? ________________________

________________________________________

- នាងបានបំពេញក្អមរបស់នាងនៅរដូវនិទាឃរដូវ! រំពេចនោះអ្នកបម្រើរបស់លោក អប្រាហាំក៏ជួបនាងយ៉ាងប្រញ៉ាប់ប្រញ៉ាល់ដើម្បីសុំទឹកពីនាងបរិភោគ។ នៅក្នុងខជាបន្តបន្ទាប់ទៀតបានប្រាប់យើង

ថានាងបានធ្វើអ្វីខ្លះ។ អ្វីៗគ្រប់យ៉ាងគឺត្រូវបានកើតឡើង ដូចនឹងអ្វីគាត់បានអធិស្ឋានទូលសូមព្រះជាម្ចាស់។ នាងក៏បានជូនទឹកទៅគាត់ពិសារ ថែមទាំងសត្វអូដ្ឋរបស់គាត់ទាំងអស់ផឹកបានឆ្អែតផង។ នៅពេលដែលលោកអ្នកសញ្ជឹងគិតអំពីរឿងនេះ ថាវាគឺជាការរំពឹងទុកយ៉ាងខ្លាំងរបស់អ្នកបម្រើ! សត្វអូដ្ឋ ១០ ក្បាល! ថាម៉េច ឲ្យវាផឹកទឹករហូតដល់ពួកវាឆ្អែត? តើនាងត្រូវធ្វើដំណើរប៉ុន្មានត្រឡប់នាទិទាយរដូវ ក្នុងការមកដងទឹកដើម្បីយកទៅបំពេញពាងទទេរបស់នាង?

- នៅក្នុងខ ២១ ហាក់ដូចជាបានបង្ហាញឲ្យយើងបានដឹងថា អ្នកបម្រើនោះមិនបានជួយអ្វីដល់នាងបន្តិចណាសោះ ផ្ទុយទៅវិញគាត់នៅឈរសម្លឹងមកនាងយ៉ាងជិតទៅវិញ។ ____________________

______________________________________________________________

______________________________________________________________

នៅក្នុងខបន្ទាប់ទៀត យើងឃើញថាមានបុរសម្នាក់ មានពាក់មាសនៅនឹងច្រមុះ និង ខ្សែដៃមាសមកដល់ រួចអ្នកបម្រើនោះក៏ផ្ដើមសួរទៅនាង រេបេការ ថានាងជានរណា ហើយរស់នៅឯណា គាត់នោះក្នុងគោលបំណងដើម្បីសុំកន្លែងស្នាក់នៅបានមួយយប់នៅឯផ្ទះរបស់ឪពុករបស់នាង។ តើនៅក្នុងខ ២៥ នាងបានឆ្លើយតបទៅអ្នកបម្រើវិញយ៉ាងដូចម្ដេច? ____________________

______________________________________________________________

______________________________________________________________

រំពេចនោះ តើអ្នកបម្រើបានពោលទៅកាន់នាងវិញថាដូចម្ដេចខ្លះ? ____________________

______________________________________________________________

______________________________________________________________

តើមានហេតុផលអ្វីបានជាគាត់ថ្វាយបង្គំ និង អរព្រះគុណទៅព្រះជាម្ចាស់ (ខ២៧)?

១. ____________________________________________________________

២. ____________________________________________________________

## មេរៀនទី ១ - ផ្នែកទី ៤

## សេចក្ដីបង្រៀន:

នៅក្នុងខ ៧ និងខ ២៧ បានរំលឹកឲ្យយើងដឹងអំពីភាពស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះសេចក្ដីសន្យារបស់ទ្រង់។ ទ្រង់តែងតែចងចាំជានិច្ចនូវអ្វីដែលទ្រង់បានមានព្រះបន្ទូល ហើយព្រះបន្ទូលរបស់ទ្រង់នោះឯងគឺជាសេចក្ដីពិត។ នៅភាគ "ភាពស្មោះត្រង់របស់ព្រះជាម្ចាស់ សេចក្ដីសង្ឃឹមរបស់យើង" យើងបានសិក្សាអំពីដំណើរជីវិតរបស់លោក អប្រាហាំ និង អំពីការរង់ចាំសេចក្ដីសន្យារបស់ព្រះបានសម្រេច។ យើងត្រូវតែមានការប្រុងប្រយ័ត្ន ចំពោះភាពស្មោះត្រង់របស់ព្រះជាម្ចាស់ទៅនឹងព្រះបន្ទូលរបស់ទ្រង់ គឺវាមិនមែនផ្អែក

ទៅលើកម្មវិធីរបស់យើងនោះទេ។ ការរំពឹងទុក និង ភាពគ្មានការអត់ធ្មត់របស់មនុស្សយើង នោះនាំឲ្យខូចដល់ការគិត និង ក្តី ទន្ទឹងរង់ចាំរបស់ខ្លួនឯង។ ជាញយដឹងមនុស្សយើងតែងតែកំណត់អត្ថន័យនៃភាពស្មោះត្រង់ទៅតាមគំនិត និង ការយល់ឃើញរបស់ខ្លួនជាជាងទុកឲ្យព្រះជាម្ចាស់បង្រៀនយើងថាវាមានអត្ថន័យយ៉ាងដូចម្តេចទៅវិញ។ ក្នុងខណៈពេលយើងកំពុងសិក្សាដើម្បីឲ្យស្គាល់ព្រះជាម្ចាស់ និង ដើម្បីរីកលូតលាស់ក្នុងទំនាក់ទំនងជាមួយនឹងទ្រង់ នោះទ្រង់នឹងប្រទានឲ្យយើងមានការយល់ដឹង និង ប្រាជ្ញា ដែលអាចធ្វើឲ្យអាចយល់នូវភាពស្មោះត្រង់ និង ការទុកចិត្តលើទ្រង់ ថាទ្រង់យ៉ាងណា។

នៅមានរឿងមួយទៀតដែលយើងត្រូវតែប្រុងប្រយ័ត្នអំពី ការសន្យារបស់យើង គឺមិនមែនជាសេចក្តីសន្យារបស់ព្រះជាម្ចាស់នោះទេ ហើយយើងក៏មិនអាចនឹងតម្រូវឲ្យទ្រង់គោរពបន្ទូលសន្យារបស់ទ្រង់ចំពោះយើងនោះដែរ។ ព្រះអង្គសន្យាដោយស្មោះត្រង់ គឺទ្រង់បានធ្វើដូច្នោះមែន! ជួនកាលខ្ញុំបានសន្យាជាមួយក្មេងអំពីរឿងអ្វីមួយ ប៉ុន្តែមានកាលៈទេសៈខ្លះជម្រុញធ្វើឲ្យខ្ញុំធ្វើការជ្រើសរើសថាតើខ្ញុំត្រូវធ្វើតាមការសន្យា ឬ មិនធ្វើតាមការសន្យាជាមួយក្មេងម្នាក់នោះ។ ជារឿងៗ ដោយសារនិស្ស័យជាមនុស្សរបស់យើង បាននាំឲ្យយើងប្រតិបត្តិចំពោះព្រះជាម្ចាស់ទុកដូចត្រឹមតែជាមនុស្សប៉ុណ្ណោះ គឺថាតើខ្ញុំ ឬមួយក៏ទ្រង់ដែលត្រូវជ្រើសរើសយកភាពស្មោះត្រង់ ឬមិនស្មោះត្រង់ចំពោះសេចក្តីសន្យានោះ។ តាមការជាក់ស្តែង ភាពស្មោះត្រង់គឺពោលពាក្យមួយទៅកាន់ព្រះជាម្ចាស់ ពាក្យមួយទៀតទៅតាមតម្រូវការរបស់មនុស្សត្រូវគោរពតាម។ ទោះបីជាយ៉ាងណាក៏ដោយ អត្តចរិត និង អកប្បកិរិយារបស់ព្រះជាម្ចាស់ បានក្លាយទៅជាផ្នែកមួយចរិតលក្ខណៈរបស់យើង ក្នុងខណៈពេលទ្រង់ធ្វើស្អាងចិត្ត និង កែប្រែពួកយើងឲ្យមានលក្ខណៈដូចជាទ្រង់។ លោកអ្នកត្រូវតែចាំទុកថា លក្ខណៈដូចទ្រង់ គឺជាផែនការណ៍ដំបូងបង្អស់របស់ព្រះជាម្ចាស់សម្រាប់យើង នេះបើតាមការបញ្ជាក់នៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ១:២៧។

## សំហាត់បន្ថះ

- នៅក្នុងខ ២៨-៣៣ រេបេកា បានរត់យ៉ាងប្រញាប់ប្រញាល់រត់ទៅផ្ទះដើម្បីជម្រាបអ្នកផ្ទះអំពីរឿងនេះ។ ឡាបាន់ គឺជាបងប្រុសរបស់ រេបេកា ក៏រួសរាល់ទៅជួបអ្នកបម្រើ។ គាត់បានឃើញថានាង រេបេកា គឺមានក្រវិលមានពាក់នៅនឹងច្រមុះ។ ឡាបាន់បានស្តាប់តាមប្អូនស្រី កំពុងរបៀបរាប់ប្រាប់ថាមានរឿងអ្វីកើតឡើង។ គាត់ក៏បានធ្វើដំណើរទៅភៅជាមួយនឹងសត្វអូដ្ឋរបស់គាត់ទៅកាន់ផ្ទះរបស់ឡាបាន់ដើម្បីសស្នាក់នៅទីនោះមួយយប់។ មុននឹងអ្នកបម្រើចំណីអាហារ នៅចំពោះមុខគាត់គឺជាបេធូអែល ជាឪពុករបស់នាង រេបេកា ហើយត្រូវជាប់ជាសាច់ញាតិជាមួយនឹងគាត់ដែរ នៅពេលនោះគាត់បាននិយាយប្រាប់ បេធូអែល និង ឡាបានអំពីអ្វីដែលគាត់ត្រូវនិយាយ។
- នៅក្នុងខ ៣៤-៤៩ អ្នកបម្រើបានរៀបរាប់យ៉ាងលំអិតតាំងពីចំណុចចាប់ផ្តើម នៃការណែនាំរបស់លោក អប្រាហាំ រហូតវេលាបានជួបជាមួយនឹងនាង រេបេកា ដែលមានពាក់ក្រវិលនៅច្រមុះ និង

មានពាក់ខ្សែដៃ។ បើតាមគំនិតរបស់លោកអ្នក តើការរៀបរាប់នោះមានចំណុចសំខាន់អ្វីខ្លះ? ____

______________________________________________

នេះគឺជារឿងមួយយ៉ាងសំខាន់ណាស់ដែលអ្នកបម្រើដឹងថាត្រូវឆ្លើយយ៉ាងដូចម្តេចនៅ ខ ២៣ និង ខ ៤៧។ តើអ្នកជាកូនស្រីរបស់នរណា? ហេតុអ្វី? ______________________

______________________________________________

តើលោក អប្រាហាំ បានទទួចអំពីរឿងអ្វីនៅក្នុងព្រះលោកុប្បត្តិ ២៤:៤? ____________

______________________________________________

ក្រៅពីអ្វីៗទាំងអស់ខាងលើនោះទៅ ព្រះជាម្ចាស់បានប្រទានពរជាថ្មីម្តងទៀត។ ព្រះជាម្ចាស់បានផ្គត់ផ្គង់ដោយប្រទានកូនចៀមសម្រាប់ថ្វាយដង្វាយ (លោកុប្បត្តិ ២២:១៣) ហើយពេលនេះដែរទ្រង់ក៏បានផ្គត់ផ្គង់ដោយប្រទានប្រពន្ធឲ្យអ៊ីសាក់ទៀតផង។ ជាថ្មីម្តងទៀត ទ្រង់បានបង្ហាញនូវសេចក្តីសប្បុរស និង ភាពស្មោះត្រង់របស់ទ្រង់ឲ្យលោក អប្រាហាំ បានឃើញ ចំណែកឯ ឡាបាន់ និង បេធូអែលក៏បានឃើញពីព្រះហស្តព្រះជាម្ចាស់ចង្អុលបង្ហាញដំណើរការទិសដៅផងដែរ។ តើពួកគេបានឆ្លើយតបវិញដូចម្តេចនៅក្នុងខ ៥០-៥១? ______________________

______________________________________________

______________________________________________

- ជំនួនត្រូវបានប្រគល់ជូន នាង រេបេកា និង គ្រួសាររបស់នាងដើម្បីចងស្ពានមានមេត្រីរវាងគ្រួសារទាំងពីរ។ តើអ្នកបម្រើមានជំនួនអ្វីជូនដល់នាង រេបេកា? ______________________

______________________________________________

តើអ្នកបានជូនជំនួនអ្វីទៅបងប្រុស និង ម្តាយរបស់នាង រេបេកា? ______________

______________________________________________

- នៅក្នុងខ ៥៤-៦១ ឡាបាន់ និង ម្តាយរបស់គាត់បានប្រុងប្រៀបរៀបចំឲ្យនាង រេបេកា បានទៅជាមួយនឹងអ្នកបម្រើដើម្បីធ្វើជាប្រពន្ធរបស់អ៊ីសាក់។ លុះដល់ព្រលឹមស្រាងៗនាថ្ងៃបន្ទាប់ អ្នកបម្រើបានត្រៀមខ្លួនរួចជាស្រេចក្នុងការចេញដំណើរត្រឡប់ទៅផ្ទះម្ចាស់របស់គាត់វិញ ដើម្បីនឹងជម្រាបពីការគ្រប់យ៉ាងដែលព្រះជាម្ចាស់ទ្រង់បំពេញឲ្យគាត់។ តើគ្រួសារនាង រេបេកា បានសំណូមពរអ្វីខ្លះនៅក្នុងខ ៥៥? ______________________________________

______________________________________________

ក៏ប៉ុន្តែ អ្នកបម្រើបានទទួលសុំ! គ្រួសាររបស់នាងសុខចិត្តធ្វើតាមសំណូមពររបស់នាង គឺព្រមឲ្យនាងទៅជាមួយនឹងអ្នកបម្រើ ដោយមានអ្នកបម្រើរបស់នាងទៅជាមួយផងដែរ។ ចូរកត់ត្រានូវការ

ប្រទានសម្រាប់នាងនៅក្នុងខ ៦០ ________________________________________

________________________________________________________________

________________________________________________________________

- នៅក្នុងខ ៦២-៦៧ តើមានរឿងអ្វីកើតឡើងនៅពេល អ៊ីសាក់បានជួយនឹងនាងរេបេកា?
    - o តើពេលនោះអ៊ីសាក់នៅឯណា? ________________________________
    - o នាង រេបេកា ឃើញអ៊ីសាក់រួចនាងសួរថា ____________________________

      ____________________________________________________________

    - o អ្នកបម្រើបានប្រាប់ទៅ រេបេកាថា នេះគឺ អ៊ីសាក់គឺជាម្ចាស់របស់គាត់ តើនៅពេលនាងរេបេកាធ្វើដូចម្ដេច? ____________________________________________

      ____________________________________________________________

      ____________________________________________________________

    - o នៅពេលដែល អ៊ីសាក់ បានស្ដាប់អ្នកបម្រើរាយការណ៍ តើគាត់ធ្វើដូចម្ដេច? __________

      ____________________________________________________________

      ____________________________________________________________

    - o ប្រហែលជា អ៊ីសាក់ និង រេបេកាមិនបានរៀបចំពិធីជប់លៀងអបអរសាទរមង្គលការធំដុំនោះទេ តែអ្វីដែលយើងដឹង ការរួមភេទសម្ពន្ធគឺជាការបំពេញកិច្ចនៃអាពាហ៍ពិពាហ៍។
    - o យើងដឹងរេបេកាបានក្លាយទៅជាប្រពន្ធរបស់អ៊ីសាក់ ហើយគាត់ស្រលាញ់នាងណាស់។ មួយរយ:ពេលក្រោយមកតើរេបេកាបានយកអ្វីឲ្យអ៊ីសាក់? ______________________

      ____________________________________________________________

    - o ការលួងលោមថ្នាក់ថ្នម និង ការកំសាន្តរបស់ប្រពន្ធចំពោះប្ដីខ្លួន គឺជួយឲ្យប្ដីបានស្កប់ស្កល់ចិត្ត។

## មេរៀនទី ១ - ផ្នែកទី ៥

## តើយើងបានសិក្សាអ្វីខ្លះអំពីព្រះជាម្ចាស់:

ចូរអានឡើងវិញនូវព្រះគម្ពីរលោកុប្បត្តិ ២៤! ក្នុងពេលកំពុងអានសូមលោកអ្នកយកហាឡាយ ឬ ខ្មៅដៃដើម្បីគូសចំណាំនូវពាក្យ ឬ ឃ្លាណាដែលបរិយារៀបរាប់អំពីចរិតលក្ខណ:របស់ព្រះជាម្ចាស់។ ចូរស្វែងរកពាក្យ ឬ ឃ្លាតដែលបង្ហាញអំពីចារិតលក្ខណ:របស់ព្រះជាម្ចាស់ ដោយប្រាប់លេខខដែលអ្នករកឃើញផង។

## លេខខគម្ពីរ　　　　　　　　　　ពាក្យ និង ឃ្លា

ពាក្យថា សេចក្ដីសប្បុរស និង ភាពស្មោះត្រង់ ត្រូវយើងរកឃើញនៅក្នុង ២៧ និង មួយទៀតនៅ ៤៩។ ដោយទូលថា សូមឲ្យព្រះយេហូវ៉ាជាព្រះនៃអ័ប្រាហាំចៅហ្វាយទូលបង្គំ ដែលទ្រង់មិនបានខាននឹងផ្ដល់សេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់ដល់ចៅហ្វាយទូលបង្គំបានប្រកបដោយព្រះពរ ឯទូលបង្គំសោត ក៏ព្រះយេហូវ៉ាទ្រង់នាំផ្លូវមកដល់ផ្ទះពួកបងប្អូនរបស់ចៅហ្វាយទូលបង្គំហើយ។

## សំនួរអនុវត្តន:

- ភាពស្មោះត្រង់ត្រូវបានស្ដែងចេញតាមរយៈពាក្យសម្ដីប្រកដដោយការប្ដេជ្ញាចិត្តខ្ពស់ ភាពស្មោះត្រង់គឺវាបណ្ដុះនូវទំនុកចិត្ត។ អាពាហ៍ពិពាហ៍គឺការកោះហៅបុរសម្នាក់ និង នារីម្នាក់ឲ្យមកធ្វើការប្ដេជ្ញាចិត្តចំពោះគ្នាដោយរក្សាភាពស្មោះត្រង់ទៅវិញទៅមក។ នៅពេលណាការប្ដេជ្ញាចិត្តត្រូវបានបាក់បែក នោះទំនុកចិត្តក៏ត្រូវបានបំផ្លាញដែរ។ ភាពស្មោះត្រង់គឺបើបាននិយាយយ៉ាងណា នោះត្រូវតែធ្វើយ៉ាងនោះ។ តើលោកអ្នកធ្លាប់មានបទពិសោធន៍យ៉ាងដូចម្ដេចដែរអំពីភាពស្មោះត្រង់? តើនរណាដែលបានបង្ហាត់បង្រៀនលោកអ្នកអំពីភាពស្មោះត្រង់? តើនរណាដែលគ្មានភាពស្មោះត្រង់ចំពោះលោកអ្នក? ______________________________

- តើអ្នកបានតស៊ូនឹងភាពស្មោះត្រង់របស់ព្រះជាម្ចាស់ដែរឬទេ? តើលោកអ្នកមានបទពិសោធន៍ពីការនេះយ៉ាងដូចម្ដេចខ្លះ? តើអ្នកបានទទួលការបង្រៀនអំពីភាពស្មោះត្រង់របស់ទ្រង់យ៉ាងណាខ្លះ? _

- តើលោកអ្នកមានការប្តេជ្ញាយ៉ាងណាដូចម្តេចក្នុងការធ្វើជាគំរូសម្រាប់ដល់អ្នកទៀត? ចូរនឹកចាំអំពីពេលវេលាណាមួយ ដែលអ្នកដទៃបានលើកទឹកចិត្តលោកអ្នកអំពីភាពស្មោះស្រង់ ហើយសេចក្តីទុកចិត្តត្រូវបានដុះឡើងតាមរយៈការប្តេជ្ញាចិត្ត

## ចូលឱ្យកាន់តែជ្រៅ:

ភាពស្មោះត្រង់របស់ព្រះជាម្ចាស់មិនមែនអាស្រ័យទៅលើអ្វីមួយក្រៅពីទ្រង់នោះទេ។ ២ ធីម៉ូថេ ២:១៣ គឺជាការអះអាងថាបើទុកជាយើង ______________________ តែទ្រង់នៅតែ __________ ______________ ទ្រង់ធ្វើជា ________________________________________

ព្រះជាម្ចាស់គឺជាព្រះជាម្ចាស់! ភាពស្មោះត្រង់គឺជាបុគ្គលិកលក្ខណៈរបស់ទ្រង់មួយ ហើយតាមរយៈបុគ្គលិកលក្ខណៈនេះហើយដែលបានប្រាប់យើងឲ្យដឹងអំពីសារៈសំខាន់ក្នុងការបញ្ជាក់ថាទ្រង់គឺជានរណា! ឬអាចនិយាយបានម្យ៉ាងទៀត ភាពស្មោះត្រង់គឺជាផ្នែកមួយនៃខ្សែលោហិតរបស់ទ្រង់ (DNA)។ នៅមានគំរូឧទាហរណ៍មួយទៀតដែលបង្ហាញពីបុគ្គលិកលក្ខណៈរបស់ទ្រង់ ដូចជានៅក្នុងព្រះគម្ពីរបានប្រាប់យើងថាព្រះជាម្ចាស់ទ្រង់គឺជាសេចក្តីស្រលាញ់។ តាមរយៈព្រះគម្ពីរដែលបានបង្ហាញឲ្យយើងស្គាល់ពីបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ថាទ្រង់គឺ មានសេចក្តីយុត្តិធម៌! បើតាមបទគម្ពីរ ១ យ៉ូហាន ១:៨-១០ តើបានបុគ្គលិកលក្ខណៈអ្វីខ្លះរបស់ព្រះជាម្ចាស់? ________________________________ និង __ __________________________________ ។ ព្រះជាម្ចាស់ ទ្រង់ប្រកបដោយភាពស្មោះត្រង់ហើយយុត្តិធម៌ ប្រយោជន៍ឲ្យយើងបានរួចពីអំពើបាប។ នៅក្នុងបទគម្ពីរខាងលើនេះ បានប្រាប់យើងថា បើយើងលន់តួបាបនៅចំពោះព្រះអង្គ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង។ ផ្ទុយទៅវិញ បើសិនជាយើងនិយាយកុហកខ្លួនឯង និង កុហកដល់ព្រះជាម្ចាស់អំពីស្ថានភាពអំពើបាបនៅក្នុងចិត្តរបស់យើងស នោះក្នុងចិត្តរបស់យើងគ្មានណាអាចនឹងទុកព្រះបន្ទូលសន្យារបស់ទ្រង់បានទេ ព្រោះតែព្រះអង្គមានពេញទៅដោយសេចក្តីយុត្តិធម៌។

## សេចក្តីអធិស្ឋាន:

ឱព្រះអម្ចាស់អើយ! ព្រះអង្គមានសេចក្តីសប្បុរស ហើយស្មោះត្រង់នឹងលោក អប្រាហាំ ទូលបង្គំសូមអរព្រះគុណដែលទ្រង់បានគោរពតាមសេចក្តីសន្យារបស់ព្រះអង្គ។ ព្រះអង្គអើយ! ទូលបង្គំក៏ជឿថាព្រះអង្គមានសេចក្តីសប្បុរស ហើយស្មោះត្រង់ចំពោះទូលបង្គំផងដែរ ទោះបីជាទូលបង្គំត្រូវពុះពារការលំបាកចំពោះ ក្តីសប្បុរស និង សេចក្តីស្មោះត្រង់ក៏ដោយ។ មានពេលខ្លះទូលបង្គំមិនមានចិត្តស្មោះត្រង់ឡើយ! ទូលបង្គំមិនបានគោរពតាមពាក្យសន្យារបស់ទូលបង្គំ ព្រោះតែអ្នកដទៃគ្មានការទុកចិត្តមកលើទូលបង្គំ។ សូមទ្រង់មេត្តាជួយទូលបង្គំចំពោះការខ្វះខាតភាពសប្បុរស ហើយសូមជួយកែផ្នែទូលបង្គំឲ្យបានដូចជាទ្រង់ផង! ទូលបង្គំ

ដឹងព្រះស្មោះត្រង់ គឺមិនអាស្រ័យលើភាពស្មោះត្រង់របស់ទូលបង្គំឡើយ។ ទូលបង្គំសូមអរព្រះគុណសម្រាប់សេចក្តីស្រលាញ់ និង ការអត់ទោសបាបតាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ ព្រមទាំងការធានាអះអាងអំពីភាពស្មោះត្រង់ ភាពយុត្តិធម៌ និង សេចក្តីសប្បុរសរបស់ព្រះអង្គចំពោះទូលបង្គំដ៏នៅអស់កល្បជានិច្ច។ ______

______________________________________________

______________________________________________

______________________________________________

# មេរៀនទី ២

## មេរៀនទី ២ - ផ្នែកទី ១

## សេចក្តីណែនាំ:

ក្រោយពេលលោក អប្រាហាំ បានទទួលមរណៈភាព កូនប្រុសរបស់គាត់គឺ អ៊ីសាក់ និង អ៊ីស្មាអែល យកសពរបស់គាត់ទៅបញ្ចុះជាមួយនឹងសពភរិយារបស់គាត់គឺលោកស្រី សារ៉ា។ ក្រោយពីនោះបន្តិច អ៊ីសាក់ និង រេបេការបានផ្លាស់ទៅរស់នៅតំបន់ ឡាហាយ-រយ ហើយសាច់រឿងរបស់អ៊ីសាក់ត្រូវបានបន្តក្នុងព្រះគម្ពីរ លោកុប្បត្តិ ២៥។ សេចក្តីសន្យារបស់ព្រះជាម្ចាស់ចំពោះលោក អប្រាហាំ ត្រូវបានបន្តទៅដល់កូនចៅជំនាន់ក្រោយជាច្រើនដូចជាផ្កាយនៅលើមេឃ ដូចគ្រាប់ខ្សាច់នៅមាត់សមុទ្រ។ លុះដល់ពេលនេះគាត់បានទទួលមរណៈភាពទៅដោយបន្សល់ទុកនៅកូនប្រុសម្នាក់គឺ អ៊ីសាក់ ដែលជាអ្នកទទួលមរតកបន្ត។

## កិច្ចការ:

ចូរលោកអ្នកអានព្រះគម្ពីរ លោកុប្បត្តិ ២៥:១៩-៣៤

## លំហាត់:

នៅក្នុងជំពូកនេះ យើងបានដឹងអំពីសាច់រឿងរបស់អ៊ីសាក់ជាបន្តទៀត! នៅក្នុងខ ១៩-២០ គឺជាចំណុចមួយតម្រូវឲ្យយើងធ្វើការរំលឹងសារឡើងវិញ! ដូច្នេះ ចូរយើងរំលឹងសារឡើងវិញទាំងអស់គ្នា។

- នៅក្នុងខ ១៩ តើនរណាជាឪពុករបស់អ៊ីសាក់? ______________________
- នៅក្នុងខ ២០ តើអ៊ីសាក់បានរៀបការនៅអាយុប៉ុន្មាន? ______________________
- តើអ៊ីសាក់បានរៀបការជាមួយនរណា? ______________________
    - o តើឪពុករបស់នាងគឺជានរណា? ______________________
    - o តើបងប្រុសរបស់នាងគឺជានរណា? ______________________
- នៅក្នុងខ ២១ អ៊ីសាក់បានទូលអង្វរសម្រាប់រេបេកា
    - o តើអ៊ីសាក់បានអធិស្ឋានសម្រាប់រឿងអ្វីខ្លះ? ______________________
    - o ហេតុអ្វីបានរឿងនេះគឺជារឿងសំខាន់? ______________________
- បើសិនជាអ៊ីសាក់គឺមនុស្សម្នាក់ដែលត្រូវនាំសេចក្តីសន្យារបស់ព្រះជាម្ចាស់ឲ្យបានសម្រេច? ខណៈតើមានអ្វីកើងឡើង? ______________________

  ______________________________________________
- យើងសិក្សាអំពីព្រះជាម្ចាស់បានឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់អ៊ីសាក់។ តើមានអ្វីកើតឡើង? _

  ______________________________________________

- នៅក្នុងខ ២២ តើបទគម្ពីរបានប្រាប់អ្វីខ្លះដល់យើងអំពីការមានផ្ទៃពោះរបស់រេបេកា? ________

________________________________________________

________________________________________________

## សេចក្តីបង្រៀនៈ

នាងរេបេកាបានមានផ្ទៃពោះជាកូនភ្លោះ ជាក់ស្តែងស្ត្រីដែលមានផ្ទៃកូនភ្លោះពិតជាមានការលំបាកណាស់។ តាមសាច់បានប្រាប់យើងថាទារកក្នុងពោះរបស់នាង "វារើបំរះកម្រើកនៅក្នុងពោះរបស់នាង"! ស្ត្រីមួយចំនួនដែលធ្លាប់មានផ្ទៃពោះពីមុនបាននិយាយថា មិនមែនរឿងស្រួលទេពេលស្ត្រីមានផ្ទៃ ព្រោះថាកូនៅក្នុងពោះវាកម្រើក ហើយរើបំរះ។ ដូច្នេះ នាងរេបេកា ពិតជាមានលំបាកមិនតិចទេ នៅពេលដែលមានផ្ទៃ ដោយកូនភ្លោះបែបនេះ ជាពិសេសគឺនៅពេលជិតគ្រប់ខែត្រូវសម្រាល គឺកូនទាំងពីរនៅក្នុងពោះរើបំរះ កម្រើកព្រមៗគ្នានៅក្នុងពោះ។ ដោយសារភាពលំបាកដូច្នេះ ទើបធ្វើឲ្យនាងត្រូវការព្រះជាម្ចាស់ "ហេតុការនេះត្រូវកើតឡើងចំពោះខ្ញុំម្ចាស់ទៅវិញ?"

## លំហាត់បន្ថៈ

- នៅក្នុងខ ២៣ បើតាមពាក្យសម្តីរបស់លោកអ្នក តើព្រះជាម្ចាស់ប្រាប់នាងដូចម្តេច? ________

________________________________________________

________________________________________________

________________________________________________

________________________________________________

ជីវិតរបស់នាង រេបេកា នឹងមានភាពខុសប្លែកពីគេ ដោយសារនាងផ្ទៃជាកូនភ្លោះ! ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់នាងថា កូនប្រុសទាំងពីររបស់នាងនឹងបង្កើតបានជាមនុស្សពីរក្រុម ហើយ ដាច់ចេញពីគ្នា។ ក្នុងចំណោមជាតិសាសន៍របស់ពួកគេទាំងពីរ នឹងមានមួយរឹងមាំ ខ្លាំងពូកែ ជាងជាតិសាសន៍មួយទៀត ហើយរឿងចុងក្រោយទ្រង់បានដល់នាងថាមនុស្សចាស់ នឹងត្រូវបម្រើក្មេង ដែលជារឿងផ្ទុយពីវប្បធម៌របស់ពួកគេ។

- នៅក្នុងខ ២៤ វេលាគ្រប់ខែត្រូវសម្រាលក៏មកដល់ ហើយនាងក៏បង្កើតបានកូនប្រុសភ្លោះពីរនាក់ តើក្នុងព្រះគម្ពីរប្រាប់យើងយ៉ាងដូចម្តេចអំពីកូនប្រុសដែលកើតមកមុន (ខ២៥)? ________

________________________________________________

________________________________________________

តើពួកគេដាក់កូនប្រុសច្បងនោះឈ្មោះអ្វី? ________________________

________________________________________________

- នៅក្នុងខ ២៦ បានបរិយាយអំពីប្អូនប្រុសរបស់គាត់: ______________________

______________________

តើពួកគេបានដាក់ឈ្មោះអ្វីឲ្យកូនប្រុសជាប្អូន? ______________________

ក្រោយពីអ៊ីសាក់បានរៀងការជាមួយនឹង រេបេកា បាន ២៥ ឆ្នាំ ពួកគេបង្កើតកូនប្រុសភ្លោះពីរនាក់គឺ អេសាវ និង យ៉ាកុប ហើយពេលនេះអ៊ីសាក់មានអាយុ ៦០ ឆ្នាំហើយ។

- នៅក្នុងខល២៧ និង ២៨ បានរៀបរាប់ប្រាប់យើងបន្ថែមទៀតអំពីការចម្រើនវ័យរបស់កូនប្រុសទាំងពីរនាក់។ តើមានលក្ខណៈពិសេសអ្វីចំពោះអេសាវដែលខុសពីមនុស្សដទៃ? ______________________

______________________

តើយើងបានសិក្សាអ្វីខ្លះអំពីយ៉ាកុប? ______________________

______________________

កូនប្រុសទាំងពីរនេះមានអត្តចរិតខុសពីគ្នាស្រលះ ម្នាក់មានចំណូចចិត្ត និង ពូកែខាងកិច្ចការក្រៅផ្ទះជាទីពេញចិត្តរបស់ឪពុក ហើយម្នាក់ទៀតចូលចិត្ត និង ពូកែខាងឯកិច្ចការក្នុងផ្ទះ ជាទីពេញចិត្តដល់ម្ដាយវិញ។

## មេរៀនទី ២ - ផ្នែកទី ២

## កិច្ចការ:

ចូរអានបទគម្ពីរចាប់ពីខ ២៩-៣៤ ដើម្បីសិក្សាអំពីអត្តចរិតលក្ខណៈរបស់កូនប្រុសភ្លោះទាំងពីរនេះ។

## លំហាត់បន្ទះ:

តាមការជាក់ស្ដែង យ៉ាកុប គឺជាមនុស្សម្នាក់ដែលជំនាញខាងជួយកិច្ចការងារក្នុងផ្ទះ រីឯ អេសាវ វិញ គឺជាមនុស្សម្នាក់ដែលពូកែ ហើយជំនាញខាងការងារធ្ងន់ៗនៅក្រៅផ្ទះ។

- នៅក្នុងខ ២៩ មានថ្ងៃមួយពេលអេសាវវិលត្រឡប់មកផ្ទះ តើគាត់មានសភាពយ៉ាងដូចម្ដេច? ___

______________________

______________________

- នៅក្នុងខ ៣០ តើមានអ្វីតម្រូវអេសាវដោះដូរ? ______________________
- នៅក្នុងខ ៣១ យ៉ាកុបនឹងមិនឲ្យអ្វីទៅអេសាវដោយគ្មានការចចារគ្នានោះទេ។ តើយ៉ាកុបមានសំណើរបែបណាទៅអេសាវជាងបង? ______________________

______________________

______________________

## សេចក្តីបង្រៀនៈ

នៅក្នុងខ ៣១ បាននិយាយអំពី "សិទ្ធជាកូនច្បង!" ជាទូទៅសិទ្ធជាកូនច្បងត្រូវតែជាកម្មសិទ្ធរបស់កូនប្រុសដែលបានកើតមកមុខគេអង្គុស់នៅក្នុងគ្រួសារទោះបីជាកូនរបស់ប្រពន្ធដើម ឬប្រពន្ធចុងក្តី។ កូនប្រុសណាដែលជាម្ចាស់លើសិទ្ធិកូនច្បងនេះទៀតសោត នឹងបានជាមេដឹកនាំក្នុងគ្រួសារ ហើយរាល់កេរ្តិ៍មរតក នឹងត្រូវបានផ្ទេរបន្តទៅខ្សែលោហិតជំនាន់ក្រោយតាមរយៈអ្នកជាម្ចាស់លើសិទ្ធកូនច្បង ជាងនេះទៅទៀតនោះគឺនឹងត្រូវទទួលបានចំណែកកេរ្តិ៍មរតកពីឪពុកច្រើនជាងកូនឯទៀតៗពីរដង។

អ្វីដែលយ៉ាកុបបានស្នើរសុំពីបងប្រុសរបស់គាត់គឺមិនមែនជារឿងតូចតាចឡើយ គឺគាត់ចង់ធ្វើម្ចាស់លើសិទ្ធិជាកូនច្បងពីអេសាវជាបងគាត់។ ចូរយើងនឹកចាំអំពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ រេបេកា ទ្រង់បានប្រាប់ថា មនុស្សចាស់ នឹងបម្រើក្មេង។ យ៉ាកុបគឺជាមនុស្សឆ្លាត ព្រោះគាត់ដឹងថាអេសាវគឺជាមនុស្សងាយស្រួលបោកបញ្ឆោត។ អេសាវ គិតអំពីរឿងចំណីអាហារជាជាងអ្វីៗទាំងអស់ តើសិទ្ធិជាកូនច្បងនឹងបានល្អប្រសើរយ៉ាង ប្រសិនគាត់បានស្លាប់ទៅ?

**លំហាត់បន្ត:** ចូរយើងបន្តចាប់ពីខ ៣៣ ទៅ...

- យ៉ាកុបបានទទួចចង់ឲ្យ អេសាវស្បថមុននឹងគាត់បរិភោក? ពេលនោះតើ អេសាវ ធ្វើដូចម្តេច? _

  ________________________________________

  ________________________________________

  ________________________________________

  ទង្វើរនៃការស្បថនៅពេលនោះ គឺប្រៀបបីដូចជាការលក់សិទ្ធិកូនច្បង សិទ្ធិទទួលមរតក និងសិទ្ធិផ្សេងៗទៀតរបស់គាត់ឲ្យទៅយ៉ាងកុបដែរ។

- នៅក្នុងខ ៣៤ ក្នុងខណៈនោះ យ៉ាកុប ក៏បានឲ្យអ្វីដែល អេសាវ ចង់បរិភោគ។ តើ អេសាវ បានលក់សិទ្ធិកូនច្បងរបស់គាត់ដើម្បីបានអ្វីមកបរិភោគ? ____________________

  ________________________________________

  ________________________________________

  ហេតុអ្វីបានជាអេសាវឆោតល្ងង់យ៉ាងនេះ! ព្រោះតែបបរសណ្តែកមួយចានប៉ុណ្ណោះ គាត់បែរជាសុខចិត្តប្រគល់សិទ្ធិជាកូនច្បងឲ្យទីយ៉ាកុបជាប្អូន។
  នៅខាងចុងខនេះ បាននិយាយប្រាប់យើងថា អេសាវ បានបរិភោគ ហើយគាត់ក៏បានងើបឡើង រួចបានចេញបាត់ទៅ "ដូច្នេះ ____________________

## មេរៀនទី ២ - ផ្នែកទី ៣
## តើយើងបានសិក្សាអ្វីខ្លះអំពីព្រះជាម្ចាស់?

សាច់រឿងស្ដីអំពីសិទ្ធិកូនច្បងនេះត្រូវបានបញ្ចប់ទៅយ៉ាងខ្លីត្រឹមតែ ១៥ ខក៏ពិតមែន ប៉ុន្តែយ៉ាងបានរៀនអំពីរឿងរ៉ាវជាច្រើនដែលទាក់ទងជាមួយនឹងក្រុមគ្រួសាររបស់អ៊ីសាក់ គឺយើងសិក្សាអំពីសមាជិកនិមួយៗក្នុងគ្រួសាររបស់គាត់ ជាពិសេសទៅទៀតនោះ គឺយើងបានដឹងអំពីនិន្នការ និង ចំណង់ចំណូលចិត្ត។ យើងក៏បានស្រាវជ្រាវឃើញពីគុណតម្លៃនៃកូនប្រុសណាមួយដែលបានទទួលសិទ្ធិកូនច្បង។ នៅមានទៀតគឺថាសមាជិកម្នាក់ប្រឆាំងតទល់នឹងម្នាក់ទៀត ដោយពួកគេម្នាក់ៗខំប្រឹងព្យាយាមគេងយកផលប្រយោជន៍ពីគ្នាទៅវិញទៅមក។ តែព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យស្មោះត្រង់ ចំពោះសេចក្ដីសន្យារបស់ទ្រង់ជាមួយនឹងលោក អប្រាហាំ និង គ្រួសាររបស់គាត់ជានិច្ច ដរាបដល់ពួកគេបានទទួលគ្រង់មរតកនៃសេចក្ដីសន្យា។

យើងបានធ្វើឲ្យបាត់លក្ខណៈដើមដោយសារការគិតរបស់យើង ហើយបែរជាជឿថាព្រះជាម្ចាស់មិនអាចប្រើយើងបានទេ ដ្បិតជីវិតមានពេញដោយទុក្ខព្រួយ។ យើងតែងតែជឿជាក់ថាសេចក្ដីសន្យារបស់ព្រះជាម្ចាស់បានសម្រេចឬក៏យ៉ាងណាគឺវាអាស្រ័យលើអកប្បកិរិយា និង ការប្រព្រឹត្តរបស់យើង ហើយយើងតែងតែគិតទៀតថា ការប្រព្រឹត្តរបស់យើងបែបណា នោះគឺជាការកំណត់បានថាព្រះជាម្ចាស់ក៏នឹងប្រព្រឹត្តដូច្នោះមកលើជីវិតរបស់យើងដែរ គឺគិតថាបើយើងធ្វើល្អ នោះទ្រង់នឹងប្រទានពរ តែបើយើងមិនបានធ្វើល្អ នោះទ្រង់ក៏នឹងមិនប្រទានពរឲ្យយើងដែរ។ អេសាវ ស្រេកឃ្លានចង់បានចំណីអាហារដើម្បីចំអែតក្រពះ ពេលនោះ យ៉ាកុបបានមើលឃើញជាឱកាសល្អក៏ឈ្លៀតទាញយកផលប្រយោជន៍ដើម្បីសម្រេចបានសិទ្ធិជាកូនច្បង។ ក្នុងពេលជាមួយគ្នានោះ យើងក៏សង្កេតឃើញថាកូនបងត្រូវបានឪពុកបង្គាប់ឲ្យទៅរកម្ហូបអាហារដែលគាត់ចូលចិត្តមុននឹងគាត់ប្រទានពរឲ្យ តែយ៉ាកុបកបានយកឱកាសបន្លំខ្លួនទទួលបានមរតកពីបងប្រុសរបស់គាត់ទៀត។

សកម្មភាពរបស់ព្រះជាម្ចាស់មិនមែនអាស្រ័យទៅលើអកប្បកិរិយារបស់យើងនោះទេ! ព្រះជាម្ចាស់ធ្វើអ្វីៗក៏ដោយមួយនឹងយើង គឺអាស្រ័យទៅលើការចងសម្ព័ន្ធមេត្រីដែលទ្រង់បានចងទុកនឹងយើង។ ព្រះជាម្ចាស់បានសន្យានឹងយើង ព្រះអង្គបានសន្យាជាមួយនឹងលោក អប្រាហាំ ដែលជាសម្ព័ន្ធមេត្រីដ៏នៅអស់កល្បសម្រាប់គាត់ កូនចៅរបស់គាត់គ្រប់ៗជំនាន់ និង ពូជពង្សក្រោយរបស់គាត់ដែរ។ ព្រះជាម្ចាស់មិនបានថ្លឹងថ្លែងថាទ្រង់នឹងសម្រេចតាមសេចក្ដីសន្យា "បើសិនជាពួកគេបានប្រព្រឹត្តអំពើល្អគ្រប់គ្រាន់" ឬថា "បើសិនជាពួកគេព្រមធ្វើទៅតាមការបង្គាប់របស់ទ្រង់" ឬថា "បើសិនជាពួកគេបានគោរពតាមពាក្យសម្ដី"។ តាមការជាក់ស្ដែងព្រះជាម្ចាស់មិនបានប្រព្រឹត្តដូចការរៀបរាប់ខាងលើនោះឡើយ គឺទ្រង់ធ្វើអ្វីៗទៅតាមព្រះបន្ទូលរបស់ទ្រង់។ ព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អប្រាហាំ អ៊ីសាក់ និង កូនៗរបស់ពួកគេ គឺទ្រង់បានធ្វើទៅតាមអ្វីដែលទ្រង់បានសន្យាដូច្នោះមែន! អ្វីៗគ្រប់យ៉ាងដែលទ្រង់បានធ្វើគឺព្រោះតែសេចក្ដីស្រលាញ់យ៉ាង

អស្ចារ្យរបស់ទ្រង់ចំពោះមនុស្សគ្រប់ៗរូប។ យើងទាំងអស់គ្នាក៏មានចំណែកនៅក្នុងសេចក្តីសន្យានោះដែរ គឺតាមរយៈទទួលពិធីបុណ្យជ្រមុជទឹក ហើយសេចក្តីសន្យានេះត្រូវបានសម្រេចឬយ៉ាងណាគឺអាស្រ័យព្រះអង្គទាំងស្រុង បើទោះបីជាយើងមានចិត្តសង្ស័យលើទ្រង់ក្តី មិនស្មោះត្រង់ក្តី ឬបានឆក់ឱកាសទាញយកផលប្រយោជន៍ពីអ្នកដទៃយ៉ាងណាក្តី ក៏ទ្រង់នៅតែស្មោះត្រង់ នៅតែប្រកាន់យកសេចក្តីពិត ហើយធ្វើអ្វីទៅតាមព្រះបន្ទូលបានសន្យា។

ទោះបីជានិស្ស័យជាមនុស្សរបស់យើងម្នាក់ៗយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់នាំរាស្ត្ររបស់ទ្រង់ឲ្យការពាក់ព័ន្ធក្នុងផែនការណ៍ទ្រង់ ក្នុងគោលបំណងតែមួយគាត់គឺចង់ឲ្យមនុស្សគ្រប់ៗគ្នាបានត្រឡប់រកសភាពដើមដូចដែលទ្រង់បានបង្កើតពួកគេកាលពីដំបូងមក។ ទ្រង់បានជ្រើសរើស សម្រាប់សេចក្តីប្រោសលោះគ្រប់មនុស្សទាំងអស់ឲ្យបានរួចចេញពីអំពើបាប ហើយចង់ឲ្យពួកគេរស់នៅក្នុងជីវិតប្រកបសេរីភាព និង ការអត់ទោសបាប។ សេចក្តីប្រោសលោះរបស់យើងទាំងអស់គ្នាគឺមាននៅក្នុងទ្រង់! ព្រះជាម្ចាស់ផ្ទាល់ក៏កូនច្បងម្នាក់ដែរទ្រង់មានព្រះនាមថា "យេស៊ូវ" ទ្រង់បានទទួលខុសត្រូវក្នុងនាមជាកូនច្បងយ៉ាងយកព្រះហឫទ័យទុកខ្ពស់បំផុត។ ជាការរំលឹកឲ្យយើងនឹកឃើញឡើងវិញតាមរយៈបទគម្ពីរ យ៉ូហាន ៣:១៦-១៧! ចូរកត់ត្រានូវបទគម្ពីរនេះឡើងវិញ

យើងទាំងអស់គ្នាពិតបានទទួលព្រះពរហើយ ដ្បិតព្រះយេស៊ូវដែលកូនច្បងនៃយើងទ្រង់មិនបានលក់សិទ្ធិជាកូនច្បងរបស់ទ្រង់ទៅឲ្យនរណាម្នាក់ឡើយ ទ្រង់បានយាងមកក្នុងឋានៈជាកូនច្បង ជាព្រះរាជបុត្រាតែមួយដែលស្ម័លះចោលសិរីល្អគ្រប់យ៉ាង ដើម្បីប្តូរយកជីវិតដ៏នៅអស់កល្បជានិច្ចសម្រាប់អស់អ្នកណាដែលបានទទួលជឿដល់ទ្រង់។ មានន័យថាព្រះជាម្ចាស់បានចាត់អង្គព្រះយេស៊ូវឲ្យយាងមកដើម្បីផ្សះផ្សារទំនាក់ទំនងរវាងមនុស្សទាំងអស់ ឲ្យបានជានាជាមួយនឹងព្រះវរបិតាឡើងវិញ ហើយនាំពួកគេទាំងនោះឡើងទៅកាន់នរគស្ថានសួគ៌ជាមួយនឹងព្រះបុត្រានៃព្រះជាម្ចាស់លើអ្វីៗទាំងអស់។

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ទូលបង្គំបានប្រព្រឹត្តដោយមានចិត្តមន្ទិលសង្ស័យចំពោះអ្នកដទៃ ដើម្បីធ្វើយ៉ាងណាក៏ដោយឲ្យតែបានសម្រេចតាមអ្វីចង់បាន! ទូលបង្គំបានគិត ហើយបានប្រព្រឹត្តចំពោះសមាជិកគ្រួសារ ចំពោះមិត្តភ័ក្ររួមការងារ។ ជារឿយៗ អ្វីៗគ្រប់យ៉ាងគឺទូលបង្គំឯកោតែម្នាក់ឯង ហើយមានពេញដោយបន្ទុក នៃក្តីអស់សង្ឃឹមព្រោះដឹងខ្លួនឯងថាមានកំហុស។ ឱព្រះយេស៊ូវអើយ! សូមជួយឲ្យទូលបង្គំមានចិត្តក្លាហានក្នុងការសារភាពអំពើបាប ហើយលន់តួចំពោះព្រះអង្គផង! ទូលងបង្គំដឹងថាមានតែព្រះអង្គមួយគាត់ដែលអាចចម្រើនកម្លាំងឲ្យទូលបង្គំបាន ហើយអាចបំផ្លាស់បំប្រែឲ្យទូលបង្គំមានសេចក្តីស្មោះត្រង់ និង ជួយឲ្យទូលបង្គំប្រព្រឹត្តនូវអំពើល្អបាន។ ទូលបង្គំសូមឲ្យព្រះអង្គធ្វើការក្នុងគ្រប់ផ្នែកនៃជីវិតរបស់ទូលបង្គំ ដូចជា ____

________________________________________________

________________________________________________

________________________________________________

________________________________________________

## មេរៀនទី ២ - ផ្នែកទី ៤

## សេចក្តីណែនាំៈ

យើងនឹងចាប់ផ្តើមដោយការដាស់អារម្មណ៍ ឲ្យដឹងបានដឹងនូវរឿងរ៉ាវមួយចំនួនដែលកើតឡើងមិនប្រក្រតីនៅក្នុងរង្វង់គ្រួសាររបស់អ៊ីសាក់។ ព្រះជាម្ចាស់បានបើកសម្តែងឲ្យ រេបេកា ដឹងថានាងនឹងមានកូនប្រុសភ្លោះ ហើយនឹងបានជាជាតិសាសន៍ពីរផ្សេងពីគ្នា។ កូនប្រុសម្នាក់ឈ្មោះថា យ៉ាកុប ដែលមានអត្ថន័យថា "គាត់បោកបញ្ឆោត" ឌើយការបោកបញ្ឆោតនេះគឺជាអ្វីដែលគាត់ប្រព្រឹត្ត! នៅពីរបីជំពូកទៅមុខទៀតយើងនឹងបានដឹងថាតើយ៉ាកុបគឺជាអ្នកបោកបញ្ឆោតយ៉ាងដូចម្តេច តើគាត់គឺជាអ្នកបោកបញ្ឆោតគេ ឬ គេបោកបញ្ឆោតគាត់? យើងទើបនឹងបានសិក្សានៅក្នុងមេរៀនទី ២ ផ្នែកទី ៤ ឃើញថា យ៉ាកុប បានបោកបញ្ឆោតអេសាវជាបងរហូតទទួលបានសិទ្ធិជាកូនច្បងរួចមកហើយ។ នៅក្នុងទង្វើបែបនេះក៏បញ្ជាក់ឲ្យឃើញថា អេសាវ ក៏គ្មានតម្លៃសក្តិសមធ្វើជាកូនច្បងក្នុងគ្រួសារដែរ។ ជាងនេះទៅទៀតនោះ គឺគាត់បានសម្រេចចិត្តយកស្ត្រីសាសន៍ហេត មកធ្វើជាប្រពន្ធ (លោកុប្បត្តិ ២៦:៣៤-៣៥) ហើយកំណត់ជីវិតដោយធ្វើអ្វីៗដោយខ្លួនឯង។ តាមរយៈសាច់រឿងបានប្រាប់ឲ្យយើងដឹងថា គាត់មានចិត្តមើលងាយហើយបានងាកចេញពីឪពុកម្តាយ និង ព្រះជាម្ចាស់ដែលហេតុធ្វើឲ្យមិនមានការគោរពដល់ឪពុកម្តាយ។ មានរឿងសំខាន់មួយដែលរំលឹកឲ្យយើងបានដឹងថា យ៉ាកុបបានទទួលព្រះពរគ្រប់យ៉ាងពីលោក អប្រាហាំ គឺសេចក្តីសន្យាទាំងប៉ុន្មានដែលព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អប្រាហាំ ក៏បានបន្តមកអ៊ីសាក់ ហើយបន្តរហូតមកដល់យ៉ាកុប។

## សេចក្តីបង្រៀនៈ

សិទ្ធិជាកូនច្បង និង ព្រះពរ គឺជាអំណោយដែលព្រះជាម្ចាស់បានប្រទានឲ្យតាមរយៈឪពុកដល់កូនប្រុសណាដែលបានកើតមកមុនគេនៅក្នុងគ្រួសារ។ កូនច្បងមានសិទ្ធិទទួលកេរ្តិ៍មរតកបន្តពីឪពុក ចំណែកឯព្រះពរវិញក៏នឹងត្រូវបានប្រកាសដោយឪពុកថានឹងឲ្យដល់កូនប្រុសម្នាក់ណា នោះនឹងបានគេនឹងបានទទួលពេញមួយជីវិត។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៥:២៧-៣៤ យើងបានសិក្សាអំពីយ៉ាកុបបានទទួលសិទ្ធជាកូនច្បងពីអេសាវជាបងរបស់គាត់។ លុះដល់លោកុប្បត្តិជំពូក ២៧ យើងនឹងសិក្សាអំពីថាតើអេសាវបានទទួលព្រះយ៉ាងដូចម្តេច។

**កិច្ចការៈ** ចូរអានព្រះគម្ពីរលោកុប្បត្តិ ២៧:១-២៩

**លំហាត់ៈ** ចូរយើងសង្កេតមើលបទគម្ពីរទាំងនេះ ហើយថាតើសាច់រឿងនឹងទៅជាយ៉ាងណា?

- តើស្ថានភាពសុខភាពរបស់អ៊ីសាក់យ៉ាងដូចម្តេច? ______________________________

  ______________________________________________________________

  ______________________________________________________________

- អ៊ីសាក់ ទទួលស្គាល់ថាអាយុជីវិតរបស់គឺមានចំនួនកំណត់។ គាត់មានវ័យកាន់តែចាស់ គាត់ក៏ខ្សោយហើយពិការភ្នែកទៀត។ គាត់ដឹងថាដល់ពេលដែលត្រូវប្រទានឲ្យកូនប្រុសរបស់គាត់ ដូច្នេះគាត់ក៏ផ្តើមគំនិតដោយអេសាវឲ្យមកជួបនឹងគាត់។ នៅក្នុងខ ៣-៤ តើអ៊ីសាក់ប្រាប់ឲ្យអេសាវធ្វើអ្វីខ្លះ?

  ១. ____________________________________________________________

  ២. ____________________________________________________________

  ៣. ____________________________________________________________
- អ៊ីសាក់គាត់ថា "គឺដល់ពេលដែលខ្ញុំអាចប្រទានពរដល់គេមុនពេលខ្ញុំស្លាប់បានហើយ" ។

## សេចក្តីបង្រៀនៈ

ទោះបីជាអ៊ីសាក់បានស្គាល់អេសាវប៉ុណ្ណាក៏ដោយ តែគាត់បានកំណត់ថានឹងប្រទានពរដល់អេសាវដែរ ព្រោះគេគឺជាកូនសំណព្វចិត្តរបស់គាត់។ ឪពុកនឹងកូនទាំងពីរនាក់បានចែករំលែកសេចក្តីស្រលាញ់ដល់គ្នាទៅវិញទៅមកក្នុងការប្រម៉ាញ់ជាមួយគ្នា (លោកុប្បត្តិ ២៥:២៧-២៨)។ ប៉ុន្តែ អេសាវបានបដិសេធន៍មិនព្រមទទួលស្គាល់ព្រះរបស់ឪពុកគាត់ ដោយគាត់សម្រេចចិត្តធ្វើតាមគំនិតរបស់ខ្លួនឯង ដូចជាការទៅយកប្រពន្ធពីគ្រួសារ អ៊ីស្មាអែល ក្រោយៗមកទៀតគាត់ក៏បានដាច់ចេញពីសម្ព័ន្ធមេត្រីដែលព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អប្រាហាំ តាំងពីដើមដំបូងមកម្លេះ។

## មេរៀនទី ២ - ផ្នែកទី ៥

## លំហាត់:

កូនប្រុសសំណព្វចិត្តរបស់រេបេកា គឺយ៉ាកុប! នាងបានស្តាប់ឮការសន្ទនាគ្នារវាងអ៊ីសាក់ជាមួយនឹងអេសាវ ដូច្នេះហើយ នាងមានគំនិតទាញយកព្រះពរនេះ តែមិនមែនសម្រាប់រូបនាងផ្ទាល់ទេ គឺសម្រាប់យ៉ាកុបជាកូនប្រុសសំណព្វរបស់នាង។

- នៅពេលដែលអេសាវចាកចេញទៅ តើរេបេកាបានធ្វើអ្វីខ្លះ (លោកុប្បត្តិ ២៧:៦-៧)? ______

____________________________________________

____________________________________________

- តើនាងបានណែនាំដល់យ៉ាកុបយ៉ាងដូចម្តេចខ្លះ នៅក្នុងខ ៨? ______________________

____________________________________________

  - o នៅក្នុងខ ៩ ____________________________________

    ____________________________________________

  - o នៅក្នុងខ ១០ ___________________________________

    ____________________________________________

នាងក៏ចាប់ផ្តើមរៀបចំគម្រោងការដូចជាអ៊ីសាក់ដែរ! "ខ្ញុំនឹងអាចប្រទានពរដល់គេមុនពេលខ្ញុំស្លាប់ដែរហើយ" (លោកុប្បត្តិ ២៧:១០)

- ទោះបីជាយ៉ាងក៏ដោយ អ៊ីសាក់ គាត់ដឹងថានឹងមានបញ្ហាខ្លះៗចំពោះគម្រោងការរបស់គាត់។ តើគាត់បានគិតគួរដល់រឿងអ្វី (ខ ១១-១២)? ______________________________

____________________________________________

____________________________________________

ជាការជាក់ស្តែង រឿងដែលធំបំផុតនោះគឺទង្វើនៃការបោកបញ្ឆោត គឺនឹងត្រូវបណ្តាសារជាជាងទទួលព្រះពរដោយសារឪពុក។

- រេបេកា បានចេញមុខរៀបចំផែនការណ៍នេះដោយមានការប្តេជ្ញាចិត្តរួចជាស្រេចថាបើត្រូវទទួលបណ្តាសារនោះនាងសុខចិត្តឲ្យបណ្តាសារនោះធ្លាក់មកលើរូបនាងចុះ គឺធ្វើយ៉ាងឲ្យតែយ៉ាកុបបានបានទទួលព្រះពរពីអ៊ីសាក់។ នៅក្នុងខ ១៣ តើរេបេកាប្រញាប់ប្រញាល់ធ្វើអ្វី។ តើនាងបាននិយាយអ្វីខ្លះ? ______________________________

____________________________________________

- ក្រោយពីបានទទួលការណែនាំពីម្តាយរួចហើយ យ៉ាកុបក៏ស្តាប់បង្គាប់ធ្វើតាមគ្រប់យ៉ាងតាមម្តាយបង្គាប់ក្នុងការទទួលយកព្រះពររបស់បងប្រុសខ្លួនពីឪពុក។ ចូរកត់សម្គាល់នូវអ្វីដែលពួកគេបានធ្វើអ្វីៗទៅតាមលំដាប់លំដោយដើម្បីឲ្យបានប្រាកដថា អ៊ីសាក់បម្រុងនឹងប្រទានពរឲ្យ។
  - ក្នុងខ ១៤ ______________________________
    ______________________________
  - ក្នុងខ ១៥ ______________________________
    ______________________________
  - ក្នុងខ ១៦ ______________________________
    ______________________________
- បន្ទាប់មកយ៉ាកុបក៏បានចូលទៅជួបនឹងឪពុករបស់ខ្លួន។ នៅក្នុងខ ១៨ តើជាដំបូងអ៊ីសាក់បានសួរសំនួរដូចម្តេច? ______________________________
  ______________________________
  ______________________________
- នៅក្នុងខ ១៩ តើយ៉ាកុបបានឆ្លើយតបវិញយ៉ាងដូចម្តេច? ______________________________
  ______________________________
- នៅក្នុងខ ២០ អ៊ីសាក់មានការភ្ញាក់ផ្អើលដោយអេសាវវិលត្រឡប់មកផ្ទះយ៉ាងលឿន។ រួចគាត់ក៏បានសួរថា ______________________________
  ______________________________
  ______________________________
- យ៉ាកុបបានឆ្លើយថា ______________________________
  ______________________________
- នៅក្នុងខ ២១ អ៊ីសាក់ចង់ឲ្យប្រាកដថាពិតជាអេសាវ ដូច្នេះគាត់បានឲ្យចូលមកជិត រួចគាត់ក៏ស្ទាបហេតុអ្វីបានអ៊ីសាក់មានចិត្តសង្ស័យថាមិនមែនជាអេសាវ មកពីគាត់ធ្លាប់មានបទពិសោធន៍ត្រូវបានគេបោកបញ្ឆោតឬ? ឬមួយគាត់ធ្លាប់បោកបញ្ឆោតគេ? តើអ្នកមានគំនិតដូចម្តេច? __________
  ______________________________
  ______________________________

អ៊ីសាក់ធ្លាប់បានរស់នៅក្នុងគ្រួសារមួយបោកបញ្ឆោត! ប្រពន្ធរបស់គាត់ផ្ទាល់ជ្រើសរើសវិធីបោកបញ្ឆោតប្តីរបស់ខ្លួនដើម្បីឲ្យយ៉ាកុបបានទទួលអ្វីដែលនាងគិតថាជារឿងត្រឹមត្រូវ។ យ៉ាកុបក៏ធ្លាប់

បោកបញ្ឆោតបងប្រុសរបស់ខ្លួនដើម្បីទទួលបានសិទ្ធិជាកូនច្បងដែរ។ ហើយឥឡូវនេះ ម្ដាយ និង កូនប្រុស ក្រោយពីឪពុកបានប្រទានពរឲ្យរួចរាល់ហើយទើបដឹងថាអ្វីៗគ្រប់បែបយ៉ាងគឺត្រូវចាញ់បោកយ៉ាកុបទាំងអស់គ្នា។

- ដោយសារតែសម្លេងរបស់យ៉ាកុបស្រដៀងគ្នានឹងសម្លេងរបស់អេសាវ ហើយមានពេញដោយរោមនៅលើដៃទៀតផងនោះ ហេតុនេះហើយទើបផែនការបោកបញ្ឆោតរបស់គាត់បានទទួលជោគជ័យដោយគ្មានឧបសគ្គ។ នៅក្នុងខ ២៤ អ៊ីសាក់បានសួរម្ដងទៀត ______________________

  ______________________________________________

- រួចយ៉ាកុបបានឆ្លើយតបវិញ ______________________________

  ______________________________________________

- អ៊ីសាក់បានប្រាប់ឲ្យម្ហូបអាហារដែលគេបានរៀបចំទុកមកឲ្យគាត់។ រួចគាត់ក៏បានបរិភោគរួចរាល់ដោយមានទាំងពិសារស្រាទំពាំងបាយជូរផង។ ខណៈអ៊ីសាក់បានបង្គាប់ឲ្យយ៉ាកុបចូលមកជិត រួចគាត់បានថើប! នៅក្នុងខ ២៧ តើអ៊ីសាក់ធ្វើដូចម្ដេចក្នុងការបញ្ជាក់លើកចុងក្រោយដើម្បីឲ្យប្រាកដថាពិតជាអេសាវ? ______________________________

  ______________________________________________

- នៅទីបញ្ចប់ ព្រះពរត្រូវបានប្រទានឲ្យរួចរាល់! តើព្រះពរទាំងនោះមានអ្វីខ្លះ? (ខ ២៨-២៩)

  1. "សូមឲ្យព្រះជាម្ចាស់ ______________________________

     ______________________________________________

     ______________________________________________

  2. សូមឲ្យជាតិសាសន៍ ______________________________

     ______________________________________________

     ______________________________________________

  3. សូមឲ្យកូនប្រុសៗ ______________________________

     ______________________________________________

     ______________________________________________

  4. សូមឲ្យអស់អ្នកណា ______________________________

     ______________________________________________

     ______________________________________________

## ការអនុវត្តន៍ផ្ទាល់ខ្លួន:

តើព្រះពរអ្វីខ្លះដែលអ៊ីសាក់បានប្រគល់ឲ្យទៅយ៉ាកុបកូនប្រុសរបស់គាត់? តើអ្នកធ្លាប់បានទទួលព្រះពរបែបនេះពីនរណាម្នាក់ពីមុនមកដែរឬទេ? ពីឪពុកម្តាយ? ពីមិត្តភ័ក្រ? ពីគ្រូគង្វាល ឬចាស់ទុំនៅក្នុងពួកជំនុំ? នៅក្នុងវប្បធម៌ជាច្រើនការពរដល់កូនចៅគឺមិនដូចគ្នានោះឡើយ។ តែទោះបីជាយ៉ាងណាក៏ដោយអស់អ្នកណាដែលបានទទួលព្រះពរ គឺជាអ្នកដែលពិសេស ហើយចម្រុងចម្រើនជាមិនខាន។ តើលោកអ្នកធ្លាប់បានឮព្រះជាម្ចាស់ប្រទានពរសម្រាប់ជីវិតរបស់លោកអ្នកដែរឬទេ?

- តើលោកអ្នកចង់ឮព្រះជាម្ចាស់ប្រទានពរសម្រាប់លោកអ្នកយ៉ាងដូចម្តេច? ______________

  ______________________________________________

  ______________________________________________

  ______________________________________________

- តើព្រះពរបែបណាដែលលោកអ្នកចង់ប្រគល់ឲ្យទៅកូនចៅរបស់លោកអ្នក ប្តីឬប្រពន្ធ មិត្តភ័ក្រ ឬអ្នករួមការងាររបស់លោកអ្នក? ______________________________

  ______________________________________________

  ______________________________________________

  ______________________________________________

  ជាទូទៅបើឪពុកម្តាយប្រទានពរដល់កូនចៅ ប្រហែលជាកូនចៅនោះត្រូវចាកចេញពីផ្ទះ។ ចូរចងចាំថាលោកអ្នកត្រូវនិយាយថា "ឪពុក/ម្តាយស្រលាញ់កូន!"។

- ចូររំលឹកឡើងវិញកាលដែលព្រះជាម្ចាស់បានប្រទានពរដល់លោក អប្រាហាំ គឺដើម្បីឲ្យគាត់បានប្រទានពរដល់អ្នកដទៃដែរ។ ចូរគិតពិចារណាថាតើលោកអ្នកនឹងប្រទានពរដល់អ្នកណាខ្លះ។ តើលោកអ្នកគិតថានឹងត្រូវប្រទានពរដល់នរណាខ្លះ? ______________________

  ______________________________________________

  ______________________________________________

  ______________________________________________

  តើលោកអ្នកនឹងនិយាយយ៉ាងណា ឬ ត្រូវធ្វើដូចម្តេចក្នុងការប្រទានពរដល់អ្នកនោះ? ________

  ______________________________________________

  ______________________________________________

  ______________________________________________

  ______________________________________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ព្រះអង្គបានប្រទានពរដល់ទូលបង្គំ! ទូលបង្គំមិនដែលគិតថានឹងត្រូវទ្រង់បោកបញ្ឆោតទាល់តែសោះ ផ្ទុយទៅវិញមានតែព្រះអង្គមួយប៉ុណ្ណោះដែលតែងតែចង់ប្រទានអ្វីដែលល្អបំផុតសម្រាប់ទូលបង្គំ ដូច្នេះព្រះអង្គអើយ! សូមឲ្យទូលបង្គំបានឮព្រះសូរសៀងព្រះទានពររបស់ទ្រង់ដល់ទូលបង្គំផង! សូមព្រះនៃសេចក្តីសង្ឃឹម បំពេញលោកអ្នកដោយសេចក្តីអំណរ និង សេចក្តីសុខសុខសាន្តដូចដែលលោកអ្នកបានទុកចិត្តលើទ្រង់ ដើម្បីឲ្យលោកអ្នកបានពេញហូរហៀរទៅដោយ សេចក្តីសង្ឃឹមតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ (រ៉ូម ១៥:១៣)។ សូមទូលបង្គំបានជាទីបញ្ចេញព្រះពរដល់អ្នកដទៃទៀតផង! សូមអ្វីៗដែលទូលបង្គំធ្វើបានជាសិរីល្អ និង ព្រះកិត្តនាមដល់ព្រះអង្គជារៀងរហូត។ ____________________

____________________________________________________________

____________________________________________________________

____________________________________________________________

# មេរៀនទី ៣

## មេរៀនទី ៣ - ផ្នែកទី ១

**កិច្ចការៈ** ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ២៧ សារឡើងវិញ!

## សេចក្តីបង្រៀនៈ

ចាប់តាំងពីបានសិក្សាអំពីការបោកបញ្ឆោតអស់ជាច្រើនផ្នែកនៃសាច់រឿង រហូតធ្វើមានអ្នកខ្លះក៏បានអនុវត្តតាម! ពេលនេះគឺសមល្មមនឹងយើងចំណាយពេលវេលាខ្លះដើម្បីសិក្សាផ្នែកផ្សេងទៀតនៃព្រះគម្ពីរដែលបាននិយាយអំពីការបោកបញ្ឆោតនេះទាំងអស់គ្នា។ តើការបោកបញ្ឆោតគឺជាអ្វី? តើអ្នកប្រព្រឹត្តអំពើឆបោកនឹងត្រូវទទួលលទ្ធផលដូចម្តេច? តើអ្វីដែលជាឫសគល់នៃបញ្ហា? នៅក្នុងចម្លើយតទៅនេះតម្រូវឲ្យយើងចាកចេញពីព្រះគម្ពីរលោកុប្បត្តិ ២៧ បន្តិចដើម្បីរកមើលអំពីអំណះអំណាងខ្លះទាក់ទងនឹងបញ្ហានេះ។ ខាងក្រោមនេះនឹងតម្រូវឲ្យមានការអនុវត្តន៍ខ្លះតាមរយៈបទគម្ពីរ ដែលបានផ្តល់ជូនដកស្រង់ចេញពីព្រះគម្ពីរផ្សេងៗពីគ្នា ហើយបទគម្ពីរទាំងអស់នេះគឺជាព្រះបន្ទូលនៃព្រះ គឺជាឱកាសមួយដើម្បីបង្រៀនយើង។

- ម៉ាថាយ ១៣:២២-២៣ ជារឿយៗ តើអ្វីដែលតែងតែបោកបញ្ឆោតយើង? ______________

  ________________________________________

- យេរេមា ១៧:៩ តើអំពើបោកបញ្ឆោតវាកើតចេញមកពីណា?______________________

  ________________________________________

- ម៉ាកុស ៧:២០-២១ តើចិត្តមានទំនាក់ទំនងយ៉ាងដូចម្តេចចំពោះអំពើបោកបញ្ឆោត? ________

  ________________________________________

- លេវីវិន័យ ១៩:១១ តើព្រះជាម្ចាស់មានបង្គាប់ដូចម្តេច? __________________________

  ________________________________________

នៅក្នុងព្រះគម្ពីរម៉ាថាយបាននិយាយថា ការឆបោកគឺបណ្តាលមកពីទ្រព្យសម្បត្តិ។ មានពេលខ្លះយើងម្នាក់ៗធ្លាប់ត្រូវបានចេញការឆបោកទ្រព្យសម្បត្តិ ហើយការនេះជាទូទៅគឺបណ្តាលមកពី "វាគឺជាអ្វីៗដែលយើងត្រូវតែមាន!"។ មនុស្សមួយចំនួនបានទិញរបស់អ្វីមួយ ឬ ការទទួលស្គាល់បរិមាណនៃទ្រព្យសម្បត្តិ គឺយើងដឹងថា ត្រូវបានចាញ់ការឆបោកគេដោយជឿថា ពេលណាបានរបស់នោះមកហើយ វានឹងធ្វើឲ្យសុភមង្គល ឬ ធ្វើឲ្យបានស្កប់ចិត្ត តាមរយៈមិត្តភាព ឬ អ្វីមួយដែលយើងលង់ចិត្តជឿ។ ប៉ុន្តែ តាមពិតទៅនោះគឺសុទ្ធតែជាការបោកបញ្ឆោតឲ្យយើងលង់ជឿលើការកុហក់បោកប្រាស់ទាំងអស់។

នៅក្នុងព្រះគម្ពីរយេរេមា ប្រាប់យើងថា ចិត្តគឺជាគ្រឿងបោកបញ្ឆោតជាអ្វីៗទាំងអស់ ហើយតាមបទគម្ពីរប្រាប់យើងទៀតថា "ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន"។ អំពើបាបវាបានរីកសាយភាពពេញក្នុងចិត្តមនុស្ស ហើយកត្តាសំខាន់ដែលនាំឲ្យមានអំពើបាបគឺបណ្តាលមកពីការឆបោក។ ចូរយើងរំលឹងទៅដល់ហេតុការកាលនៅក្នុងសួនច្បារអេដែន នៅពេលដែលសត្វពស់វាបាននិយាយទៅកាន់ស្ត្រីគឺសុទ្ធតែជាពាក្យពេញដោយការបោកបញ្ឆោតទាំងអស់។ ហើយនៅក្នុងព្រះគម្ពីរម៉ាកុស ក៏បានប្រាប់យើងដែរថា នៅក្នុងចិត្តមនុស្សមានពេញទៅដោយការបោកបញ្ឆោត វាគឺជាបុព្វហេតុធ្វើឲ្យមនុស្សមានពេញដោយអំពើបាប។

ព្រះជាម្ចាស់បានបង្គាប់យើងតាមរយៈព្រះគម្ពីរលេវីវិន័យថា មិនត្រូវយើងឲ្យឆបោកគ្នាឡើយនេះគឺជាការល្អណាស់ ដែលទ្រង់បានប្រទានក្រិត្យវិន័យមក។ ចូរសម្គាល់ថា យ៉ាកុប នៅពេលដែលគាត់ប្រលោកខ្លួនចូលទៅក្នុងអំពើឆបោក គឺតម្រូវឲ្យគាត់និយាយកុហក់។ គាត់បានកុហក់ឪពុករបស់គាត់មិនមែនតែម្តងទេ គឺច្រើនដង! ពេលណាដែលមានការបោកបញ្ឆោត គឺពេលនោះប្រាកដជាមានការនិយាយកុហក់! នៅក្នុងព្រះគម្ពីរបង្រៀនយើងវិញ្ញាណអាក្រក់មួយចំនួនគឺជាមេបោកបញ្ឆោត ហើយឪពុករបស់វាគឺការកុហក់ ហើយនៅក្នុងពួកវាគ្មានសេចក្តីពិតឡើយ (យ៉ូហាន ៨:៤៤)។

ពាក្យផ្ទុយពីការឆបោក ឬ ការបោកបញ្ឆោតគឺជាសេចក្តីពិត! ពេលនេះចូលយើងសង្កេតមើលបទគម្ពីរមួយចំនួនដូចតទៅនេះដើម្បីសិក្សាជាមួយគ្នាអំពីសេចក្តីពិតវិញម្តង។

- សុភាសិត ១៤:៥ តើបន្ទាល់នៃសេចក្តីពិតមានលក្ខណៈដូចម្តេច? ____________________

  ______________________________________________

- អេភេសូរ ៤:២១-២៤ តើសេចក្តីពិតមានមកពីណា? ____________________

  ______________________________________________

- ១ កូរិនថូស ៣:១៨ តើយើងត្រូវឈប់ធ្វើអ្វី? ____________________

  ______________________________________________

- ១ យ៉ូហាន ១:៨-៩ ចូរសរសេរឡើងវិញនូវបទគម្ពីរនេះ ____________________

  ______________________________________________

  ______________________________________________

  ______________________________________________

- ១ ពេត្រុស ២:២១-២២ តើព្រះយេស៊ូវមានគំរូដូចម្តេចដែលយើងត្រូវយកតម្រាប់តាម?________

  ______________________________________________

  ______________________________________________

- យ៉ូហាន ១៤:៦ តើព្រះយេស៊ូវមានព្រះបន្ទូលដូចម្ដេចអំពីទ្រង់ផ្ទាល់? ____________________

____________________________________________________________

នៅក្នុងសេចក្ដីពិតគ្មានការបោកបញ្ឆោតទេ! សេចក្ដីពិតគឺគួរឲ្យទុកចិត្តបាន! តើអ៊ីសាក់ ព្យាយាមបញ្ជាក់ប៉ុន្មានដង ដើម្បីឲ្យប្រាកដថាអ្នកដែលគាត់នឹងប្រទានពរឲ្យនោះគឺពិតជាអេសាវកូនប្រុសសំណព្វគាត់? អំពើឆបោកគឺមាននៅក្នុងគ្រួសាររបស់គាត់តាំងមុនមកម្លេះ! ដូច្នេះហើយទើបបានជាគាត់មិនទុកចិត្តចំពោះអ្វីដែលមើលមិនឃើញ។ សេចក្ដីពិត និង ការឆបោកគឺមិនអាចនៅជាមួយគ្នាបានជាដាច់ខាត! ដ្បិតមួយ គឺជាបន្ទាល់ពីសេចក្ដីពិត ហើយមួយទៀតគឺជាបន្ទាល់ពីការឆបោក។

សេចក្ដីពិតគឺកើតចេញមកពីព្រះយេស៊ូវ! សេចក្ដីពិតនេះហើយដែលបញ្ជាក់ពីលក្ខណៈរបស់ទ្រង់។ ទ្រង់មានព្រះបន្ទូលថា ទ្រង់គឺជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត! យើងអាចទុកចិត្តលើសេចក្ដីពិតរបស់ទ្រង់បាន ក្នុងពេលណាវិញ្ញាណអាក្រក់វាមកបោកបញ្ឆោតយើងដោយការនិយាយកុហក់។ ការពិតយើងខ្លួនឯងត្រូវតែបញ្ឈប់ការបោកបញ្ឆោតខ្លួនឯងជាងនរណាៗទាំងអស់។ យើងបោកបញ្ឆោតខ្លួនឯងក្នុងករណីធ្វើឲ្យជឿថាយើងគឺជាអ្វីមួយ ទាំងការពិតយើងមិនមែនដូច្នោះទាល់តែសោះ។ ជួនកាលវាធ្វើឲ្យយើងគិតថា ខ្លួនឯងហ្នឹងជាមនុស្សពិសេស អស្ចារ្យ គ្រាន់បើ វិសេសវិសាលជាងនរណាៗទាំងអស់។ ចូរកុំឲ្យចាញ់ការបោកបញ្ឆោតខ្លួនឯងឡើយ ដ្បិតព្រះជាម្ចាស់មិនសព្វព្រះហឫទ័យចំពោះទង្វើបែបនេះឡើយ! សាវ័ក ប៉ូល បានប្រាប់យើងនៅក្នុងព្រះគម្ពីរកាឡាទី ៦:៧-៨ ថា អ្នកណាសាបព្រោះពូជអ្វី នឹងបានប្រមូលផលនោះជាក់ជាមិនខាន នេះបើតាមគោលការណ៍សកិកម្ម។ "កុំឲ្យច្រឡំឡើយ និងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ អ្នកណាដែលព្រោះខាងឯសាច់ឈាមរបស់ខ្លួន នឹងច្រូតបានសេចក្ដីពុករលួយពីសាច់ឈាមនោះឯង តែអ្នកណាដែលព្រោះខាងឯព្រះវិញ្ញាណ នោះនឹងច្រូតបានជីវិតអស់កល្បជានិច្ច ពីព្រះវិញ្ញាណវិញ"។

លោក យ៉ូហាន ចង់ឲ្យបានស្គាល់ទាំងដំណឹងល្អ និង ដំណឹងអាក្រក់! ដំណឹងអាក្រក់នោះគឺថា បើសិនថាយើងគ្មានបាប នោះឈ្មោះថាយើងបោកបញ្ឆោតខ្លួនឯងហើយ ព្រោះយើងមិនបានប្រាប់សេចក្ដីពិតដល់ខ្លួនឯង ហើយគាត់និយាយទៀតថា សេចក្ដីពិតមិននៅក្នុងយើងឡើយ! ប៉ុន្តែ បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង។ ដូចយើងបានដឹងអំពីភាពស្មោះត្រង់របស់ទ្រង់ចំពោះលោក អប្រាហាំ អ៊ីសាក់ យ៉ាកុប ហើយទ្រង់ក៏ស្មោះត្រង់ចំពោះយើងទាំងអស់គ្នាដែរ ព្រមទាំងអស់ទោសពីគ្រប់ទាំងអំពើបាបតាមរយៈអង្គព្រះយេស៊ូវទៀតផង។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់យើងម្នាក់ៗមានភាពស្មោះត្រង់ទាំងចំពោះព្រះអង្គ និង ចំពោះខ្លួនឯងដែរ។

យើងទាំងអស់គ្នាត្រូវជាប់មានទោសក៏ព្រោះតែអំពើបាបនៃការបោកបញ្ឆោតនេះដែរ។ ការប្រព្រឹត្តរបស់ពួកយើងម្នាក់អាចថាខុសពីការប្រព្រឹត្តរបស់លោក យ៉ាកុប និង រេបេកា ប៉ុន្តែ ការបោកបញ្ឆោត គឺនៅតែជាការបោកបញ្ឆោត ទោះបីជាស្ថិតក្នុងទម្រង់ ឬរូបភាពបែបណាក៏ដោយ។ ព្រះយេស៊ូវ ទ្រង់បានយាងមក គឺដើម្បីដោះយើងរាល់គ្នាឲ្យមានសេរីភាព រួចផុតពីអំពើបោកបញ្ឆោតទាំងអស់នេះ ដូចជា ការចិត្តឆបោក ខ្លួនឯង ការបោកបញ្ឆោតពីសំណាក់ពពួកវិញ្ញាណអាក្រក់ជាដើម។ នៅលើសកលលោកសម័យសព្វថ្ងៃនេះ គឺមានពោរពេញទៅដោយការឃោសនា បង្កើតនូវភាពទាក់ទាញនានា ជួនកាលអ្នកដែលបោកបញ្ឆោតយើងអាចជាមិត្តភ័ក្រ សមាជិកក្រុមគ្រួសាររបស់យើងផ្ទាល់ក៏មានដែរ។ គឺមានតែអង្គព្រះយេស៊ូវមួយប៉ុណ្ណោះដែលគ្មានការបោកបញ្ឆោតទាល់តែសោះ។ ដំណឹងល្អនោះគឺថា ទ្រង់បានយកឈ្នះការនេះដោយសារទ្រង់ស៊ូលះបង់ព្រះជន្មទ្រង់ផ្ទាល់ ហេតុដូចនេះហើយ ទើបបានជាក្នុងពេលឥឡូវនេះយើងបានចម្រើនឡើងដោយសារទ្រង់ប្រទានឲ្យដោយឥតគិតថ្លៃដល់អស់អ្នកណាដែលបានបោះជំហានដើរតាមទ្រង់ ហើយទ្រង់នឹងលុបបំបាត់រាល់ការបោកបញ្ឆោតនានា ដែលងាយនឹងបឺតជញ្ជក់ ស្រូបយកយើងឲ្យធ្លាក់ទៅក្នុងអន្ទាក់នៃអំពើអាក្រក់ផ្សេងៗ។ ចូរព្រះគុណនៃសេចក្ដីពិត និង សេចក្ដីមេត្តាករុណារបស់ទ្រង់ បានរំដោះយើងឲ្យបានរស់នៅជាកូនស្ងួនភ្ងា ព្រមទាំងបានទទួលគ្រងមរតកនៃនរគស្ថានសួគ៌ជាមួយនឹងទ្រង់ផងចុះ។

## មេរៀនទី ៣ - ផ្នែកទី ២

## លំហាត់:

យ៉ាកុបបានទទួលព្រះពរួចហើយ គាត់ក៏បានចាក់ចេញពីវត្តមានរបស់ឪពុកគាត់! បន្តិចក្រោយមក អេសាវបានវិលត្រឡប់មកដល់ផ្ទះវិញ។

- នៅក្នុងខ ៣១ តើអេសាវបានធ្វើអ្វី? ______________________________
  ______________________________
- តើអ៊ីសាក់បានសួរដូចម្ដេច? ______________________________
  ______________________________
- តើអេសាវបានឆ្លើយតបវិញយ៉ាងដូចម្ដេច? ______________________________
  ______________________________
- អំពើឆបោករបស់យ៉ាកុបត្រូវបានលាតត្រដាង! ចូរសម្គាល់មើល នូវប្រតិកម្មប្រកបដោយអារម្មណ៍ហឹង្សារបស់ពួកគេ។
  - នៅក្នុងខ ៣៣ ប្រតិកម្មរបស់អ៊ីសាក់ ______________________________
    ______________________________

o នៅក្នុងខ៣៤ ប្រតិកម្មរបស់អេសាវ ________________________________________

________________________________________

________________________________________

- ពួកគេទាំងពីរនាក់សុទ្ធតែត្រូវបានគេបោកបញ្ឆោត! ពួកគេមិននឹងស្មានថាយ៉ាកុបហ៊ានធ្វើដូច្នេះទេ! នៅក្នុងខ ៣៦ តើអេសាវបាននិយាយអំពីយ៉ាកុបដូចម្តេចខ្លះ? ________________________________________

________________________________________

________________________________________

- នៅក្នុងខ ៣៦ អេសាវបានសុំអង្វរឪពុករបស់គាត់ឲ្យប្រទានពរដល់គាត់ដែរ "សូមប្រទានពរដល់ខ្ញុំដែរមកលោកឪពុក" "តើលោកឪពុកមិនបានទុកព្រះពរណាខ្លះសម្រាប់ខ្ញុំទេឬអី?" នៅក្នុងខ ៣៧ អ៊ីសាក់បានប្រាប់អេសាវថា គាតប់ប្រទានពរដល់យ៉ាកុបអស់ទៅហើយ ហើយគាត់សួរថា " តើឲ្យឪពុកអាចប្រទានអ្វីទៀតដល់ឯងកូនប្រុសពុក?" ឪពុកអីក៏ខ្វះខ្វាយផ្តេសផ្តាស់យ៉ាងនេះ! នៅក្នុងខ ៣៨ តើអេសាវបានសួរដូចម្តេចទៅឪពុករបស់គាត់? ________________________________________

________________________________________

________________________________________

________________________________________

- ដូច្នេះ អ៊ីសាក់ក៏ប្រទានពរដល់អេសាវជាកូនដែរ។ នៅក្នុងខ ៣៩-៤០ តើអ៊ីសាក់បាននិយាយដូចម្តេចខ្លះ? ________________________________________

________________________________________

________________________________________

________________________________________

តើនេះលោកអ្នកគិតថាគឺជាការប្រទានពរដែរឬទេ? ចូរប្រៀបធៀបពាក្យសម្តីរបស់អ៊ីសាក់កាលគាត់និយាយឲ្យពរដល់យ៉ាកុប និង ពាក្យសម្តីដែលគាត់និយាយក្នុងពេលឲ្យពរដល់អេសាវ ____

________________________________________

________________________________________

________________________________________

________________________________________

## គំនិតឆ្លុះបញ្ចាំង៖

យើងជិតឈានមកដល់ការបញ្ចប់សាច់រឿងហើយ! មានរឿងផ្សេងជាច្រើនទៀតចូលមកដល់ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ព្រះពរត្រូវបានប្រគល់ឲ្យរួចហើយដែរ ហើយយើងឃើញថា អំពើបោកបញ្ឆោតនៅតែជាប់ក្នុងគ្រួសារមួយនេះដដែល! នៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ រេបេកា ថា អ្នកចាស់ជាង នឹងត្រូវបម្រើដល់អ្នកដែលក្មេងជាងវិញ តើទ្រង់មានការនៅក្នុងព្រះតម្រិះរបស់ទ្រង់ឬទេ? បើសិនជា យ៉ាកុប និង រេបេកា មិនបានលោភលន់ប្រព្រឹត្តរឿងទាំងអស់នេះទេ ដូច្នេះធ្វើដូចម្តេចនឹងបានសាច់រឿងមានការកែប្រែទៅបាន?

ម្នាក់មិនអាចជួយអ្វីកើត បានត្រឹមតែមានអារម្មណ៍ស្តាយក្រោយចំពោះប្រត្តិកម្មរបស់ឪពុក ហើយម្នាក់ទៀតបានត្រឹមតែនឹកឆ្ងល់ថា ភ្លាមៗនោះស្រាប់តែអេសាវ ទាមទារចង់បានព្រះពរពីឪពុកដែរ បើគាត់មិនបានឲ្យតម្លៃដល់សិទ្ធិជាកូនច្បង ហើយថែមទាំងមិនដើរតាមផ្លូវរបស់គាត់ផងដូច្នេះ។ តើព្រះពរសម្រាប់គាត់មានន័យដូចម្តេច? តើត្រូវរស់ក្នុងជីវិតមួយដោយគ្មានព្រះពរយ៉ាងដូចម្តេច?

តើព្រះវរបិតាដែលគង់នៅនរគស្ថានសួគ៌ ទ្រង់ប្រទានពរសម្រាប់យើង ជាមនុស្សដែលមានលក្ខណៈដូចទ្រង់ហើយ មានបំណងព្រះហឫទ័យចង់ផ្សះផ្សារទំនាក់ទំនងប្រកដោយសេចក្តីស្រលាញ់ជាមួយនឹងទ្រង់វិញជាយ៉ាងដែរ?

អេសាវមានចិត្តត្រេកត្រអាលចង់បានព្រះពរពីឪពុករបស់គាត់ណាស់! ចុះតើយើងរាល់គាត់មានចិត្តស្រេកឃ្លានចង់បានព្រះពរព្រះវរបិតាដែលគង់នៅនរគស្ថានសួគ៌ ដូចជាអេសាវស្រេកឃ្លានចង់បានព្រះពរពីឪពុករបស់គាត់ដែរឬទេ?

តើយើងនឹងបង្ហាញដួងចិត្តស្រេកឃ្លានចង់បានព្រះពរព្រះវរបិតា ដែលគង់ទ្រង់នៅនរគស្ថានសួគ៌របស់យើងសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃយ៉ាងដូចម្តេច?

ចូរចំណាយពេលវេលាខ្លះដើម្បីកត់ត្រានូវគំនិតរបស់លោកអ្នកចូលក្នុងសៀវភៅ។ ចូរចងចាំថា មិនគ្រប់ចម្ងល់ទាំងអស់សុទ្ធតែមានចម្លើយនោះទេ ប៉ុន្តែចម្លើយទៅនឹងសំនួររបស់យើងគឺស្ថិតនៅលើព្រះតម្រិះរបស់ព្រះជាម្ចាស់ជាអ្នកសម្រេចឲ្យ។

## មេរៀនទី ៣ - ផ្នែកទី ៣

## ការទន្ទេញចងចាំៈ

មានបទគម្ពីរមួយដែលសំខាន់ជាងគេបំផុតសម្រាប់មេរៀននេះគឺ ១ យ៉ូហាន ១:៨-៩។ ខគម្ពីរយោងនៃបទគម្ពីរត្រូវបានដឹងម្តងរួចមកហើយកាលនៅខាងដើមនៃមេរៀន ប៉ុន្តែជាថ្មីម្តងទៀត សូមលើកទឹកចិត្តលោកអ្នកឲ្យកត់ត្រាបទគម្ពីរនេះទុកក្នុងសៀវភៅរបស់លោកអ្នក ហើយរីករាយក្នុងការទន្ទេចឲ្យបានចាំមាត់នូវសេចក្តីពិតនេះទាំងអស់គ្នា។ សូមឲ្យព្រះបន្ទូលដ៏រស់នេះ ប្រទានពរដល់លោកអ្នកបានលន់តួបាបគ្រប់ៗគ្នា និង មានសេចក្តីអំណរតាមរយៈសេចក្តីពិតនៃព្រះបន្ទូលទ្រង់នេះ ដោយការទទួលស្គាល់ថាព្រះជាម្ចាស់ មានភាពស្មោះត្រង់ និង យុត្តិធម៌ ព្រមទាំងមានព្រះហឫទ័យក្នុងការអត់ទោសបាបដល់យើងគ្រប់ៗគ្នាឲ្យបានជាបរិសុទ្ធ សុចរិតនៅចំពោះព្រះភ័ក្រទ្រង់ដោយសារព្រះបុត្រារបស់ព្រះអង្គគឺអង្គព្រះយេស៊ូវ។

## ការអនុវត្តន៍ផ្ទាល់ខ្លួនៈ

ការលុបបំបាត់អំពើបោកបញ្ឆោតទាំងឡាយដែលនៅជុំវិញយើង ទំនាក់ទំនងនៅក្នុងក្រុមគ្រួសារត្រូវជួបនឹងឧបសគ្គ មានការវិវាទនៅក្នុងការធ្វើមុខជំនួញ កេរ្តិ៍ កិត្តិយសក្នុងជួរនយោបានត្រូវរងការអាម៉ាស់ តើអាចនឹងមានផលប៉ះផលបែបណាខ្លះដែលលោកអ្នកត្រូវដោះស្រាយ បើសិនដោយសារលោកអ្នកគឺជាអ្នក បោកបញ្ឆោត ឬលោកអ្នកត្រូវបានគេបោកបញ្ឆោតវិញ? ______________________________

______________________________________________________________

______________________________________________________________

តើវាគឺជាការបោកបញ្ឆោតដូចម្តេច? ______________________________

______________________________________________________________

______________________________________________________________

តើវាគឺជាការបោកបញ្ឆោតដូចម្តេចដែលបង្ករឲ្យទំនាក់ទំនងរបស់លោកអ្នកត្រូវបាក់បែក? __________

______________________________________________________________

______________________________________________________________

តើទោសកំហុសបែបណាខ្លះដែលត្រូវតែសារភាព? តើទង្វើបែបណាដែលត្រូវលើកឡើងក្នុងការអត់ទោសឲ្យ? ______________________________

______________________________________________________________

______________________________________________________________

ព្រះជាម្ចាស់បានលើកទឹកចិត្តយើងម្នាក់ៗឲ្យចូលទៅចំពោះព្រះភ័ក្រទ្រង់ដើម្បីធ្វើការលន់តួបាប និង សារភាពចំពោះទោសកំហុសទាំងឡាយដែលយើងបានប្រព្រឹត្តខុសចំពោះទ្រង់កន្លងមក ទ្រង់សព្វព្រះហឫទ័យចង់ឲ្យជីវិតយើងរាល់គ្នាមានចំណែកនៅក្នុងសេចក្ដីពិត គឺជាសេចក្ដីពិតដែលនាំមកនូវការលន់តួបាប និង ការសារភាពទោសកំហុសគ្រប់យ៉ាងចំពោះទ្រង់ ហើយទទួលមកវិញនូវសេចក្ដីស្រលាញ់ និង ការអត់ទោសបាប។

## សេចក្ដីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ទូលបង្គំត្រូវតែសារភាពចំពោះទ្រង់នូវអំពើបោកបញ្ឆោតទាំងឡាយដែលមាននៅក្នុងចិត្តរបស់ទូលបង្គំ វាគឺជាស្ថានភាពមួយដ៏អាក្រក់ដែលមិនអាចព្យាបាលជា។ ទូលបង្គំបានបោកបញ្ឆោតដោយការនិយាយកុហក់ ដែលចេញមកពីក្នុងចិត្តទូលបង្គំផ្ទាល់ ដោយហេតុទូលបង្គំជាមនុស្សមានបាបជាប់តាំងពីកំណើតមក។ ប៉ុន្តែ ព្រះអង្គមានពេញដោយសេចក្ដីពិត ហើយព្រះបន្ទូលរបស់ទ្រង់គឺជាសេចក្ដីពិត! សូមទ្រង់មេត្តាប្រាប់ដល់ទូលបង្គំ ដោយការលន់តួបាបចំពោះទ្រង់ ដើម្បីឲ្យអំពើបាបរបស់ទូលបង្គំបានជម្រះជ្រះ ព្រះអង្គមានពេញទៅដោយភាពស្មោះត្រង់ យុត្តិធម៌ និង មានព្រះហឫទ័យសុចរិតក្នុងការអត់ទោសបាបសម្រាប់ទូលបង្គំ។ ទូលបង្គំសូមចូលមកចំពោះព្រះភ័ក្រទ្រង់ក្នុងពេលនេះ ព្រោះទូលបង្គំជឿថាព្រះបុត្រារបស់ទ្រង់គឺព្រះយេស៊ូវ អាចព្យាបាលដល់ទូលបង្គំបាន។ សូមទូលបង្គំបានដើរក្នុងផ្លូវរបស់ទ្រង់ផង។ ____

________________________________________________

________________________________________________

________________________________________________

# មេរៀនទី ៣ - ផ្នែកទី ៤

## សេចក្ដីណែនាំៈ

យ៉ាកុបបានបោកបញ្ឆោតឪពុក និង បងប្រុសរបស់គាត់ដើម្បីបានទទួលព្រះពរ ហើយមានចេតនាធ្វើជាកូនប្រុសច្បងនៅក្នុងគ្រួសារទៀតផង។ អេសាវត្រូវបានទទួលរងការខាតបង់ ក្រោយពីបានដឹងថា យ៉ាកុបបានទទួលព្រះមុនគាត់ រួចគាត់ក៏សុំឲ្យឪពុកប្រទានពរដល់គាត់ដែរ។ ប៉ុន្តែ ព្រះពរគ្រប់យ៉ាងត្រូវបានប្រគល់ឲ្យទៅយ៉ាកុបអស់ទៅហើយ។ ព្រះពរនោះក៏ "ចូរឲ្យបានផ្គត់ផ្គង់ដល់ការទ្រទ្រង់នឹងដើមទំពាំងបាយជូរថ្មី"។ នៅក្នុងមេរៀនទី ៣ ផ្នែកទី ៤ សាច់រឿងត្រូវបានបន្តទៅមុខទៀត គឺអេសាវ មានចិត្តចងគំនុំ ដោយមិនបានទទួលព្រះពរពីឪពុករបស់ខ្លួនក្នុងនាមគាត់គឺជាកូនប្រុសច្បងក្នុងគ្រួសារ។

## កិច្ចការ:

ចូរអានព្រះគម្ពីរលោកុប្បត្តិ ២៧:៤១ បន្តរហូតដក់ លោកុប្បត្តិ ២៨:៩

## សេចក្តីបង្រៀន:

នៅក្នុងផ្នែកទី ៣ យើងបានសិក្សាខ្លះៗអំពីព្យាការី យេរេមា ដែលបានបង្រៀនយើងថា "ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន"។ (យេរេមា ១៧:៩) រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលសួរទៅស្ត្រីថា ឯងបានធ្វើអ្វីដូច្នេះ នាងទូលឆ្លើយថា ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទាន។ (លោកុប្បត្តិ ៣:១៣) អំពើរបោកបញ្ឆោតត្រូវបានសម្តែងចេញនៅក្នុងចិត្តដែលពេញដោយអំពើបាប។ ការបោកបញ្ឆោតនេះវារំលឹកយើងទាំងអស់គ្នាថាព្រះជាម្ចាស់នឹងបំផ្លាញយើងគ្រប់គ្នាដោយព្រោះអំពើបាបរបស់យើង។ យើងមិនអាចធ្វើការឆ្លុះបញ្ចាំងអំពីបំណងព្រះហឫទ័យទ្រង់ក្នុងការបង្កបង្កើតនោះឡើយ។

**លំហាត់:** អេសាវមិនបានទុកឲ្យរឿងរ៉ាវគ្រប់យ៉ាងនៅស្ងាត់ស្ងៀមនោះឡើយ! សាច់ត្រូវបានបន្ថែមទៀតនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៧:៤១។

- ដោយយោងទៅតាមខ ៤១ តើអេសាវនឹងមានគំនិតធ្វើអ្វី? ____________________

  ____________________

  ____________________

- តើមានអ្វីជាឫសគល់ធ្វើឲ្យអេសាវត្រូវស្តាមុខមាត់ឡើងវិញ? ហេតុអ្វីបានគាត់ត្រូវធ្វើដូច្នេះ? ____

  ____________________

  ____________________

- តើមានគម្រោងការនឹងធ្វើអ្វី? ____________________

  ____________________

  មកដល់ត្រង់ចំណុចនេះធ្វើឲ្យយើងនឹកឃើញទៅដល់រឿងបងប្អូនប្រុសពីរនាក់ គឺកាអ៊ីន ដែលមានបំណងចង់សម្លាប់អេបិលជាប្អូនប្រុសរបស់ខ្លួន។ (លោកុប្បត្តិ ៤:៨)

- ការចង់គំនុំ គឺជាការបំពេញចិត្តខាងអំពើបាប និង អំពើអាក្រក់នានាគឺអាចនាំទៅដល់ការសម្លាប់គ្នាបាន។ តាមរយៈព្រះគម្ពីរអេភេសូរ ៤:២៦ តើសាវ័ក ប៉ូលបានបង្រៀនយើងយ៉ាងដូចម្តេចខ្លះ? ____

  ____________________

  ____________________

  ហេតុអ្វីមិនបាន? ចូរខឹងចុះ តែកុំឲ្យធ្វើបាបឡើយ កុំឲ្យសេចក្តីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ ក៏កុំឲ្យអារក្សមានឱកាសឲ្យសោះ (អេភេសូរ ៤:២៦-២៧)

- នៅពេលដែល រេបេកា បានទទួលដំណឹងអំពីផែនការណ៍របស់អេសាវហើយ នោះនាងក៏ប្រញ៉ាប់ប្រញ៉ាល់ផ្តល់ដំណឹងនោះទៅយ៉ាកុបភ្លាម។ នៅក្នុងខ ៤២ តើនាងបានប្រាប់យ៉ាកុបដូចម្តេច? ___

______________________________________________

អេសាវបានគិតបែបនេះ ពេលនោះគាត់មានផែនការមួយ គឺត្រូវរងចាំដល់ឪពុកគាត់ស្លាប់សិន។

- នៅក្នុងខ ៤៣ សម្រាប់លើកទី ៣ នៅក្នុងជំពូក ២៧ តើរេបេកាប្រាប់ឲ្យយ៉ាកុបធ្វើអ្វី? _______

______________________________________________

______________________________________________

ចូររកឲ្យនូវខយោង និង ការកំណត់សម្គាល់ពីរកន្លែងដែលនិយាយអំពីពួកគេ។

____________________ និង ____________________

- ការណែនាំរបស់រេបេកាគឺ "គ្រាន់តែធ្វើតាមអ្វីដែលម៉ែប្រាប់ទៅ" តើមានគំនិតបែបណាដែលស្តែងអំពីចរិតលក្ខណៈរបស់នាង? ______________________________

______________________________________________

ទំនាក់ទំនងរបស់គាត់ជាមួយនឹងយ៉ាកុប? ______________________________

______________________________________________

- ដោយយោងតាមខ ៤៣-៤៥ តើរេបេកាមានគម្រោងការណ៍ដូចម្តេច? ________________

______________________________________________

______________________________________________

______________________________________________

______________________________________________

- នៅក្នុងខ ៤៦ តើមានហេតុអ្វីខ្លះដែលធ្វើរេបេកា បង្គាប់ឲ្យយ៉ាកុបចេញដំណើរយ៉ាងប្រញ៉ាប់ប្រញ៉ាល់ម្លេះ? តាមរយៈលោកុប្បត្តិ ២៦:៣៤-៣៥ ចូរឲ្យគំនិតខ្លះ ________________

______________________________________________

______________________________________________

- នៅក្នុងលោកុប្បត្តិ ២៨:១-២ អ៊ីសាក់បានជ្រាបអំពីផែនការណ៍របស់រេបេកាភ្លាម ក៏បញ្ជូនយ៉ាកុបឲ្យទៅកាន់ផ្ទះឪពុករបស់នាង ជាហេតុនាំឲ្យយ៉ាកុបយកប្រពន្ធដោយខ្លួនឯង។ ចូររំលឹកឡើងវិញអំពោះឪពុករបស់អ៊ីសាក់ គឺលោក អប្រាហាំបានចាត់អ្នកបម្រើរបស់គាត់ឲ្យរកញាតិសណ្តានរបស់គាត់នៅតំបន់ ហារ៉ាន ឬ ប៉ាដាន់ អើរ៉ាម ដើម្បីទទួលយកនារីម្នាក់ឲ្យធ្វើជាប្រពន្ធរបស់អ៊ីសាក់។

តើ គាត់បានណែនាំដូចម្ដេចដល់យ៉ាកុប? ____________________

____________________

____________________

- តើអ៊ីសាក់បានប្រទានពរដល់យ៉ាកុបដូចម្ដេចខ្លះមុនពេលគាត់បញ្ជូនឲ្យទៅ (លោកុប្បត្តិ ២៨:៣-៤)

____________________

____________________

- តើមានពាក្យណាខ្លះដែលស្រដៀងនឹងព្រះបន្ទូលដែលព្រះជាម្ចាស់ប្រាប់ទៅជីតារបស់គាត់ គឺលោក អប្រាហាំ និង ឪពុករបស់គាត់គឺ អ៊ីសាក់? ____________________

____________________

____________________

- នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៨:៥ យ៉ាកុបធ្វើដំណើរតាមផ្លូវជាមួយឪពុកមារបស់គាត់ ____________________ ដែលជា ____________________ បងប្រុសរបស់គាត់។ ឪពុករបស់ពួកគេគឺជា ____________________។ ជាថ្មីម្ដងទៀតដែលយើងមើលអំពីសារៈសំខាន់នៃពូជពង្សខ្សែរលោហិតនៃព្រះយេស៊ូវ គឺជាសម្ព័ន្ធមេត្រីដែលបានចងឡើងជាមួយនឹងលោក អប្រាហាំ និង ពូជពង្សគ្រប់ជំនាន់ក្រោយៗរបស់គាត់។

## មេរៀនទី ៣ - ផ្នែកទី ៥

## ចូលឱ្យកាន់តែជ្រៅ:

- ខណៈពេលដែលយ៉ាកុបទៅនៅផ្ទះឡាបាន់ ឪពុកមារបស់គាត់ តើយើងបានសិក្សាអ្វីខ្លះអំពីអេសាវ? (នៅក្នុងខ ៦-៩) ____________________

____________________

____________________

____________________

តើសកម្មភាពរបស់អេសាវប្រាប់យើងយ៉ាងដូចម្ដេច? តើមានអ្វីកើតឡើងចំពោះគាត់? ____________________

____________________

____________________

- ចូររំលឹងសារឡើងវិញថាតើ អ៊ីស្មាអែលគឺជានរណា? អ៊ីស្មាអែល គឺជាឪពុកមារបស់អេសាវ ដែលមានឪពុកតែមួយម្ដាយផ្សេងគ្នាជាមួយនឹងអ៊ីសាក។ (អ៊ីស្មាអែលជាកូនប្រុសរបស់នាងហាហ្គា)។

តើឪពុករបស់គាត់សប្បាយចិត្តក្នុងការដែលគាត់ទៅឯងគ្រួសាររបស់អ៊ីស្មាអែល យើងរៀបការប្រពន្ធម្នាក់ទៀតនោះ? ក្រោយអ្វីៗបានកន្លងផុតទៅ យ៉ាកុបបានធ្វើដំណើរទៅរកបងប្រុស និង ម្តាយរបស់គាត់វិញ។ តើមានកំហុសអ្វីក្នុងការដែលអេសាវទៅឯងគ្រួសាររបស់អ៊ីស្មាអែល? ចូររំលឹកឡើងវិញថាតើទេវត្តានៃព្រះអម្ចាស់បានប្រាប់នាង ហាហ្គាដូចម្តេចខ្លះអំពីអ៊ីស្មាអែល បើតាមព្រះគម្ពីរលោកុប្បត្តិ ១៥:១១-១២ និង លោកុប្បត្តិ ២៥:១៨។

## សំនួរឆ្លុះបញ្ចាំង

សាច់រឿងប្រហែលជាត្រូវផ្លាស់ប្តូរគ្នាបន្តិច! ប៉ុន្តែមុននឹងយើងតាមដានអំពីដើររបស់យ៉ាកុបទៅ ហារ៉ានយើងត្រូវតែចំណាយពេលខ្លះដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីអារម្មណ៍ និង អកប្បកិរិយារបស់យើងផ្ទាល់ចំពោះអ្វីដែលបានកើតឡើងនាពេលកន្លងមកបន្តិចសិន។ នៅក្នុងគ្រួសារត្រូវបានបែកខ្ញែកគ្នា! កូនប្រុសពីរនាក់ម្នាក់ជាទីពេញចិត្តរបស់ឪពុក ហើយម្នាក់ទៀតជាពេញចិត្តរបស់ម្តាយ។ ប៉ុន្តែឪពុកមានអោបជាប់នូវព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់បន្តមកពីឪពុករបស់គាត់ទៀតគឺលោក អប្រាហាំ។ កាលដែលកូនប្រុសទាំងពីរនៅក្នុងផ្ទៃពោះម្តាយនៅឡើយ ព្រះជាម្ចាស់បានព្រះបន្ទូលប្រាប់រេបេកាថា កូនប្រុសទាំងពីរនឹងត្រូវបែកគ្នា ហើយកូនបង និង ត្រូវបម្រើដល់កូនប្អូន ហើយនៅទីបំផុតអ្វីៗគ្រប់យ៉ាងត្រូវបានកើតឡើយយ៉ាងដូច្នោះប្រាកដមែន។

យ៉ាកុបបានទទួលទាំងសិទ្ធិជាកូនច្បង ទាំងព្រះពរកូនប្រុសច្បង! បើតាមត្រូវទាំងពីរនេះគឺជាកម្មសិទ្ធិរបស់អេសាវទេ ប៉ុន្តែ អេសាវខ្លួនឯងមិនបានឲ្យតម្លៃចំពោះរឿងទាំងពីរនេះ ជាពិសេសទៀតនោះគឺគាត់មិនឲ្យតម្លៃចំពោះប្អូនប្រុស និង ឪពុករបស់គាត់ដែរ។ ដូច្នេះហើយ ទើបបានជាសព្វថ្ងៃនេះ យើងតែងតែបានរឿងស្រដៀងគ្នានេះកើតឡើងជាញឹកញយ។ មិនថាជាមានរឿងអ្វីក៏ដោយ បើបបងប្អូនមិននិយាយរកទៅវិញទៅមកទេ នោះពួកគេនឹងចម្រើនវ័យឡើងហាក់ដូចជាដាច់ដោយឡែកពីគ្នា។ បើកាលណាបងប្រុសមានការអាក់អន់ចិត្ត ឬ ចង់បានមុខមាត់ ដូច្នេះទំនាក់ទំនងនឹងត្រូវបែកបាក់ជាមួយគ្នានោះសេចក្តីស្រលាញ់ក៏ត្រូវបានបាត់បង់ដែរ។

តើអនាគតគ្រួសារមួយនេះនឹងត្រូវប្រឈមមុខនឹងបញ្ហាអ្វីខ្លះ? តើការរស់នៅក្រោមសម្ព័ន្ធមេត្រីនៃសេចក្តីសន្យាត្រូវប្រឈមមុខនឹងបញ្ហាដែរឬទេ? អ៊ីសាក់គឺជាមនុស្សតែម្នាក់ដែលត្រូវបានទទួលគ្រងសេចក្តីសន្យានេះ។ គាត់មានកូនប្រុសតែពីរនាក់ ហើយក្នុងពេលនេះពួកគេទាំងពីរបានធ្វើឲ្យអ្វីៗក្រឡាប់ចាក់ខុសពីការដែលគាត់បានគ្រោងទុក! កូនប្រុសប្អូនត្រូវរត់គេចខ្លួនព្រោះខ្លាចបងប្រុសសម្លាប់។ ពេលស្ថិតក្នុងស្ថានភាពដ៏ច្របូកច្របល់បែបនេះ តើព្រះជាម្ចាស់គង់នៅឯណា? តើទ្រង់បានបោះបង់ចោលគ្រួសារមួយនេះមែនទេ? តើទ្រង់ផ្លាស់ប្តូរព្រះហឫទ័យអំពីសម្ព័ន្ធមេត្រីដែលទ្រង់បានចងឡើងជាមួយលោក អប្រាហាំ និង ពូជពង្ស

ក្មួនចៅរបស់គាត់ហើយមែនទេ? រឿងរ៉ាវទាំងអស់នេះបានកើតឡើងក៏ព្រោះតែមានអំពោះបោកបញ្ឆោតនៅក្នុងគ្រួសារមួយនេះដែរ ដែលជាបុព្វហេតុនាំឲ្យមានការប៉ះពាល់ដល់ផែនការរបស់ព្រះជាម្ចាស់ទាំងមូល។

សំនួរឆ្លុះបញ្ចាំងជួនកាលមិនចាំបាច់មានចម្លើយក៏បានដែរ ប៉ុន្តែជាការធ្វើឲ្យយើងគិតពិចារណានូវអ្វីៗដែលអាចនឹងកើតមានឡើង ឬធ្វើឲ្យយើងនឹងស្រមៃទៅដល់អ្វីដែលអាចនឹងកើតមានប្រហាក់ប្រហែលនឹងជីវិតនរណាម្នាក់។ សំនួរឆ្លុះបញ្ចាំង នាំឲ្យយើងចោទសួរនូវបញ្ហាលំបាកៗមួយចំនួន ដូចជាសួរថា ស្ថិតក្នុងស្ថានភាពបែបនេះតើព្រះជាម្ចាស់ទ្រង់គង់នៅឯណា? តើទ្រង់មានព្រះរាជតម្រិះដូចម្តេច? តើព្រះអង្គនឹងគួរធ្វើដូចម្តេច? តើទ្រង់នឹងមិនរវល់ទេឬមួយយ៉ាងណា? តើព្រះអង្គសព្វព្រះហឫទ័យទតមើលគ្រួសារមួយដែលមានបងប្អូនប្រុសពីរនាក់រកកាប់សម្លាប់គ្នាបែបនេះឬ? តើទ្រង់ជាអ្នកអនុញ្ញាតិ្តឲ្យអំពើបោកបញ្ឆោតទាំងអស់នេះកើតឡើងមែនទេ? បើទំនាក់ទំនងត្រូវបានបាក់បែបដូច្នេះ តើទ្រង់អាចសម្រេចតាមគោលបំណងរបស់ទ្រង់ដែរឬទេ?

នៅពេលដែលលោកអ្នកធ្វើការឆ្លុះបញ្ចាំងអំពីសាច់រឿងមកដល់ត្រង់ចំណុចនេះ តើលោកអ្នកមានគំនិត ដូចម្តេច់? តើលោកអ្នកនឹងមានសំនួរលំបាកបែបណាខ្លះដែលចង់ចោទសួរ? ______________________

______________________________________________

______________________________________________

## សេចក្តីអធិស្ឋាន:

ឱព្រះអម្ចាស់អើយ! ទូលបង្គំបានចាប់ផ្តើមមានអារម្មណ៍ថាដូចជាគ្មានសេចក្តីសុខទាល់តែសោះ! កាលណាទូលបង្គំកាន់តែរៀនអំពីបញ្ហានៅក្នុងគ្រួសាររបស់អ៊ីសាក់ ទូលបង្គំកាន់តែរកឃើញថាទូលបង្គំមានបញ្ហាទាំងអស់នេះដែរ។ មានបញ្ហាលំបាកដោះស្រាយជាច្រើននៅក្នុងគ្រួសាររបស់ទូលបង្គំ។ របៀបដែលម្នាក់ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក គឺមានតែធ្វើមានរបួសស្នាម ហើយគឺជារបួសហាក់គ្មានវិធីព្យាបាលបាន។ ទូលបង្គំសូមព្រះអង្គបានព្យាបាលទំនាក់ទំនងដែលបាក់បែកនេះផង! សូមបង្ហូរសេចក្តីស្រលាញ់របស់ទ្រង់មកលាងសម្អាតភាពឈឺចាប់ គ្រាំគ្រារបស់ទូលបង្គំផង! យើងខ្ញុំត្រូវការព្រះហស្តនៃសេចក្តីសុខសាន្តរបស់ទ្រង់ មកផ្សះផ្សារពួកយើងឲ្យមានពេញទៅដោយសេចក្តីអំណរក្នុងជីវិតរស់នៅ។ ទូលបង្គំសូមលើកទូលថ្វាយដល់ទ្រង់នូវបញ្ហាទាំងឡាយដែលមានក្នុងចិត្តទូលបង្គំក្នុងពេលនេះ គឺ ______________________

______________________________________________

______________________________________________

______________________________________________

# មេរៀនទី ៤

## មេរៀនទី ៤ - ផ្នែកទី ១

## សេចក្តីបង្រៀនៈ

ពាក្យថា "បុព្វបុរស" ពាក្យនេះប្រហែលជាលោកអ្នកធ្លាប់បានឮពីមុនមកជាមិនខាន! នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានបុព្វបុរសបីនាក់ដែលលេចធ្លោជាងគេ គឺ លោក អប្រាហាំ អ៊ីសាក់ យ៉ាកុប។ ពាក្យ "បុព្វបុរស" មកពីភាសាឡាតាំង "Patri" ឬ ឪពុក។ មនុស្សទាំងនេះ ត្រូវបានគេចាត់ទុកថាគឺជាពួកព្ធយុកោរបស់ប្រជាជនថ្វីហ្វនេះ ជាតិសាសន៍ហេព្រើរ។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៨:១០-២២ យើងរៀនអំពីព្រះជាម្ចាស់ជ្រើសរើសយ៉ាកុបដើម្បីគ្រងសម្ព័ន្ធមេត្រីនៃសេចក្តីសន្យាដ៏នៅអស់កល្បជានិច្ច។

## លំហាត់ៈ

ចូរយើងបន្តសាច់រឿងដោយរួមដំណើរជាមួយនឹងយ៉ាកុប! ឯយ៉ាកុប គាត់ចេញពីបៀរ-សេបា ទៅឯខារ៉ាន (លោកុប្បត្តិ ២៨:១០) នៅជាមួយនឹងឪពុកមារបស់គាត់គឺលោក ឡាបាន់។

- នៅក្នុងខ ១១ តើគាត់នៅឯណា? តើគាត់ធ្វើអ្វី? ________________________________

  ________________________________________________

- ចូរបរិយាយអំពីការយល់សព្វរបស់គាត់ នៅក្នុងខ ១២ ____________________________

  ________________________________________________

  ________________________________________________

  - ដោយយោងទៅតាមខ ១៣ តើនៅនរណានៅកំពូលខ្ពស់ជាងគេ? ________________

    ________________________________________________

  - តើទ្រង់មានព្រះបន្ទូលថាទ្រង់គឺជានរណា? ________________________

    ________________________________________________

  - តើទ្រង់មានព្រះបន្ទូលថាទ្រង់នឹងប្រទានអ្វីឲ្យ? ____________________

    ________________________________________________

  - នៅក្នុងខ ១៤ តើព្រះជាម្ចាស់បានសន្យាដូចម្តេចចំពោះកូនចៅ និង ពូជពង្សរបស់យ៉ាកុប? ___

    ________________________________________________

    ________________________________________________

    ________________________________________________

- o នៅក្នុងខ ១៥ តើទ្រង់បានសន្យាយ៉ាងដូចម្ដេច?
  - ▪ យើងនឹងធ្វើជា ______________________________________________
  - ▪ ហើយនឹង _________________________________________________
  - ▪ តើនឹងមិន _________________________________________________
- ជាថ្មីម្ដងទៀតរំលឹកដល់សេចក្ដីសន្យាអំពីទឹកដី និង អំពីកូនចៅ! សេចក្ដីសន្យាសម្រាប់លោកអប្រាហាំ និង អ៊ីសាក់ ក៏បន្តមកដល់ យ៉ាកុបទៀតគឺជាសេចក្ដីសន្យាដដែលនោះឯង។ គាត់ក៏បានភ្ញាក់ខ្លួន បានដឹងអំពីវត្តមានរបស់ព្រះជាម្ចាស់។ នៅក្នុងខ ១៧ តើគាត់មានប្រតិកម្មយ៉ាងដូចម្ដេច?

  ____________________________________________________________

  ____________________________________________________________

  តើគាត់និយាយដូចម្ដេច? ____________________________________________

  ____________________________________________________________

- តាមការជាក់ស្ដែង បើតាមខ ១៨ បានប្រាប់យើងឲ្យដឹងថា សុបិន្តរបស់គាត់គឺបានកើតឡើងនៅពាក់កណ្ដាលយប់ ដោយបានបញ្ជាក់ថា "ព្រលឹមស្រាងៗនាថ្ងៃបន្ទាប់" លុះដល់ព្រឹកឡើងតើយ៉ាកុបបានធ្វើអ្វី? ____________________________________________

  ____________________________________________________________

- តើគាត់បានដាក់ឈ្មោះឲ្យកន្លែងនោះថាដូចម្ដេច? _________________________

  ចូលសង្កេតមើលខយោងនៅក្នុងព្រះគម្ពីររបស់លោកអ្នក។ នៅក្នុងព្រះគម្ពីររបស់លោកអ្នកគឺនឹងមានខយោងប្រាប់អំពីអត្ថន័យនៃពាក្យថា "បេតអែល"។ គឺវាមានន័យថា ______________

  ____________________________________________________________

  ពាក្យបេអែលនេះមកពីពាក្យពីរមាត់គឺ បេត (Beth) មានន័យថាផ្ទះ ហើយនឹងពាក្យថាអែល (El) ដែលមានន័យថាព្រះ។
- នៅក្នុងខ ២០-២២ យ៉ាកុបបានស្បថ! ក្នុងការការស្បថគឺតែងតែមានបង្កប់នូវពាក្យពីរមាត់គឺ "បើសិនជា" និង ពាក្យថា "នោះនឹង"។
  - o តើពាក្យថា "បើសិនជា" មានន័យដូចម្ដេច? ______________________________

    ____________________________________________________________

    ____________________________________________________________

o តើពាក្យថា "នោះនឹង" មានន័យដូចម្ដេច? ______________________________

______________________________________________

______________________________________________

យ៉ាកុបបាននិយាយថថា <u>**បើសិនជា**</u> ព្រះជាម្ចាស់នឹង ១. គង់នៅជាមួយគាត់ ហើយតាមការពារគាត់ ២. ប្រទានឲ្យគាត់នូវម្ហូបអាហារ និង សម្លៀកបំពាក់ ៣. ជួយការពារគាត់ឲ្យវិលត្រឡប់ទៅផ្ទះរបស់ឪពុកគាត់វិញដោយសុវត្ថិភាព <u>**នោះនឹង**</u> ១. ព្រះជាម្ចាស់នឹងបានជាព្រះរបស់គាត់ ២. ដុំថ្ម ឬ សសរ នឹង បានជាព្រះដំណាក់នៃព្រះជាម្ចាស់ និង ៣. គ្រប់អ្វីដែលព្រះជាម្ចាស់បានប្រទានមកឲ្យ គាត់នឹងដក ១ ភាគនៅក្នុង ១០ ថ្វាយដល់ព្រះជាម្ចាស់វិញ។

- នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៨:២២ គឺជាបទគម្ពីរយោងអំពីការថ្វាយដង្វាយ ១ ភាគនៅក្នុង ១០។ យ៉ាកុបបានប្ដេជ្ញាចិត្តនឹងថ្វាយ ១ ភាគនៅក្នុង ១០ ពីគ្រប់អ្វីៗដែលគាត់ទទួលបានពីព្រះជាម្ចាស់។ នៅមានកន្លែងផ្សេងទៀតនៃព្រះគម្ពីរបានកំណត់ឲ្យថ្វាយដង្វាយមួយភាគដប់ចំពោះទ្រព្យសម្បត្តិដែលមាន ហើយការអនុវត្តន៍ថ្វាយដង្វាយមួយភាគដប់ក៏បានជាប់មករហូតដល់សព្វថ្ងៃនេះ។ នៅក្នុងពួកជំនុំគឺបានយកគំរូតាមការថ្វាយដង្វាយរបស់យ៉ាកុប! ការថ្វាយដង្វាយមួយភាគដប់គឺជាការរំលឹកឲ្យដឹងថាគ្រប់អ្វីៗដែលខ្លួនមានគឺសុទ្ធតែបានមកពីព្រះជាម្ចាស់ទាំងអស់ គឺមានតែទ្រង់មួយប៉ុណ្ណោះដែលអ្នកផ្គត់ផ្គង់រាល់សេចក្ដីត្រូវការរបស់យើងម្នាក់ៗ។

## មេរៀនទី ៤ - ផ្នែកទី ២

## ការឆ្លុះបញ្ចាំងៈ

ជាថ្មីម្ដងទៀតយើងត្រូវតែផ្អាកការសិក្សារបស់បន្តិចសិន ដើម្បីចំណាយពេលធ្វើការឆ្លុះបញ្ចាំងនូវគ្រប់រឿងរ៉ាវនានាអំពីយ៉ាកុបដែលបានរត់គេចខ្លួនទៅនៅនឹងផ្ទះឡាបាន់ពូរបស់គាត់។ ការរត់គេចរបស់គាត់គឺដើម្បីឲ្យបានរួចពីការសម្លាប់! នៅតាមផ្លូវគាត់បានគេងមួយយប់នៅក្រោមពន្លឺផ្កាយជាច្រើនដោយកើយនឹងថ្ម គាត់ក៏បានយល់សុបិន្ត តែសុបិន្តមិនមែនដូចជាសុបិន្តធម្មតាពីមុនមកនោះទេ។ គាត់សុបិន្តឃើញថា ព្រះជាម្ចាស់បានយាងចុះមករកគាត់ ហើយបានសន្យានឹងគាត់ដូចគ្នានឹងអ្វីដែលទ្រង់បានសន្យាជាមួយនឹងលោក អប្រាហាំ និង អ៊ីសាក់ ហើយក៏បន្តមកដល់គាត់ គឺថាទឹកដីទាំងប៉ុន្មាននឹងបានជារបស់គាត់ និងកូនចៅរបស់គាត់ ហើយ កូនចៅជំនាន់ក្រោយរបស់គាត់នឹងបានបែកខ្ញែកនៅពាសពេញទាំងផែនដីផង។ គ្រប់មនុស្សទាំងអស់នៅលើផែនដីនឹងបានទទួលព្រះពរតាមរយៈគាត់ និង កូនចៅរបស់គាត់នៅជំនាន់ក្រោយៗមកទៀត។ រួចយ៉ាកុបបានដឹងថានោះគឺជាវត្តមានរបស់ព្រះជាម្ចាស់ ហេតុដូច្នេះហើយទើបគាត់បានយកដុំថ្មសង់ធ្វើជាស្តូបថ្វាយដល់ទ្រង់ ដោយយកប្រេងមកបង្ហូរពីលើថ្មនោះ ហើយទុកកន្លែងនោះថាជាទីបរិសុទ្ធ។ គាត់បានសាង

សង់ឡើងក្នុងភាពជាក់ស្តែងដោយមានពាក្យថា បើសិនជា និង នោះនឹង រួមបញ្ចូលជាមួយនឹងសេចក្តីសន្យាពីការថ្វាយដង្វាយមួយភាគដប់ពីគ្រប់អ្វីៗដែលគាត់បានទទួលពីព្រះទៅព្រះជាម្ចាស់វិញទៀតផង។ នេះគឺជាការសង្ខេបសាច់រឿងរបស់យ៉ាកុប។

ឥឡូវនេះគឺជាការចាប់ផ្តើមថ្មីមួយទៀតអំពីយ៉ាកុបដដែល គឺការត្រង់ចំណុចនៃការវិលត្រឡប់មកវិញរបស់គាត់។ តើយ៉ាកុបបានទទួលយកព្រះរបស់ឪពុកគាត់មកធ្វើជាព្រះជាម្ចាស់ដោយខ្លួនឯងឬទេ? តើព្រះជាម្ចាស់មានន័យដូចម្តេចចំពោះគាត់? តើនៅមានអ្វីខ្លះទៀត? នៅទីបំផុតវត្តមានរបស់ព្រះជាម្ចាស់ក៏គង់នៅទីនោះ យ៉ាកុបក៏មានការភ័យខ្លាច! ព្រោះគាត់ទទួលស្គាល់ថាទីកន្លែងនោះមិនមែនជាកន្លែងធម្មតាឡើយ គឺជាកន្លែងដ៏អស្ចារ្យមួយ គ្មានទីកន្លែងណាផ្សេងទៀតសក្តិសមធ្វើជាដំណាក់របស់ព្រះជាម្ចាស់សោះឡើយ គឺជាច្រកទ្វារទៅកាន់ស្ថានសួគ៌។ ការមួយដែលបានដឹងគឺថាមនុស្សគ្រប់ៗគ្នាបានមើលទៅឯយ៉ាកុបក្នុងក្រសែរភ្នែកខុសៗគ្នានៅវេលាយប់នៅ និង នាព្រឹកព្រលឹមក្នុងថ្ងៃបន្ទាប់។ គាត់បានត្រៀមខ្លួនរួចជាស្រេចក្នុងការសាកល្បងនឹងព្រះជាម្ចាស់! ព្រះអង្គបានទតមើលមកទូលបង្គំ ដ្បិតទូលបង្គំមានសេចក្តីភ័យខ្លាច ចំពោះការតាមសម្លាប់! ទូលបង្គំគ្មានអ្វីទាំងអស់ តែព្រះអង្គបានផ្គត់ផ្គង់ម្ហូបអាហារ និង សម្លៀកបំពាក់ដល់ទូលបង្គំយ៉ាងគ្រប់គ្រាន់។ ទូលបង្គំបានរត់ចាកចេញពីផ្ទះ ចេញពីគ្រួសារ និង អ្វីៗដែលទូលបង្គំស្រលាញ់ ប៉ុន្តែទ្រង់បាននាំទូលបង្គំត្រឡប់មកវិញដោយសុវត្ថិភាព។ នៅក្នុងញាណរបស់ទូលបង្គំមានបញ្ហាជាច្រើនដែលត្រូវសួរ ត្រូវការ សូមឲ្យព្រះអង្គធ្វើកិច្ចការទាំងនេះសម្រាប់គាត់។ តើទូលបង្គំធ្លាប់បានទូលសូមអ្វីពីព្រះជាម្ចាស់ដោយចិត្តរបស់ទូលបង្គំដែរឬទេ? តើនៅពេលណាទើបដល់ពេលវេលាសម្រាប់ទូលបង្គំសូមពីទ្រង់? ________

________________________________________

________________________________________

បើសិនជាទូលបង្គំមិនបានទូលសូមព្រះអង្គទាំងទទួចទេនោះ តើនឹងមានអ្វីជាបន្ទុកយ៉ាងធ្ងន់ធ្ងរនៅក្នុងចិត្តទូលបង្គំ? ទូលបង្គំសូមឲ្យមានការធានាចំពោះទូលបង្គំថា មានសេចក្តីស្រលាញ់ និង ការយកព្រះហឫទ័យទុកដាក់ចំពោះទូលបង្គំ។ ទូលបង្គំចង់ទ្រង់ធ្វើជាព្រះជាម្ចាស់របស់ទូលបង្គំ ហើយទូលបង្គំក៏ចង់ធ្វើជាកូនស្ងួនភ្ងារបស់ទ្រង់ដែរ។ ________________________________

________________________________________

________________________________________

យ៉ាកុបក៏បានសន្យាជាមួយនឹងព្រះជាម្ចាស់ថា ទ្រង់នឹងធ្វើជាព្រះរបស់គាត់ ហើយគាត់នឹងទទួលស្គាល់ថាទីកន្លែងនេះគឺជាព្រះដំណាក់របស់ព្រះជាម្ចាស់ មិនតែប៉ុណ្ណោះគាត់បានសន្យាទៀតថា នឹងថ្វាយដង្វាយមួយភាគដប់ពីគ្រប់ៗអ្វីដែលព្រះបានប្រទានពរដល់គាត់។ តើនេះដូចជាព្រះជាម្ចាស់របស់លោកអ្នកដែរឬទេ? តើលោកអ្នកបានទទួលទ្រង់ធ្វើជាព្រះតែមួយ ដែលបានផ្គត់ផ្គង់គ្រប់ទាំងសេចក្តីត្រូវការនៅក្នុងចិត្តរបស់លោក

អ្នកដែរឬទេ? យ៉ាកុបបានឃើញខ្លួនឯងធ្វើទីបន្ទាល់ អំពីទំនាក់ទំនងរវាងគាត់ជាមួយនឹងព្រះតាមរយៈការថ្វាយដង្វាយមួយភាគដប់។ តើលោកអ្នកនឹងធ្វើជាសក្ខីភាពអំពីទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងទ្រង់យ៉ាងដូចម្តេច? ________________________________________________

________________________________________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ព្រះអង្គបានលេចមកឯយ៉ាកុបក្នុងពេលដែលជីវិតរបស់គាត់កំពុងតែដាក់ចុះជាខ្លាំង គឺនៅពេលដែលគាត់កំពុងរត់គេចចេញពីការតាមសម្លាប់ គាត់កំពុងតែជួបនឹងភាពអស់សង្ឃឹម ត្រូវឃ្លាតឆ្ងាយពីទីកន្លែងដែលគាត់ធ្លាប់រស់នៅ និង ឆ្ងាយពីអ្វីដែលគាត់ធ្លាប់មាន ក្នុងពេលដែលគាត់កំពុងតែឯកោ ព្រះអង្គក៏បង្ហាញវត្តមានទ្រង់ដល់គាត់ ព្រមទាំងប្រកាសប្រាប់ឲ្យគាត់ដឹងថា ទ្រង់បានចងសម្ព័ន្ធមេត្រីជាមួយនឹងជីតាគាត់ ឪពុកគាត់ ហើយបន្តមកដល់គាត់ទៀតផង។ ព្រះអង្គមិនប្រែប្រួលឡើយ! ហើយព្រះបន្ទូលទ្រង់ក៏មិនចេះផ្លាស់ប្រែដែរ។ ទូលបង្គំសូមឲ្យទ្រង់បានយាងមកពេលដែលទូលបង្គំកំពុងតែឯកោ! ព្រះអង្គទ្រង់ជ្រាប់គ្រប់ទាំងសេចក្តីត្រូវការនៅក្នុងចិត្តរបស់ទូលបង្គំ។ ទូលបង្គំសូមព្រះអង្គមកធ្វើជាព្រះរបស់ទូលបង្គំ ហើយទូលបង្គំបានត្រឡប់ជាកូនស្ងួនភ្ងារបស់ព្រះអង្គជារៀងរហូតផង! ប្រយោជន៍ឲ្យទូលបង្គំបានធ្វើជាបន្ទាល់អំពីទំនាក់ទំនងរវាងទូលបង្គំយើងខ្ញុំដោយសារតែព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ គឺអង្គព្រះយេស៊ូវគ្រីស្ទ។ ទូលបង្គំសូមអរព្រះគុណ និង សរសើរដម្កើងចំពោះទ្រង់ ព្រមទាំងទូលថ្វាយទ្រង់វិញនូវអ្វីៗដែលទ្រង់បានប្រទានមកទូលបង្គំ។ ________________________________________________

________________________________________________

________________________________________________

________________________________________________

## មេរៀនទី ៤ - ផ្នែកទី ៣

## សេចក្តីណែនាំៈ

យ៉ាកុបបានចាកចេញពីបេតអែល ដែលជាកន្លែងគាត់បានសុបិន្ត រួចក៏បន្តដំណើរទៅកាន់តំបន់ហារ៉ាន។ គាត់បានមកដល់ទឹកដីរបស់មនុស្សភាគខាងកើត ត្រង់កន្លែងដែលមានអណ្តូងទឹកមួយ នៅទីនោះមានហ្វូងចៀមខ្លះៗ និង អ្នកគង្វាលនៅក្បែរនោះដែរ។ អណ្តូងទឹកនោះគឺសម្រាប់ហ្វូងចៀមនៅក្បែរនោះផឹក ក៏មានផ្ទាំងថ្មមួយដុំធំបានដាក់នៅមាត់អណ្តូងនោះដែរ។ នៅពេលណាពួកអ្នកគង្វាលគេរំកិលផ្ទាំងថ្មនោះចេញ ក៏មានទឹកហូរចេញមកពីអណ្តូងសម្រាប់ឲ្យហ្វូងចៀមរបស់ពួកគេផឹង លុះពេលពួកគេបានហ្វូងចៀមផឹកឆ្អែតរួចរាល់អស់ហើយ ពួកគេក៏រំកិលផ្ទាំងថ្មនោះបិតមាត់អណ្តូងវិញ។

**កិច្ចការៈ**

ចូរអានព្រះគម្ពីរលោកុប្បត្តិ ២៩:១-៣០! នៅក្នុងបទគម្ពីរទាំងនេះនឹងណែនាំយើងឲ្យបានស្គាល់ ឡាបាន់ លេអា និង រ៉ាជែល។ ចូរចងចាំថា ឡាបាន់គឺជាបងប្រុសរបស់រេបេកា ហើយត្រូវជាឪពុកក្មេករបស់យ៉ាកុបដែរ។

**លំហាត់:** យ៉ាកុបបានជួបប្រាស្រ័យទាក់ទងសន្ទនាគ្នាជាមួយនឹងពួកអ្នកគង្វាលខ្លះៗនៅទីនោះ។

- នៅក្នុងខ ៤ តើយ៉ាកុបបានឃើញអ្វី? ______________________________________________

  ______________________________________________

- នៅក្នុងខ ៥ បន្ទាប់មកគាត់បានសួរដូចម្ដេច? ______________________________________________

  ______________________________________________

- នៅក្នុងខ ៦ យើងបានដឹងថា ឡាបាន់គាត់សុខសប្បាយជាធម្មតាទេ ហើយកូនស្រីរបស់គាត់គឺ នាង រ៉ាជែលត្រូវបានណែនាំបានស្គាល់ដែរ។ នៅក្នុងខ ៧ យ៉ាកុបបានឲ្យហ្វូងចៀមដេកសម្រាប់នៅក្បែរអណ្ដូងទឹកក្រោយពីពួកគេបានផឹកទឹកឆ្អែតហើយ រួចគាត់ក៏នាំហ្វូងចៀមទាំងនោះទៅឯវាលស្មៅវិញ។ នៅក្នុងខ ៨ តើគាត់បានជួបនឹងបញ្ហាអ្វី? ______________________________________________

  ______________________________________________

  ______________________________________________

- រ៉ាជែលបានមកឯងអណ្ដូងទឹកដោយមានហ្វូងចៀមរបស់ឪពុកនាងមកជាមួយផង។ រ៉ាជែលគឺជា _

  ______________________________________________

- នៅក្នុងខ ១០ តើយ៉ាកុបបានធ្វើដូចម្ដេចនៅពេលដែលគាត់បានឃើញនាង រ៉ាជែល? __________

  ______________________________________________

- នៅក្នុងខ ១១-១២ យ៉ាកុបបានណែនាំខ្លួនគាត់បានទៅនាង រ៉ាជែល ថាគាត់គឺជានរណា ពេលនោះនាងក៏រត់ត្រឡប់ទៅផ្ទះវិញ ហើយរៀបរាប់ឪពុករបស់នាងអំពីរឿងនោះ។ តើ ឡាបាន់បានធ្វើដូចម្ដេចនៅពេលគាត់បានឮដំណឹងអំពីយ៉ាកុបដូច្នេះ? ______________________________________________

  ______________________________________________

  ______________________________________________

- បន្ទាប់ពីយ៉ាកុបបានរៀបរាប់រឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងចប់សព្វគ្រប់អស់ហើយ។ នៅក្នុង ១៤ តើឡាបាន់បានឆ្លើយតបវិញយ៉ាងដូចម្ដេច? ______________________________________________

  ______________________________________________

## សេចក្ដីបង្រៀនៈ

ក្រោយពីអ្វីៗទាំងអស់បានកើតឡើងចំពោះជីវិតរបស់យ៉ាកុបហើយ គាត់បានរកឃើញទីកន្លែងសម្រាប់គាត់អាស្រ័យនៅ។ ចំណែកឯម្ដាយ និង គ្រួសាររបស់គាត់ក៏មិនបានសួរនាំ ឬរករឿងអ្វីចំពោះគាត់ក្នុងការដែលគាត់មករស់នៅជាសមាជិកនៃគ្រួសារឡាបាន់ជាពូរបស់គាត់ដែរ។ នៅក្នុងគ្រួសារឡាបាន់បានរាប់ទុកគាត់ថាជា "ឯងគឺជាសាច់ គឺជាឈាមរបស់ខ្ញុំផ្ទាល់"។ ប៉ុន្តែ យ៉ាកុបគាត់តាំងស្វែងយល់អំពីអត្ថន័យពិតប្រាកដចំពោះពាក្យថា "ជាសាច់ ជាឈាមផ្ទាល់" នោះថាតើមានន័យយ៉ាងណា។ ចរិតលក្ខណៈជាសមាជិកគ្រួសារក៏ចេះតែស៊ីជម្រៅទៅៗ។

## កិច្ចការៈ

ចូរអានត្រង់ខ ១៤-៣០! ចូរគាស់បន្ទាត់ពីក្រោមពាក្យទាំងឡាយណាដែលជាការរៀបរាប់អំពីចរិតលក្ខណៈរបស់ឡាបាន់ និង គ្រួសាររេបេកា។ តើមានពាក្យ ឬ ឃ្លាអ្វីខ្លះ? ______________________________

______________________________________________________________________

______________________________________________________________________

## មេរៀនទី ៤ - ផ្នែកទី ៤

**លំហាត់:** នៅក្នុងខ ១៤ ឡាបាន់ និង យ៉ាកុបបានពិភាក្សាគ្នាអំពីបញ្ហាប្រាក់ឈ្នួល។

- ក្រោយពីយ៉ាកុបបានរស់នៅក្នុងផ្ទះ និង ធ្វើការជាមួយនឹងឡាបាន់បានរយៈពេលមួយខែក្រោយមកឡាបាន់ គាត់មិនចង់ឲ្យយ៉ាកុបធ្វើការងារក្នុងនាមជាសាច់ញាត្តិ ដោយគ្មានបានអ្វីសោះនោះទេ។ នៅក្នុងខ ១៥ តើឡាបាន់បានសួរដូចម្ដេច? ______________________________

  ______________________________________________________________________

  ______________________________________________________________________

- នៅក្នុងខ ១៦-១៧ យើងនឹងសិក្សាអំពីកូនស្រីទាំងពីរនាក់របស់លោកឡាបាន់។ គឺកូនស្រីច្បងគឺ ________________________________ កូនស្រីប្អូនគឺ ____________________

  ចូររៀបរាប់អំពីនាងលេអា? ______________________________

  ______________________________________________________________________

  ចូររៀបរាប់អំពីនាងរ៉ាជែល? ______________________________

  ______________________________________________________________________

- នៅក្នុងខ ១៨ និយាយអំពីយ៉ាកុបបានស្រលាញ់នាងរ៉ាជែល។ តើយ៉ាកុបបានស្នើសុំទៅឡាបាន់អំពីថ្លៃឈ្នួលរបស់គាត់យ៉ាងដូចម្តេច? ______________________________________________

______________________________________________________________

- ឡាបាន់បានយល់ព្រមតាមសំណើររបស់យ៉ាកុប ដោយគាត់គិតថាគឺជាការប្រសើរជាងឲ្យកូនស្រីរបស់គាត់ទៅរៀបការជាមួយនឹងបុរសណាផ្សេងទៀត។ ដោយយោងតាមខ ២០ តើយ៉ាងកុប ធ្វើការបម្រើនៅផ្ទះឡាបាន់ដោយសារគាត់ដឹងថានឹងបាននាងរ៉ាជែលមកធ្វើជាប្រពន្ធមែនទេ? _____

______________________________________________________________

- រយៈពេល ៧ ឆ្នាំបានកន្លងផុតទៅកិច្ចការបម្រើរបស់យ៉ាកុបក៏ដល់ពេលកំណត់តាមកិច្ចសន្យា ដូច្នេះ យ៉ាកុបក៏ទៅជួបនឹងឡាបាន់ ដើម្បីជម្រាបគាត់ថាកិច្ចការភាគីខាងខ្លួនបានចប់សព្វគ្រប់ហើយ និងសូមឲ្យឡាបាន់រៀបការកូនស្រី (រ៉ាជែល) របស់គាត់មកធ្វើជាប្រពន្ធ។ ភ្លាមនោះឡាបាន់ក៏យល់ព្រមហើយរៀបចំពិធីអបអរសាទរ។ នៅក្នុងខ ២២ តើឡាបាន់បានធ្វើដូចម្តេច? _______________

______________________________________________________________

- ទោះបីជាសាច់រឿងត្រូវបានបញ្ចប់ក៏ពិតមែន! តែនៅក្នុងខ ២៣ តើឡាបាន់បានធ្វើអ្វីខ្លះ? _______

______________________________________________________________

______________________________________________________________

______________________________________________________________

ពេលនេះនាង លេអា បានក្លាយទៅជាប្រពន្ធរបស់យ៉ាកុប! ឡាបាន់បានឲ្យនាងលេអាជាកូនស្រីបង ________________________________ ខណៈពេលដែលអ្នកបម្រើរបស់នាង។

- លុះដល់ព្រឹកស្អែកឡើង ការពិតត្រូវបានលាតត្រដាង! គឺនាងលេអាបានគេនៅក្បែរម្ខាងខ្លួនទៅហើយ! ពេលឃើញដូច្នេះ យ៉ាកុបគ្មាននិយាយអ្វីទាំងអស់ ក៏ទៅជួបនឹងឡាបាប់ជាបន្ទាន់។ នៅក្នុងខ ២៥ តើយ៉ាកុបបានសួរទៅឡាបាន់ដូចម្តេច? ________________________________________

______________________________________________________________

______________________________________________________________

យ៉ាកុបនិយាយទៅឡាបាន់ថា "តើខ្ញុំមិនបានធ្វើការបម្រើដើម្បីរៀបការជាមួយនឹង រ៉ាជែលទេឬអី?" ក្នុងខណៈនោះសំណួរបានចោទឡើងដើម្បីលាតត្រដាងអំពីស្ថានភាពនៃសេចក្តីពិត។ _________

______________________________________________________________

- បន្ទាប់ពីការបោកបញ្ឆោតយ៉ាកុបហើយ នៅក្នុងខ ២៦ តើឡាបាន់បានប្រាប់យ៉ាកុបដូចម្តេច? ___
______________________________________________________________
______________________________________________________________

តាមប្រពៃណីយ៍ទំនៀមទម្លាប់របស់ពួកគេនៅសម័យនោះ គឺត្រូវតែឲ្យកូនស្រីច្បងរៀបការមុនកូនស្រីប្អូន! ឡាបាន់បានយល់ព្រមប្រគល់នាង រ៉ាជែលឲ្យទៅធ្វើជាប្រពន្ធយ៉ាកុប លុះត្រាយ៉ាកុបធ្វើការងារបម្រើរយៈ ៧ ឆ្នាំទៀតទើបគាត់ព្រមរៀបការឲ្យ។ នៅក្នុងខ ២៨ បានប្រាប់យើងថា "យ៉ាកុបក៏បានយល់ព្រម" តាមលក្ខ័ណ្ឌរបស់ឡាបាន់។ យ៉ាកុបបានរួមរស់ជាមួយនាង លេអាជាប្តីប្រពន្ធបានមួយសប្តាហ៍ លុះក្រោយមកគាត់ក៏បានទទួលនាង រ៉ាជែលមកធ្វើជាប្រពន្ធម្នាក់ទៀត។ ក្នុងលក្ខ័ណ្ឌនេះ ឡាបាន់បាន រ៉ាជែលឲ្យធ្វើជា ______________________________
នេះយើងបានដឹងតាមរយៈខ ២៩។

- នៅក្នុងខ ៣០ បានប្រាប់យើងឲ្យដឹងអំពីទំនាក់ទំនងរវាងយ៉ាកុប និង ប្រពន្ធទាំងពីររបស់គាត់។ ពីមុនគាត់ធ្លាប់បានរស់នៅក្នុងគ្រួសារដែលជាកូនសំណព្វចិត្តរបស់ម្តាយ តែមកដល់ត្រង់ត្រឹមនេះគាត់បានរស់ជាគ្រួសារមួយដែលមានប្រពន្ធពីរនាក់ ហើយស្រលាញ់ប្រពន្ធមួយជាប្រពន្ធមួយទៀត។ គឺគាត់បានធ្វើថាការងារបម្រើក្នុងផ្ទះឡាបាន់អស់រយៈពេល _______________ ឆ្នាំទៀត។

## ការឆ្លុះបញ្ចាំង:

មកដល់ត្រង់ចំណុចនេះ មានបញ្ហាមួយចំនួនបានចូលមកក្នុងគំនិតនាំឲ្យយើងធ្វើការពិចារណា។ រឿងមួយដែលធ្វើយើងមានការពិចារណាគឺអំពី នាង លេអា គឺជានារីម្នាក់ត្រូវបានឪពុករៀបចំផ្សំផ្គុំឲ្យធ្វើជាប្រពន្ធរបស់បុរសម្នាក់ដែលមិនបានស្រលាញ់នាង។ តើនាងនឹងមានអារម្មណ៍ដូចម្តេច? តើនាងមិនមានសម្រស់ស្អាតមែនទេ? តាមបទគម្ពីរបានបរិយាយប្រាប់ថាអំពីនាងថានាងមានបញ្ហានៅត្រង់ភ្នែកម្ខាង។ នាងមានអាយុច្រើនជាង តែនៅមិនទាន់រៀបការឡើយ។ ចំណែកឯប្អូនស្រីរបស់នាងគឺ រ៉ាជែលគឺនារីម្នាក់ដែលមានមនុស្សប្រុសជាច្រើនប្រាថ្នាចង់បានមកធ្វើជាប្រពន្ធ ប៉ុន្តែ លេអា នាងបានដឹងច្បាស់អំពីប្រពៃណីយ៍ទំនៀមទម្លាប់របស់មនុស្សក្នុងសម័យកាលនោះ។ តើនាងបានដឹងថារយៈពេល ៧ ឆ្នាំដំបូងនាងនឹងត្រូវរៀបការជាមួយនឹងយ៉ាកុបជាមនុស្សពូកែខាងបោកបញ្ឆោតដែរឬទេ? តើនាងបានដឹងថានាងនឹងត្រូវរៀបការ ហើយក្នុងពេលមួយរំពេចក្រោយនោះមក ស្រាប់តែត្រូវបានបើកសម្តែងពីការខកចិត្តដាច់ជាពិសេសនោះ តើនាងនឹងត្រូវបានទៅលោកយ៉ាកុបបានដែរឬទេ?

ឧបមាថាលោកអ្នកគឺជាអ្នកយកពត៌មាន ហើយត្រូវបានចាត់ឲ្យទៅជាការសម្ភាសន៍ជាមួយនឹងលេអា តើលោកអ្នកនាងសួរសំនួរបែបណាខ្លះទៅកាន់នាង? តើសំនួរបែបណាដែលជាការចាប់អារម្មណ៍របស់អ្នកអាន អំពីរឿងរ៉ាវនានាដែលទើបនឹងបានកើតឡើងនោះ? តើនាងលេអាជាអ្នកមានចំណែកនៅក្នុង

ការបោកបញ្ឆោតនោះដែរឬទេ? តើនាងគឺជាជនរងគ្រោះដែលគ្មានកំហុសមែនទេ? តើរឿងរ៉ាវទាំងអស់នេះនឹងត្រូវដោះស្រាយយ៉ាងណា? បើសិនជាលោកអ្នកធ្វើការប្រៀបធៀបពួកគេទៅនឹងប្អូនស្រី ឬបងប្រុសរបស់លោកអ្នក តើលោកអ្នកនឹងមានអារម្មណ៍បែបណាចំពោះពួកគេ?

ចូរចំណាយពេលវេលាខ្លះដើម្បីសរសេរនូវសំនួររបស់លោកអ្នកសម្រាប់ធ្វើការសម្ភាសន៍ ____________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

## មេរៀនទី ៤ - ផ្នែកទី ៥

## សំនួរអនុវត្ត:

ប្រហែលជាលោកអ្នកធ្លាប់មានបទពិសោធន៍ក្នុងការប្រកួតប្រជែងដើម្បីយកបានទទួលស្គាល់ អាចជារឿងស្នេហា...។ ចូរនឹងគិតថាតើនរណាគឺជាដៃគូរប្រកួតប្រជែងរបស់លោកអ្នក? តើគេគឺជាបងប្អូនរបស់អ្នកមែនទេ? តើមានអ្វីខ្លះដែលនាំឲ្យលោកអ្នកគិតថាខ្លួនឯងអន់ជាងគេ? ________________________

________________________________________

________________________________________

តើលោកអ្នកតែងតែប្រាថ្នាចង់ទៅជាអ្វី ឬ មានអ្វីដែលធ្វើឲ្យលោកអ្នកជឿជាក់ថាខ្លួនមានតម្លៃពិសេសជាងអ្នកដទៃ? ________________________________________

________________________________________

________________________________________

តើអ្នកដទៃប្រព្រឹត្តចំពោះលោកអ្នកយ៉ាងដូចម្តេច? តើលោកអ្នកមានបទពិសោធន៍ដូចម្តេច? ________

________________________________________

________________________________________

តើលោកអ្នកបណ្តោយការប្រព្រឹត្តិបែបណាដើម្បីធ្វើឲ្យលោកអ្នកមានអារម្មណ៍? ________________

________________________________________

________________________________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ទូលបង្គំដឹងថាទ្រង់ជ្រាបគ្រប់ការឈឺចាប់ដែលមាននៅក្នុងចិត្តទូលបង្គំ ពីព្រោះទូលបង្គំមានអារម្មណ៍ដឹងថាទូលបង្គំអន់ជាអ្នកដទៃ។ ចំណែកអ្នកដទៃ ពួកគេមើលទៅគ្រប់យ៉ាងហាក់ដូចជាមានសមត្ថភាព មានខួរក្បាលល្អ មានទេពកោសល្យ មានបុគ្គលិកលក្ខណៈ និង អ្វីៗទាំងអស់សុទ្ធតែប្រសើរជាងទូលបង្គំជាហេតុធ្វើឲ្យពួកគេមានការទាក់ទាញជាងទូលបង្គំ។ សូមទ្រង់ជួយដល់ទូលបង្គំដើម្បីឲ្យ ទូលបង្គំអាចអរព្រះគុណដល់ទ្រង់ចំពោះអ្វីៗដែលទ្រង់បានផ្តល់សម្រាប់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណទ្រង់ចំពោះសេចក្តីស្រលាញ់ និង ព្រះពរក្នុងជីវិតរបស់ទូលបង្គំ ដោយភាពស្មោះត្រង់នៃទ្រង់។ ___________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

## ការឆ្លុះបញ្ចាំងៈ

នៅមានចំណុចមួយទៀតសម្រាប់យើងធ្វើការពិចារណាអំពីយ៉ាកុប។ តាំងពីដើមដល់ចប់គឺគាត់ត្រូវបានជួបនឹងការបោកបញ្ឆោតជានិច្ច! គាត់បានព្រមព្រៀងគ្នាជាមួយនឹងឡាបាន់ថាត្រូវធ្វើការងារបម្រើក្នុងរវាង ៧ ឆ្នាំដើម្បីបាននាងរ៉ាជែលមកធ្វើជាប្រពន្ធ ហើយវាជាការពិតគឺគាត់បានធ្វើតាមការព្រមព្រៀងនោះមែន។ រយៈពេលនៃកិច្ចព្រមព្រៀងក៏មកដល់ទីបញ្ចប់ គឺជាពេលវេលាដែលយ៉ាកុបត្រូវទទួលយកនាងមកធ្វើជាប្រពន្ធគឺជាវេលាព្រះថោងតោងស្បៃ រួមរស់នឹងមួយគ្នាជាសាច់ឈាមតែមួយ។ ដោយព្រោះតែមានស្បៃបាំងមុខ និង ភាពងងឹតក្នុងពេលរាត្រីផង ទើបធ្វើឲ្យឡាបាន់អាចបោកបញ្ឆោតយ៉ាកុបបានដោយងាយស្រួល ប៉ុន្តែលុះដល់វេលាព្រឹកនាថ្ងៃបន្ទាប់ ព្រះអាទិត្យបញ្ចេញរស្មីបំភ្លឺ នៅទីបំផុតការពិតត្រូវបានលាតត្រដាងឲ្យបានឃើញយ៉ាងច្បាស់។ តើសេចក្តីពិតនៅក្នុងខណៈពេលនោះមានសភាពដូចម្តេច?

តើមានអ្វីកើតឡើងនៅពេលដែលភ្នែករបស់មនុស្សបានបើកឡើយហើយបានឃើញការពិតដូច្នេះ? យើងអាចនឹងវិលត្រឡប់ទៅវេលរឿងរបស់លោក អ័ដាំ និង នាង អេវ៉ា កាលពួកគេទាំងពីរនាក់នៅក្នុងសួនច្បារអេដែន (លោកុប្បត្តិ ៣:៧) គឺនៅពេលនោះ ភ្នែករបស់ពួកគេបានមើលឃើញ។ តើនឹងមានអារម្មណ៍ល្ងីល្ងើយ៉ាងណាទៅណ៎! យើងមានអារម្មណ៍ថាអ្វីៗត្រូវបានបកអាក្រាត ជាការងាយនឹងរងគ្រោះ ហើយទទួលស្គាល់ថា យើងម្នាក់គឺពិតជាងាយស្រួលធ្លាក់ចូលទៅក្នុងការឆបោករបស់អ្នកដទៃខ្លាំងណាស់។ យើងសួរខ្លួនឯងថាៈ តើខ្ញុំអាចជាមនុស្សល្ងីល្ងើអីដល់ថ្នាក់នេះ? អំពើបាបបានធ្វើឲ្យពួកយើងដឹងជាមុនថាអ្វីៗគ្រប់យ៉ាងគឺជាការងាយស្រួល ដូច្នេះហើយទើបយើងខិតខំព្យាយាមការពារខ្លួនឯងយ៉ាងប្រុងប្រយ័ត្នដើម្បីកុំឲ្យ

ភ្លាត់ចាញ់ការបោកបញ្ឆោតរបស់នរណាម្នាក់។ តាមការពិតយើងម្នាក់ៗក៏មិនខុសពីយ៉ាកុបនោះដែរ! ជានិច្ចកាល យើងតែងតែផ្តោតទៅលើអ្វីដែលខ្លួនជឿជាក់ថាវាគឺជាការពិត ជាជាងអ្វីៗដែលជាសេចក្តីពិត។

## ការអនុវត្តន៍ផ្ទាល់ខ្លួន:

ចូរនឹកដល់ខណៈពេលមួយដែលលោកអ្នកត្រូវចាញ់ការបោកបញ្ឆតរបស់គេដោយព្រោះតែការជឿទុកចិត្ត។ តើអ្នកបានចាញ់បោកបញ្ឆោតនរណា? តើបានចាញ់បោកគេក្នុងរឿងអ្វី? ______________________

______________________________________________________________________

______________________________________________________________________

ការបោកបញ្ឆោតអាចនាំឲ្យមានការចង់ស្តារមុខមាត់ឡើងវិញដូចជាអេសាវបានធ្វើដែរ។ តាមបទពិសោធន៍ តើលោកអ្នកមានប្រត្តិកម្ម ឬការឆ្លើយតបដូចម្តេចចំពោះការបោកបញ្ឆោត? ____________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

បើសិនជា ការបោកបញ្ឆោតគឺជាបុព្វហេតុធ្វើឲ្យលោកអ្នកមានចិត្តចង់ស្តារមុខមាត់ដោយប្រឆាំងតមចំពោះនរណាម្នាក់ បើដូច្នោះមែននោះ ព្រះជាម្ចាស់ចង់អញ្ជើញលោកអ្នកឲ្យមកទទួលការដោះឲ្យមានសេរីភាពចេញផុតពីបន្ទុកដ៏ធ្ងន់ដែលលោកអ្នកកំពុងមាននៅក្នុងជីវិតសព្វថ្ងៃនេះ ត្រឡប់មករស់នៅក្នុងជីវិតមួយយ៉ាងពេញបរិបូរណ៍វិញម្តង។ លោកអ្នកត្រូវបានទទួលការអញ្ជើញឲ្យចូលមករកព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់បានដោះបន្ទុកដ៏សែនធ្ងន់នេះចេញពីជីវិតលោកអ្នកហើយ! គឺទ្រង់ធ្វើជាអ្នកទទួលយកបន្ទុកទាំងនោះជំនួសអ្នក។

## សេចក្តីអធិស្ឋាន:

ឱព្រះអម្ចាស់អើយ! ទូលបង្គំតែងតែត្រូវបានគេបោកបញ្ឆោតរហូតមក! ហើយជឿលើការនិយាយកុហករបស់វិញ្ញាណអាក្រក់ដោយមិនបានជឿលើសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះអង្គ។ ទូលបង្គំត្រូវបានចាញ់ការបោកបញ្ឆោតតាមរយៈការឃោសនា ការផ្សាយពាណិជ្ជកម្មនានាជាច្រើនអំពីផលិតផល ឬ មុខទំនិញ និង សេវាកម្មផ្សេង មកពីអ្នកដឹកនាំ មិត្តភ័ក្រ រួមទាំងសមាជិកគ្រួសារផងដែរ។ មានពេលខ្លះទូលបង្គំបានជ្រើសរើសយកផ្លូវបោកបញ្ឆោតខ្លួនឯង ដោយសារការជឿតាមការកុហកបោកប្រាស់ និង ការឆបោក។ សូមទ្រង់អត់ទោសឲ្យទូលបង្គំផង! ទូលបង្គំចង់រស់នៅក្នុងជីវិតមួយដែលមានសេចក្តីពិត ទូលបង្គំចង់ស្គាល់សេចក្តីពិត។ ទូលបង្គំចង់ស្គាល់ ហើយជឿលើទ្រង់ ដ្បិតទ្រង់គឺជាសេចក្តីពិត។ ______________________

______________________________________________________________________

______________________________________________________________________

# មេរៀនទី ៥

## មេរៀនទី ៥ - ផ្នែកទី ១

### សេចក្ដីណែនាំ:

យ៉ាកុបបានរៀបការហើយ! គឺមាន លេអា និង រ៉ាជែល ពួកនាងទាំងពីរគឺជាប្រពន្ធរបស់គាត់។ រ៉ាជែលគឺជាប្អូននាងនៅក្មេង ហើយស្អាតជាងលេអាជាបងស្រីរបស់នាង។ ហើយយ៉ាកុបក៏ស្រលាញ់រ៉ាជែលជាងលេអាដែរ! នេះហើយគឺជាការនិយមរបស់មនុស្ស បង្កើតឲ្យមានបរិយាកាសមួយប្រកបដោយការប្រកួតប្រជែង និង ការច្រណែនឈ្នានីសត្តវារវាបបងប្អូនស្រីទាំងពីរនាក់។ ឡាបាន់បានប្រគល់អ្នកបម្រើឲ្យទៅកូនស្រីរបស់គាត់ទាំងពីរដូចៗគ្នា អ្នកបម្រើរបស់លេអាគឺ ស៊ីលផា ហើយអ្នកបម្រើរបស់រ៉ាជែលគឺ ប៊ីលហា។

លោកអ្នកត្រូវបានលើកទឹកចិត្តក្នុងការសិក្សាឲ្យបានកាន់តែច្បាស់ដោយខ្លួនឯង ជាមួយនឹងឈ្មោះរបស់កូនប្រុសទាំងប៉ុន្មានរបស់យ៉ាកុបដែលគេចាត់ទុកថាគឺជាបុព្វបុរស។ (កិច្ចការ ៧:៩) ពួកគេទាំងនោះគឺជាបុគ្គលយ៉ាងសំខាន់សម្រាប់ឲ្យយើងសិក្សា! ឈ្មោះរបស់ពួកគេមួយចំនួនលោកប្រហែលជាមិនធ្លាប់បានឮពីមុនមកនោះទេ តែយ៉ាងណាក៏ដោយក៏មានឈ្មោះខ្លះត្រូវបានមនុស្សជាច្រើនដាក់តាមរហូតមកទល់សព្វថ្ងៃនេះក៏មានដែរ។ លោកអ្នករៀងៗខ្លួនជ្រើសរើសយកវិធីណាក៏បានដែរតាមខ្លួនចូលចិត្ត តែសូមលើកទឹកចិត្តលោកអ្នកឲ្យកត់ត្រាន្ធវឈ្មោះកូនប្រុសរបស់យ៉ាកុបទាំងប៉ុន្មានចូលទៅក្នុងសៀវភៅកាត់របស់លោកអ្នកសម្រាប់ធ្វើជាអំណះអំណាងទៅថ្ងៃក្រោយៗទៀត ព្រោះថាឈ្មោះរបស់ពួកគេនិមួយៗគឺតំណាងឲ្យកុលសម្ព័ន្ធមួយ រួមសេចក្ដីទៅគឺថាឈ្មោះរបស់ពួកគេទាំងប៉ុន្មានគឺតំណាងឲ្យឈ្មោះកុលសម្ព័ន្ធទាំង ១២ របស់អ៊ីស្រាអែល។

### កិច្ចការ:

ចូរលោកអ្នកអានព្រះគម្ពីរលោកុប្បត្តិ ២៩:៣១ រហូតដល់លោកុប្បត្តិ ៣០:២៤។ ក្នុងពេលដែលលោកអ្នកកំពុងតែអានចូរលោកអ្នកគូសបន្ទាត់ពីក្រោមឈ្មោះកូនប្រុសទាំងប៉ុន្មានរបស់យ៉ាកុបដែលបានកើតមក។

### សេចក្ដីបង្រៀន:

ចំពោះស្ត្រីណាដែលចាប់ផ្ដើមមានផ្ទៃពោះ នេះគឺសបញ្ជាក់ឲ្យឃើញថាស្ត្រីនោះគឺបានទទួលព្រះពរមកពី ព្រះជាម្ចាស់ជាប្រាកដ។ ផ្ទុយមកវិញចំពោះស្ត្រីអារ ប្រាកដជាត្រូវបានមនុស្សម្នាក្នុងសហគមមើលងាយ ពេបជ្រាយឲ្យជាក់ជាមិនខាន។ ពេលយើងមកដល់ចំណុចនេះ បានធ្វើឲ្យយើងនឹកឃើញដល់លោកស្រី សារ៉ា រេបេកាជាដើម គឺពួកគេទាំងពីរនាក់គឺជាស្ត្រីអារ (លោកុប្បត្តិ ១៦:១ និង ២៥:២១)។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២៩:៣១ បានណែនាំដល់យើងម្ដងទៀតអំពីបញ្ហាស្ត្រីដែលចាប់ផ្ដើមមានផ្ទៃពោះ និង ស្ត្រីអារ។

នៅមានផ្នែកមួយទៀតនៃដំណើរវប្បធម៌ពនេចរ ក៏ត្រូវឲ្យស្វែងយល់អំពីអ្នកបម្រើផងដែរ។ នៅខាងដើមនៃព្រះគម្ពីរលោកុប្បត្តិ ១៦:៣-៤ យើងនឹងបានសិក្សាអំពីលោកស្រី សារ៉ា គឺជាស្ត្រីអារមិនអាចមានផ្ទៃពោះបានទើបគាត់ផ្តើមគំនិតបញ្ជូនអ្នកបម្រើរបស់ខ្លួនគឺនាង ហាហ្គា ឲ្យធ្វើជាប្រពន្ធរបស់គាត់ ហើយបានរួមដំណេកជាមួយនឹងប្តីរបស់គាត់គឺលោក អប្រាហាំ ក្រោយមកបន្តិចហាហ្គាក៏មានផ្ទៃពោះ។ ចំណែកឯនាង ស៊ីលផា និង ប៊ីលហា ក៏មិនខុសពីហាហ្គាដែរ គឺពួកគេទាំងពីរត្រូវបានម្ចាស់របស់នាងបង្គាប់ឲ្យទៅរួមដំណេកជាមួយនឹងប្តីរបស់គេគឺយ៉ាកុប (លោកុប្បត្តិ ៣០:៤,៩)។ យ៉ាកុបរួមដំណេកជាមួយនឹងអ្នកបម្រើទាំងនាក់នោះ រួចពួកគេក៏មានផ្ទៃពោះរៀងៗខ្លួន។ វាពិតជាគួរចាប់អារម្មណ៍ខ្លាំងណាស់ដែលព្រះគម្ពីរបានបង្រៀនយើងអំពី បុរសម្នាក់ និង ស្ត្រីម្នាក់ក្រោយពីបានរួមដំណេកជាមួយគ្នាហើយ ស្ត្រីក៏ផ្តើមមានផ្ទៃពោះរួចក៏ក្លាយទៅជាប្រពន្ធរបស់បុរសនោះទៅ។ ទង្វើនៃការរួមភេទ គឺជាការរួមភេទសម្ព័ន្ធរវាងបុរស និង ស្ត្រីហើយទង្វើនៃការរួមភេទរបស់បុរស និង ស្ត្រីនេះក៏ក្លាយទៅជាសាច់ឈាមតែមួយ (លោកុប្បត្តិ ២:២៤)។

## លំហាត់:

ចូរបំពេញតារាងខាងក្រោមនេះ ចាត់ទុកជាកិច្ចការរបស់លោកអ្នក ដោយអាចនូវបទគម្ពីរមួយចំនួន ហើយខយោងនៅក្នុងព្រះគម្ពីររបស់លោកអ្នកប្រហែលជាអាចជួយបានច្រើនក្នុងកិច្ចការនេះ។ កំណត់ឈ្មោះម្តាយ ឈ្មោះកូនប្រុស និង អត្ថន័យនៃឈ្មោះរបស់ពួកគេទាំងនោះផងដែរ។ ជាមួយនឹងការដាក់ឈ្មោះឲ្យកូននិមួយៗ ចូរសង្កេតមើលផលពិបាក និង ឧបសគ្គផ្ទៃក្នុងនៃប្រពន្ធទាំងពីររបស់យ៉ាកុប។

| ឈ្មោះរបស់ម្តាយ | ឈ្មោះរបស់កូន | អត្ថន័យនៃឈ្មោះរបស់កូន |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

- នៅក្នុងខ ៣១ យើងបានសិក្សាអំពីព្រះជាម្ចាស់បានទតឃើញថាលេអា មិនត្រូវបានទទួលសេចក្ដីស្រលាញ់ពីប្ដីឡើយ ដូច្នេះទ្រង់ក៏ប្រទានពរឲ្យនាងមានផ្ទៃពោះ។ តើយើងបានសិក្សាអំពីរ៉ាជែលវិញយ៉ាងដូចម្ដេចដែរ? ______________________________________________

______________________________________________

- នៅក្នុងខ ៣២ លេអា បានបង្កើតកូនប្រុសដំបូងគេឲ្យយ៉ាកុប។ តើពួកគេបានដាក់ឈ្មោះកូននោះថាដូចម្ដេច? តើឈ្មោះរបស់កូនប្រុសនោះមានអត្ថន័យដូចម្ដេច? (ចូរបំពេញទៅក្នុងតារាង)
  - o មានពាក្យមួយដែលបានប្រាប់លោកអ្នកថា លេអាមានសេចក្ដីស្កប់ចិត្តក្នុងជីវិតរបស់នាង តើពាក្យនោះថាដូចម្ដេច? ______________________________________________
  - o តើបំណងចិត្តមួយរបស់នាងលេអាគឺជាអ្វី? ______________________________
- នៅក្នុងខ ៣៣ បានប្រាប់ថា លេអាក៏មានផ្ទៃពោះម្ដងទៀត។ តើគេបានដាក់ឈ្មោះកូននោះថាដូចម្ដេច? ហើយឈ្មោះកូននោះមានអត្ថន័យដូចម្ដេចដែរ? (ចូរបំពេញទៅក្នុងតារាង)
  - o តើមានអ្វីដែលលេអាជឿថាគឺជាការពិត? ______________________________

    ______________________________________________

  - o នាងដឹងថាព្រះជាម្ចាស់ទ្រង់ស្ដាប់ការទូលអង្វររបស់នាង ហើយនាងជឿថាព្រះជាម្ចាស់ប្រាកដជានឹងប្រទានពរដល់នាងឲ្យមានកូនម្នាក់ទៀតជាមិនខាន ដ្បិតនាងមិនត្រូវបានទទួលសេចក្ដីស្រលាញ់ពីប្ដីរបស់នាងឡើយ។ តើមានអ្វីត្រូវបន្តទៅទៀតជាមួយនឹងសម្លេងយំសោកដ៏សែនក្តុកក្តួលរបស់នាង? ______________________________________________

    ______________________________________________

## មេរៀនទី ៥ - ផ្នែកទី ២

## លំហាត់បន្ថែម:

- នៅក្នុងខ ៣៤ បានឲ្យយើងដឹងថា លេអាបានបង្កើតកូនប្រុសលើកទី៣! តើកូនប្រុសទីបីនោះឈ្មោះអ្វី? តើឈ្មោះកូននោះមានអត្ថន័យដូចម្ដេច?
  - o ពេលនេះតើលេអាជឿថានឹងមានអ្វីកើតឡើង? ______________________________

    ______________________________________________

  - o លេអាមានបំណងចិត្តចង់ធ្វើជាមនុស្សសំខាន់ម្នាក់សម្រាប់ប្ដីរបស់នាង។ តើមានអ្វីបណ្ដាលឲ្យលោកអ្នកគិតថានាងមានអារម្មណ៍ទុកខ្លួនឯងដូចជាអ្នកបម្រើម្នាក់ដូច្នេះ? ______________

    ______________________________________________

- o នៅក្នុងខនេះតើមានអ្វីមកធ្វើឲ្យលេអាមានការឈឺចាប់? ________________________

________________________________________________

- នៅក្នុងខ ៣៥ តាមការសិក្សាបានយើងដឹងថា នាងមានផ្ទៃពោះម្តងទៀត ហើយបង្កើតបានកូនប្រុសម្នាក់ទៀត។ តើកូនប្រុសនោះឈ្មោះអ្វី? ហើយមានអត្ថន័យដូចម្តេច?
  - o លេអាបានរកឃើញលក្ខណៈសំខាន់នៅក្នុងជីវិតរបស់នាង។ តទៅនាងនឹងលែងជ្រើសរើសយកការលំបាកគ្រាំគ្រាចិត្ត ដោយគ្មានមុខមាត់ដូចពីមុនទៀតហើយ។ ________________

    ________________________________________________

  - o កាន់តែអស្ចារ្យជាងនេះទៅទៀតនោះគឺ នាងនឹងត្រូវមានផ្ទៃពោះបង្កើតកូនទីបួនទៀតផង។ __

    ________________________________________________

    ________________________________________________

  - o តើនៅចុងបញ្ចប់នៃខ ៣៥ បានប្រាប់យើងយ៉ាងដូចម្តេចខ្លះ? ____________________

    ________________________________________________

- ជាមួយគ្នានេះដែរ តើនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៣០:១ យើងបានសិក្សាអំពីរ៉ាជែលដូចម្តេចខ្លះ?

  ________________________________________________

  ________________________________________________

  - o រ៉ាជែលបានក្លាយទៅជា ________________________________ នឹងបងស្រីរបស់នាង។ តើមកពីមូលហេតុអ្វី? ______________________________________

    ________________________________________________

    ________________________________________________

  - o តើនាងបានទាមទារអ្វីពីយ៉ាកុប? __________________________________

    ________________________________________________

  - o នៅទីបំផុត រឿងនេះបានធ្វើឲ្យយ៉ាកុបមានការមិនសប្បាយចិត្ត ហើយមានកំហឹងយ៉ាងខ្លាំងផង

    ________________________________________________

    ________________________________________________

    គឺដូចជាលោកស្រី សារ៉ា ដែរ (លោកុប្បត្តិ ១៦:២) យ៉ាកុបនៅតែជឿថាព្រះជាម្ចាស់ មិនព្រមអនុញ្ញាត្តិមានផ្ទៃពោះបង្កើតកូនបានដដែល (លោកុប្បត្តិ ៣០:២)។

- o នៅក្នុងខ ៣ តើរ៉ាជែលបានប្រាប់យ៉ាកុបដូចម្តេច? ______________________________

______________________________________________

______________________________________________

រ៉ាជែលត្រូវរស់នៅក្នុងជីវិតមួយដែលមានតែភាពភ័យខ្លាច ហើយជាស្ត្រីប្រចណ្ឌច្រណែនម្នាក់ប៉ុណ្ណោះ! នាងមានការព្រួយបារម្ភខ្លាចក្រែងយ៉ាកុបដកសេចក្តីស្រលាញ់ពីខ្លួន ហើយបែរជាទៅស្រលាញ់បងស្រីរបស់នាងជាងវិញម្តង។ លេអាបង្កើតបានកូនប្រុសដល់ទៅបួននាក់សម្រាប់យ៉ាកុប នាងអស់សង្ឃឹមថានឹងអាចរក្សាសេចក្តីស្រលាញ់ឲ្យនៅស្ថិតស្ថេរទៀតបានឡើយ។

- នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៣០:៤-៦ បានប្រាប់ឲ្យយើងដឹងថា រ៉ាជែលបានបង្គាប់ឲ្យអ្នកបម្រើរបស់ខ្លួនគឺនាង ប៊ីលហា ទៅរួមដំណេកជាមួយនឹងយ៉ាកុបចាត់ថានាងគឺជាប្រពន្ធម្នាក់ដែរ។ រួចយ៉ាកុបក៏បានរួមដំណេកជាមួយនឹងអ្នកបម្រើនោះ ក្រោមមកនាងក៏ចាប់តាំងមានផ្ទៃពោះ លុះដល់វេលាកំណត់នាងក៏បង្កើតបានកូនប្រុសម្នាក់។ តើពួកគេបានដាក់ឈ្មោះកូនប្រុសនោះថាដូចម្តេច? ហើយឈ្មោះកូននោះមានអត្ថន័យដូចម្តេចដែរ?
  - o តើនរណាជាដាក់ឈ្មោះឲ្យកូនប្រុសម្នាក់នេះ? ______________________
  - o រំលឹកជាថ្មីម្តងទៀតថាអស់ស្ត្រីណាដែលគ្មានកូននោះឈ្មោះស្ត្រីអា នាងនោះនឹងត្រូវបានមនុស្សម្នាក្នុងតំបន់ និង អ្នកជិតខាងពេបជ្រាយឲ្យដោយការមាក់ងាយ។ បើដូច្នោះតើហេតុអ្វីបានជានាងត្រូវដាក់ឈ្មោះឲ្យកូននោះទៅវិញ?______________________

______________________________________________

______________________________________________

  - o រ៉ាជែលត្រូវបានរួចពីចំណងនេះ! គឺពេលនេះព្រះជាម្ចាស់បានប្រទានពរដល់នាង បង្កើតបានកូនប្រុសម្នាក់ តទៅនាងនឹងលែងមានអារម្មណ៍ថាខ្លួនមានកំហុស ដែលតម្រូវឲ្យព្រះជាម្ចាស់ដាក់ទោស មិនត្រឹមតែប៉ុណ្ណោះសោត នាងក៏ត្រូវបានរួចផុតពីការស្តីបន្ទោសទៀតផង។

## មេរៀនទី ៥ - ផ្នែកទី ៣

- យើងបានដឹងតាមរយៈការសិក្សាម្តងរួចមកហើយអំពី នាង ប៊ីលហា មានផ្ទៃពោះ ក្នុងខ ៧-៨! ក្រោយមក នាងបង្កើយបានកូនប្រុសមួយ តើកូននោះឈ្មោះអ្វី? តើឈ្មោះនោះមានន័យដូចម្តេច?
  - o គឺរ៉ាជែលគឺជាអ្នកដាក់ឈ្មោះឲ្យកូននោះដូចលើកមុនទៀត តើឈ្មោះកូនម្នាក់នេះលាតត្រដាងដូចម្តេចអំពីរ៉ាជែល? ______________________

______________________________________________

ការច្រណែនរបស់រ៉ាជែល បានជម្រុញឲ្យមានក្លាយទៅជាអ្នកប្រកួតប្រជែងជាមួយនឹងបងស្រី ខ្លួនឯង ព្រោះពេលនេះមានកូនប្រុសពីរនាក់ដោយអ្នកបម្រើស្រីរបស់នាង គឺនាង ប៊ីលហា។ រ៉ាជែលក៏ប្រកាសថាគឺនាងដែលជាអ្នកឈ្នះ!

- នៅក្នុងខ ៩-១១ លេអា លែងមានកូនតទៅទៀតហើយ! ដូច្នេះនាងក៏បង្គាប់ឲ្យអ្នកបម្រើរបស់នាងគឺ ស៊ីលផា ទៅរួមដំណេកជាមួយនឹងយ៉ាកុបជាប្តីរបស់ខ្លួន។ ក្រោយមកនាងក៏បានបង្កើតកូនប្រុសម្នាក់។ តើកូនប្រុសនោះមានឈ្មោះអ្វី? តើឈ្មោះនោះមានន័យដូចម្តេច?
  - o លេអាមានចិត្តសប្បាយរីករាយជាខ្លាំង ដោយនាងអាចមានកូនប្រុសម្នាក់ទៀតសម្រាប់យ៉ាកុបតាមរយៈអ្នកបម្រើរបស់ខ្លួនគឺនាង ស៊ីលផា។ នៅពេលនោះមានរឿងខ្លះត្រូវបានប្រែប្រួល។ តើមានអ្វីខ្លះដែលជាការឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនូវអត្តចរិតរបស់លេអា? ______________

    ____________________________________________________________

    ____________________________________________________________

- នាង ស៊ីលផា បានបង្កើតកូនប្រុសម្នាក់ឲ្យយ៉ាកុប តើកូននោះមានឈ្មោះអ្វី? តើឈ្មោះរបស់កូននោះមានអត្ថន័យដូចម្តេច?
  - o តើក្នុងពេលនេះអត្តចរិតរបស់លេអាបានឆ្លុះបញ្ចាំងយ៉ាងដូចម្តេចទៅដល់មនុស្សម្នាដែលរស់នៅក្នុងសហគមន៍ ឬ ភូមិជាមួយគ្នា? ______________________________________

    ____________________________________________________________

    ____________________________________________________________

តាមការពិតសេចក្តីភាគច្រើនដែលនាងមានគឺទទួលបានមកពីព្រះជាម្ចាស់ ហើយនាងមិនដែលធ្លាប់ទទួលសេចក្តីស្រលាញ់ពីយ៉ាកុបឡើយ។ ពេលនេះមិត្តភ័ក្រនឹងបានឃើញពីការឆ្លុះបញ្ចាំងរបស់នាងជាមិនខាន ______________________________________ ជាជាង ______________________________________។ ទុក្ខវេទនាដ៏សែនឈឺចាប់ពីការបែកបាក់គ្រួសារ និង មនុស្សដែលខ្លួនស្រលាញ់! មិត្តភ័ក្រដែលធ្លាប់តែផ្តល់សុភមង្គលឲ្យគ្នាទៅវិញទៅមក ក៏បែរជាមានរឿងឈ្លោះប្រកែកគ្នា និង ប្រកួតប្រជែញគ្នាដណ្តើមប្រជាប្រិយភាពពីអ្នកដទៃ។

- យើងសង្ឃឹមជឿជាក់ថា អ្វីៗទាំងអស់ដែលបានកើតឡើងរវាងបងប្អូនស្រីទាំងពីរ អ្នកបម្រើរបស់ពួកគេ និង យ៉ាងកុប បានល្អប្រសើរឡើងវិញទោះចុះ! នៅក្នុងខ ១៤-១៦ បានប្រាប់យើងឲ្យបានដឹងថា កូនប្រុសរបស់លេអាបានដាំដើមផ្លែស្នេហ៍ រួចហើយគេក៏បានយកមកឲ្យម្តាយរបស់គេ។ នៅពេលដែលរ៉ាជែលបានឃើញ នាងក៏សុំដើមនោះខ្លះ ប៉ុន្តែមកដល់ត្រង់ចំណុចនេះ យើងបានដឹង

ថាគឺមានជម្លោះមួយបានកើតឡើង ទើបធ្វើឲ្យយើងអាចសន្និដ្ឋានបានថា ទំនាស់រវាងបងប្អូនស្រីទាំងពីរនេះនៅមិនទាន់បានបញ្ចប់នៅឡើយទេ។ នៅក្នុងខ ១៥ តើលេអាបានឆ្លើយតបវិញយ៉ាងដូចម្ដេច? ____________________

____________________

នៅទីបញ្ចប់ លេអា ក៏បានប្រគត់ដើមផ្លែស្នេហ៍ខ្លះទៅឲ្យរ៉ាជែល ដើម្បីចង់បានឱកាសបានទៅ រួមដំណេកជាមួយនឹងយ៉ាកុបមួយយប់។

- នៅក្នុងខ ១៧-១៨ យើងបានសិក្សាអំពីព្រះជាម្ចាស់បានស្ដាប់ការទូលអង្វររបស់លេអា ហើយក៏បានប្រទានពរឲ្យនាងមានផ្ទៃពោះ បង្កើតបានកូនប្រុសទី ៥។ តើកូនទី ៥ នោះមានឈ្មោះអ្វី? ហើយមានន័យដូចម្ដេច?
  - o តើលេអាគិតថានាងនឹងសក្ដិសមត្រូវទទួលបានអ្វី? ____________________

    ____________________

    រង្វាន់ត្រូវបានសន្សំ ហើយនឹងត្រូវប្រគល់ទៅឲ្យអ្នកណាដែលសក្ដិសមនឹងទទួល! ក្នុងពេលនេះ តើលេអា អាចនឹងមានអារម្មណ៍ថា ស៊ីលផា ក៏ដូចជាប៊ីលហាដែរគឺបានបង្កើតកូនប្រុសឲ្យយ៉ាកុប?
- នៅក្នុងខ ១៩-២០ យើងបានដឹងថា លេអាបានបង្កើតកូនប្រុសទី ៦ ឲ្យយ៉ាកុប។ តើកូននោះមានឈ្មោះអ្វី? ហើយឈ្មោះនោះមានអត្ថន័យបែបណា?
  - o ពេលនេះយ៉ាកុបមានកូនប្រុសចំនួន 10 នាក់! ក្នុងនោះលេអាគឺអំណោយដ៏មានតម្លៃជាងគេ។ លេអាក៏លែងប្រាថ្នាចង់បានសេចក្ដីស្រលាញ់ពីប្ដីរបស់នាងទៀតហើយដែរ។ តើនឹងចង់គេប្រព្រឹត្តចំពោះយ៉ាងដូចម្ដេច? ____________________

    ____________________

    លេអាមានជំនឿចិត្តថា នាងបានបង្កើតកូនប្រុសដល់ទៅ ៦ នាក់សម្រាប់យ៉ាកុប ដូច្នេះនាង គឺសក្ដិសមនឹងត្រូវទទួលបានកិត្តិយស និង ការគោរពពីយ៉ាកុបជាប្ដីរបស់នាងណាស់។

## មេរៀនទី ៥ - ផ្នែកទី ៤

## លំហាត់បន្ថែម:

- នៅក្នុងខ ២១ បានប្រាប់យើងខ្លះៗទៀតថា ក្រោយពីនោះមក លេអាបង្កើតបានកូនស្រីម្នាក់ទៀត ឈ្មោះថា ឌីណា ទាំងនេះគឺជាកត់ត្រាទុកអំពីឧប្បត្តិហេតុដែលបានកើតឡើងនៅក្នុងគម្ពីរលោកុប្បត្តិ ជំពូក ៣៤ ហើយយើងនឹងមិនសិក្សាក្នុងជំពូកនេះទេ ហេតុដូច្នេះតម្រូវឲ្យលោកអ្នកអានរួចសិក្សាដោយខ្លួនឯង។
- ចុះចំណែករ៉ាជែលវិញ? នៅក្នុងខ ២២ ហាក់ដូចជាមានពាក្យខ្លះដែលបញ្ជាក់ថាព្រះជាម្ចាស់នៅ ចាំអំពីរ៉ាជែល។ ទ្រង់បានស្តាប់ឮការទូលអង្វររបស់ហើយ ទើបទ្រង់ប្រទានពរឲ្យនាងមានផ្ទៃពោះ រួចក៏បង្កើតបានកូនប្រុសម្នាក់។ តើកូនប្រុសរបស់រ៉ាជែលនោះមានឈ្មោះអ្វី? ហើយឈ្មោះនោះមានអត្ថន័យដូចម្តេច?
    - o នៅទីបំផុតនាងក៏មានផ្ទៃពោះ ព្រះជាម្ចាស់បានដកភាពអាម៉ាស់ចេញពីជីវិតរបស់នាង រួចនៅរំពេចនោះតើនាងបានទូលសូមអ្វីពីព្រះជាម្ចាស់? ______________________

      ______________________

      ______________________
- នៅក្នុងជំពូក ២៩ និង ៣០ គឺជាបញ្ជីរាយនាមកូនប្រុសទាំង ១១ នាក់របស់យ៉ាកុប ប៉ុន្តែ នៅមានកូនប្រុសម្នាក់ទៀតដែលត្រូវកើតមក។ ដើម្បីសិក្សាកូនប្រុសម្នាក់នេះ យើងចាំបាច់ត្រូវតែត្រឡប់ទៅ ព្រះគម្ពីរលោកុប្បត្តិ ៣៥:១៦-២០។
    - o យ៉ាកុបបានផ្លាស់ទីលំនៅពីបេតអែល គឺជាកន្លែងដែលគាត់បានសុបិន្ត និងជាកន្លែងដែលព្រះជាម្ចាស់បានបញ្ជាក់សេចក្តីសន្យារបស់ទ្រង់ឡើងវិញ កាលពីទ្រង់បានចងជាមួយនឹង អប្រាហាំ អ៊ីសាក់។ គឺពួកគេប្តូរពីបេតអែលទៅរស់នៅមិនឆ្ងាយពីអេប្រាតាប៉ុន្មាននោះទេ គឺនៅត្រង់ (ទីក្រុងបេថ្លេហិម) ហើយនៅក្នុងខ ១៦ តើមានអ្វីកើតឡើង? ______________________

      ______________________

      ______________________
    - o នៅក្នុងខ ១៧ ឆ្មបបានប្រាប់នាងថា នាងនឹងមានកូនប្រុសម្នាក់ទៀត រ៉ាជែលបានដាក់ឈ្មោះ កូនប្រុសម្នាក់នោះថា បេន-អូនី ក៏ប៉ុន្តែតើឪពុកបានដាក់ឈ្មោះកូនប្រុសនោះដូចម្តេច? ហើយវាមានន័យដូចម្តេច? ______________________ បន្ទាប់មករ៉ាជែល បានស្លាប់ក្នុងពេលសម្រាលកូនទៅ។

- ព្រះជាម្ចាស់បានព្រមតាមការទូលសូមរបស់រ៉ាជែល (លោកុប្បត្តិ ៣០:២៤) ហើយប្រទានពរឲ្យនាងមានកូនប្រុសម្នាក់ទៀត។

- យ៉ាកុបបានឃើញថា រ៉ាជែលគឺជាដៃស្តាំរបស់គាត់ ម្យ៉ាងគឺជាប្រពន្ធសំណព្វចិត្តរបស់គាត់ទៀតផង តែមកដល់ពេលនេះគាត់ត្រូវបញ្ចុះសព្វនាងដោយដៃគាត់ផ្ទាល់។ រ៉ាជែលបានស្លាប់ទៅមុនពេលយ៉ាកុបផ្លាស់ទីលំនៅវិលត្រឡប់ទៅផ្ទះឪពុកគាត់វិញ (ក្នុងខ ២១)។ តាមរយៈខ ២៨ បានប្រាប់យើងឲ្យបានដឹងថានៅពេលដែលអ៊ីសាក់ទទួលមរណៈភាពគឺគាត់មានអាយុ ១៨០ ឆ្នាំ។ ហើយកូនប្រុសទាំងពីររបស់គាត់ (អេសាវ និង យ៉ាកុប) គឺជាអ្នកបញ្ចុះសព្វរបស់គាត់ (ក្នុងខ ២៩)។

## ការឆ្លុះបញ្ចាំងៈ

ពេលយើងមកដល់ត្រឹមនេះ មានគំនិត និង យោបល់ជាច្រើនតម្រូវឲ្យយើងធ្វើការពិចារណាក្នុងអំឡុងពេលកំពុងសិក្សាមេរៀនក្នុងផ្នែកនៃព្រះគម្ពីរលោកុប្បត្តិនេះ។ ទស្សនៈផ្ទាល់ខ្លួន សំនួរ អារម្មណ៍ ទាំងអស់នេះត្រូវបានលើកឡើងក្នុងឱកាសពិភាក្សាគ្នាខណៈពេលមេរៀនកំពុងបន្ត។ ចំពោះសំនួរទាំងឡាយដែលគ្មានចម្លើយចូរទុកវានៅក្នុងគំនិតសិន ដ្បិតយើងមានព្រះបន្ទូលព្រះជាម្ចាស់បានកត់ត្រាទុលមកនេះប៉ុណ្ណោះ ដែលជាប់ទាក់ទងគ្នារវាងសេចក្តីពិត និង មនុស្សទាំងអស់។ នៅក្នុងមេរៀននេះ យើងមិនចាំបាច់ត្រូវពិចារណាលើគ្រប់ចំណុចទាំងអស់នោះទេ សារៈសំខាន់នៅក្នុងការសិក្សារបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានពត៌មាន និង ចំណេះដឹងផ្សេងៗសម្រាប់ទទួលយក ដើម្បីឲ្យបានយល់កាន់តែស៊ីជម្រៅជាងមុន ថាព្រះជាម្ចាស់ទ្រង់គឺជានរណា ហើយទ្រង់មានបំណងព្រះហឫទ័យចង់ឲ្យគ្រប់ៗគ្នាបានរស់នៅជាមួយទ្រង់រហូតអស់កល្បជានិច្ច ដោយមានទំនាក់ទំនងនៃសេចក្តីស្រលាញ់ និង ការអត់ទោសបាប។

ចូរចំណាយពេលវេលាខ្លះ ដើម្បីកត់ត្រាទុកនូវគំនិតឆ្លុះបញ្ចាំងរបស់លោកអ្នកតាមរយៈសាច់រឿងនេះ។ តើលោកអ្នកនឹងមានសំនួរបែបណាខ្លះសម្រាប់សួរទៅតួអង្គទាំងអស់ដូចខាងក្រោមនេះ?

- យ៉ាកុប: ____________________________________________

____________________________________________

____________________________________________

- លេអា: ____________________________________________

____________________________________________

____________________________________________

- ស៊ីលផា: ____________________________________________

____________________________________________

____________________________________________

- រ៉ាជែល: ____________________

____________________

____________________

- ប៊ីលហា: ____________________

____________________

____________________

សាច់រឿងទាំងឡាយដែលទាក់ទងនឹងលោក អប្រាហាំ អ៊ីសាក់ និង យ៉ាកុប មាននៅក្នុងព្រះគម្ពីរលោកុប្បត្តិ ឬ ហើយ ដើមកំណើត វាគឺជាការចាប់ផ្ដើមនៃប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល។ ចំពោះសាច់រឿងដាច់ដោយឡែកផ្សេងទៀត គឺអស់អ្នកដែលព្រះជាម្ចាស់បានប្រទានពរដោយសេចក្ដីស្រលាញ់ និងត្រូវបានប្រទានឲ្យពួកយើងទុកជាការធានាអះអាង អំពីសេចក្ដីសន្យារបស់ព្រះជាម្ចាស់ដែលទ្រង់បានចងកាលនៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ១២ ត្រូវបានសម្រេចហើយ។ ដោយយោងទៅតាមប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល គឺព្រះជាម្ចាស់ទ្រង់បានគោរពតាមសម្ព័ន្ធមេត្រីនៃសេចក្ដីសន្យាថា តាមរយៈជាតិសាសន៍មួយ គ្រប់ទាំងមនុស្សនៅលើផែនដីនឹងត្រូវបានទទួលព្រះពរដែរ។

## មេរៀនទី ៥ - ផ្នែកទី ៥

## សេចក្ដីបង្រៀន:

កាលនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៣០:១ តាមរយៈការសិក្សាបានឲ្យយើងដឹងថា រ៉ាជែលមានចិត្តច្រណែននឹងបងស្រីរបស់ខ្លួនឯង តែយ៉ាងណាក៏ដោយរ៉ាជែលនៅតែប្រពន្ធសំណព្វចិត្តរបស់យ៉ាកុបដដែល។ នៅក្នុងលោកុប្បត្តិ ២៩:៣០ បានប្រាប់ឲ្យយើងដឹងថាយ៉ាកុបមានចិត្តស្រលាញ់រ៉ាជែលជាងលេអា។ តើមានហេតុអ្វីដែលធ្វើនាងច្រណែននឹងបងស្រីរបស់នាង បើបងស្រីនោះមិនទាំងបានទទួលក្ដីស្រលាញ់ពីប្ដីផងនោះ? តើមានហេតុផលអ្វីដែលបណ្ដាលឲ្យរ៉ាជែលច្រណែននឹងលេអា បើគ្រាន់តែ លេអា អាចបង្កើតកូនបែបនេះ? បន្ទាប់ពីអ្វីៗទាំងអស់បានកន្លងផុតទៅ តើរ៉ាជែលមិនមែនជាអ្នកដែលយ៉ាកុបស្រលាញ់ទេឬអី?

យើងត្រូវតែស្វែងយល់ឲ្យបានច្បាស់អំពីពាក្យថា ច្រណែន! ភាពច្រណែនគឺជាការភ័យខ្លាចថាមានអ្វីមួយត្រូវបានមកជំនួស។ ភាពភ័យខ្លាចរបស់រ៉ាជែល គឺនាងខ្លាចយ៉ាកុបស្រលាញ់លេអាច្រើនជាងស្រលាញ់នាង។ រ៉ាជែលមានសេចក្ដីភ័យខ្លាចថាលេអាបងស្រីរបស់នាងចូលទៅជំនួសកន្លែងនៅក្នុងបេះដូងរបស់យ៉ាកុប និងទទួលគ្រងអ្វីៗដែលជារបស់នាង។ ភាពច្រណែនឈ្នានីស គឺជាបំផ្លាញនូវទំនាក់ទំនង ដ្បិតវាគឺជាឫសគល់នៃសេចក្ដីភ័យខ្លាច។ នៅពេលណាយើងប្រព្រឹត្តការអ្វីមួយយដោយសេចក្ដីភ័យខ្លាច នោះគំនិតរបស់យើង និង

ត្រូវបានខូចទ្រង់ទ្រាយ ហើយបែរជាប្រព្រឹត្តទង្វើណាមួយដោយមិនបានគិតច្បាស់លាស់។ រ៉ាជែលមានភាពភ័យខ្លាច ក៏ព្រោះតែលេអាបានបង្កើតកូនប្រុសដល់ទៅ ៦ នាក់ដូច្នេះហើយខ្លាចក្រែងយ៉ាកុបដកយកក្ដីស្រលាញ់ពីនាងយកទៅឲ្យលេអាជំនួសវិញ។

## ការអនុវត្តន៍ផ្ទាល់ខ្លួន៖

- តើនៅក្នុងជីវិតរបស់លោកអ្នកធ្លាប់មានបទពិសោធន៏មានការច្រណែនពីនរណាម្នាក់ដែរឬទេ? ចូររំលឹកឡើងវិញអំពីតួអង្គថានរណា ហើយស្ថិតនៅក្នុងស្ថានភាពបែបណា។ ______________________________

- តើអ្វីទៅដែលជាសេចក្តីភ័យខ្លាច? តើសេចក្តីភ័យខ្លាចសម្តែងដើម្បីឲ្យបានជំនួសយ៉ាងដូចម្តេច? តើអ្វីទៅដែលជាលទ្ធផលនៃការច្រណែន? ______________________________

- តើលោកអ្នកមានអ្វីតម្រូវឲ្យសារភាពអំពីភាពច្រណែនឈ្នានីសនៅក្នុងចិត្តដែរឬទេ? តើបុគ្គលណាមួយដែលជាបុព្វហេតុធ្វើឲ្យភាពច្រណែនឈ្នានីសចូលមកក្នុងគំនិត និង សកម្មភាពរបស់បង។ ______________________________

- នៅពេលណាដែលលោកអ្នកមានចិត្តច្រណែនចំពោះប្តី ឬ ប្រពន្ធរបស់លោកអ្នក ច្រណែននឹងមិត្តភ័ក្រ ឬ ដៃគូរជំនួញ? តើលោកអ្នកធ្លាប់មានអារម្មណ៍ភ័យខ្លាចត្រូវមានអ្នកផ្សេងចូលមកជំនួសមុខតំណែង ទំនាក់ទំនងស្នេហា ឬថាលោកអ្នកកំពុងឈរនៅក្នុងក្រុមហ៊ុនមួយដែលបានប្រទះនឹងហានិភ័យដែរឬទេ? តើលោកអ្នកមានភ័យខ្លាចការហួសសុពលភាពរបស់លោកអ្នកដែរឬទេ? ______________________________

- ជាមនុស្សច្រណែនត្រូវបានគំរាមកំហែងដោយ ការទទួលបានជោគជ័យរបស់អ្នកដទៃដោយចំណងមិត្តភាពរបស់អ្នកដទៃដោយលាភសក្ការៈសង្គមនៃអ្នកដទៃ។ ក្នុងការយល់ឃើញរបស់ពួកគេអំពីសមត្ថភាពរបស់ខ្លួនក្នុងការសម្តែងផងដែរ ដូចជាមនុស្សម្នាក់ផ្សេងទៀតបានបង្កើនគំនិតនៃការសង្ស័យ និង ការភ័យខ្លាច។ អារម្មណ៍នៃភាពមិនពេញលេញទាំងនេះរារាំងពួកគេពីការលើកទឹកចិត្តដល់អ្នកដទៃ ហើយក៏ផ្តល់នូវពាក្យណាដែលបណ្តាលឱ្យមានទំនុកចិត្ត និង ចរិតលក្ខណៈនៅក្នុងមនុស្សម្នាក់ផ្សេងទៀត។ នៅពេលដែលបានក្លាយទៅជាពេលវេលាមួយ ដែលអ្នកអាចរកឃើញដោយខ្លួនឯងថាពាក្យសម្តីនៃការអះអាង និង ការលើកទឹកដោយសារតែការច្រណែន? ______________________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ទូលបង្គំត្រូវការលន់តួនៅចំពោះទ្រង់ ថាទូលបង្គំពិតជាមានការភ័យខ្លាចនឹងសមត្ថភាព និង ទេពកោសល្យរបស់អ្នកដទៃមែន។ ទូលបង្គំភ័យខ្លាចត្រូវបាត់បង់ការងារ ជាការកសាងនរណាម្នាក់ ដែលទូលបង្គំបានរកឃើញដោយខ្លួនឯងសម្រាប់វិធីសាស្ត្រក្នុងការបំផ្លាញពួកគេទៅវិញ។ ទូលព្រះបង្គំបាននិយាយអំពីអ្នកដទៃនៅក្រោយខ្នងពួកគេ! ដោយសង្ឃឹមថានឹងបានធ្វើខ្លួនឯងបានកាន់តែប្រសើរជាងអ្នកដទៃ តែផ្ទុយទៅវិញនោះអ្វីៗទាំងប៉ុន្មានបានត្រឹមតែធ្វើឲ្យទូលបង្គំត្រូវទទួលការឈឺចាប់ប៉ុណ្ណោះ។ សូមទ្រង់អស់ទោសដល់ស្ទូលចិត្តរបស់ទូលបង្គំផង ក៏ដូចជាការគិត អកប្បកិរិយា ហើយជួយដល់ទូលបង្គំឲ្យមានសេរីភាពពីជិតផ្ទាល់ខ្លួនឯង ឈ្លោះទៅរកធមេ្យាបាយយ៉ាងណាដើម្បីអាចធ្វើជាទីបញ្ចេញព្រះពរដល់អ្នកដៃដោយគំនិតសប្បុរស ពាក្យសម្ដីប្រកបដោយការលើកទឹកចិត្ត និង ការប្រព្រឹត្តប្រកបដោយក្ដីស្រលាញ់។ សូមអរព្រះគុណដល់ទ្រង់ សម្រាប់ព្រះពរក្នុងជីវិតទូលបង្គំគឺអ្វីៗសុទ្ធតែល្អទាំងអស់។ ______________

______________________________________________

______________________________________________

______________________________________________

# មេរៀនទី ៦

## មេរៀនទី ៦ - ផ្នែកទី ១

### សេចក្តីណែនាំ:

ដូច្នេះ តើមានអ្វីកើតឡើងចំពោះអេសាវ? តើគាត់បានត្រូវបានបាត់ខ្លួនតែម្តងមែនទេ? តើមានអ្វីខ្លះកើតឡើងរវាងអេសាវ និង យ៉ាកុប? បងប្អូនភ្លោះទាំងពីរ នៅទីបំផុតពួកគេមានលក្ខណៈខុសប្លែកពីគ្នា ទាំង អត្តចរិត និង ទឹកចិត្ត។ ទំនាក់ទំនងរវាងពួកគេទាំងចេះតែអាក្រក់បន្តិចម្តងៗ រហូតមកដល់ចំណុចមួយតម្រូវឲ្យយ៉ាងរត់គេចពីការតាមសម្លាប់របស់អេសាវជាបង។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីការជួបគ្នាឡើងវិញបន្ទាប់បានបែកគ្នាអស់រយៈពេលជាច្រើនឆ្នាំ។ យ៉ាកុបមានទ្រព្យសម្បត្តិយ៉ាងស្តុកស្តម! គាត់បានទទួលព្រះនូវគ្រួសារមួយយ៉ាងធំ និង ទ្រព្យសម្បត្តិយ៉ាងស្តុកស្តម។ ឥឡូវនេះគឺជាពេលវេលាដែលគាត់ត្រូវទៅជួបមុខអេសាវជាបងប្រុសរបស់គាត់! តើអេសាវនៅតែមានចិត្តចងគំនុំ រកសម្លាប់យ៉ាកុបប្អូនប្រុសរបស់គាត់ទៀតដែរទេ? នេះគឺជាអ្វីដែលយ៉ាកុបចង់ដឹង!

### កិច្ចការ:

ចូរអានព្រះគម្ពីរលោកុប្បត្តិ ៣២:៣-២១! សូមចំណាំ! នៅក្នុងមេរៀននេះ ត្រូវចំណាយថវិការច្រើនក្នុងការទិញសំភារៈសិក្សា ដើម្បីឲ្យការសិក្សារបស់លោកអ្នកមានភាពស៊ីជម្រៅ និង លំអិតច្បាស់លាស់។

**លំហាត់:** យ៉ាកុបផ្តើមគំនិតដើម្បីនឹងចុះកិច្ចសន្យាជាមួយនឹងបងប្រុសរបស់គាត់។

- នៅក្នុងខ ៣ តើយ៉ាកុបបានធ្វើអ្វីដំបូងគេ? ____________________

  ____________________
- តើអេសាវនៅឯណា? ____________________

  ចូរចំណាយពេលវេលាខ្លះដើម្បីពិនិត្យមើលផែនទី និង ទីតាំងនៃក្រុង អេដុម។ នេះគឺចង់សំដៅទៅលើទឹកដីតំបន់ ស៊ើរ! ក្រុង អេដុម គឺជាទឹកដីស្ថិតនៅប៉ែកខាងត្បូងនៃសមុទ្រស្លាប់ ឬ សមុទ្រប្រៃ។
- តើចំណុចបីយ៉ាងដែលគាត់ចង់ដាក់បញ្ចូលនៅក្នុងសារសម្រាប់បងប្រុសរបស់គាត់មានអ្វីខ្លះ?

  ១. ____________________

  ២. ____________________

  ៣. ____________________

យ៉ាកុបចង់ឲ្យអេសាវបានដឹងថាគាត់នៅឯណា! នោះគាត់នឹងបានទទួលយកទ្រព្យសម្បត្តិ និង ក្តីបំណងចង់បានការពេញចិត្តពីគាត់។ យ៉ាកុប ចង់បង្ហាញឲ្យឃើញថា គាត់នឹងអាចទិញទឹកចិត្តបងប្រុសរបស់គាត់ ហើយចង់ឲ្យគាត់ដឹងថាទំនាក់ទំនងជាមួយនឹងអេសាវវាសំខាន់ជាងទ្រព្យសម្បត្តិ។

- នៅក្នុងខ ៦ តើអ្នកនាំសារបានរាយការណ៍ប្រាប់យ៉ាកុបវិញយ៉ាងដូចម្តេច? ______________

______________________________________________

______________________________________________

- នៅក្នុងខ ៧-៨ តើយ៉ាកុបមានប្រតិកម្មដូចម្តេចនៅពេលគាត់បានទទួលរបាយការណ៍? _______

______________________________________________

______________________________________________

តើគាត់មានផែនការណ៍សកម្មភាពជាបន្ទាន់យ៉ាងដូចម្តេច? ______________________

______________________________________________

______________________________________________

- យ៉ាកុបបានអធិស្ឋានទៅព្រះជាម្ចាស់។ នៅក្នុងខ ៩-១២ តើនៅក្នុងសេចក្តីអធិស្ឋានរបស់គាត់មានចំណុចសំខាន់បែបណាខ្លះ? ចូរពិចារណាលើបួនចំណុចធំៗ

១. តើព្រះជាម្ចាស់គឺជានរណា? (ខ៩) ______________________________

______________________________________________

២. តើគាត់គឺជានរណា? (ខ១០) ________________________________

______________________________________________

៣. តើគាត់បានទូលសូមអ្វី? (ខ១១) ______________________________

______________________________________________

៤. តើព្រះជាម្ចាស់បានសន្យាដូចម្តេច? (ខ១២) ______________________

______________________________________________

- ផែនការណ៍របស់យ៉ាកុបគឺចង់លាតត្រដាងអំពីភាពភ័យខ្លាចរបស់ចំពោះបងប្រុស ជាជាងធ្វើជាអ្នកដឹកនាំគ្រួសារ មនុស្សនៅក្នុងគ្រួសារ និង ហ្វូងសត្វ។ តើគាត់បានធ្វើអ្វី? ______________

______________________________________________

គាត់បានបែងចែកគ្រួសារ និង ទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់គាត់ជាពីរចំណែក រួចគាត់ជ្រើសរើសយកមួយចំណែកដើម្បីទុកជាអំណោយសម្រាប់អេសាវ។ តើអំណោយនោះគឺជាអ្វី? (ខ ១៤-១៥) តើតាមការពិតយ៉ាកុបបានជ្រើសរើសយកអ្វី?

ពពែ ____________________ ចៀម ________________________

អូដ្ឋ ____________________ គោ ________________________

លា ____________________

នៅក្នុងខ ១៦ តើនរណាគឺជាអ្នកដឹកនាំទ្រព្យសម្បត្តិទាំងនេះ? ____________________

- នៅក្នុងខ ១៧-២០ តើអ្នកបម្រើបានទទួលការណែនាំដូចម្តេច នៅពេលគេបានជួបអេសាវ? ___

________________________________________________

________________________________________________

________________________________________________

- នៅក្នុងខ ២០ បានលាតត្រដាងអំពីចេតនារបស់យ៉ាកុប។ តើគាត់បានគិតដូចម្តេច? ________

________________________________________________

អំណោយបាននាំមុខដំណើរយ៉ាកុបដែលហែរហមជាមួយនឹងអ្នកប្រើរបស់គាត់។ យ៉ាកុបបាននៅពីក្រោយ ហើយបានស្នាក់នៅក្នុងជំរុំអស់មួយយប់។

## មេរៀនទី ៦ - ផ្នែកទី ២

## ការឆ្លុះបញ្ចាំង:

ភាពជាអ្នកដឹកនាំ គឺត្រូវដឹកនាំ! ភាពជាអ្នកដឹកនាំ គឺត្រូវមានអ្នកដើរតាម! យ៉ាកុបគឺជាមេដឹកនាំ ឬ ជាចៅហ្វាយលើត្រកូលរបស់គាត់។ គាត់ត្រូវទៅជួបជាមួយនឹងបងប្រុសរបស់គាត់ និង មនុស្ស ៤០០ នាក់ទៀតដែលបានមកជាមួយនឹងគាត់។ តើគាត់បានចាត់នរណាឲ្យដឹកនាំទ្រព្យសម្បត្តិទាំងអស់នោះ? គឺអ្នកបម្រើរបស់គាត់! ពួកគេទាំងនោះបាននាំយកអំណោយទៅ ដោយយ៉ាកុបបានគិតថា អំណោយទាំងនោះនឹងអាចនាំមកនូវសុខសន្តិភាពជាមួយនឹងបងប្រុសរបស់គាត់ជាថ្មីឡើងវិញ។ ក្នុងពេលនេះ លោកអ្នកត្រូវបានគេចាត់បញ្ជូនឲ្យទៅក្នុងនាមជាអ្នកយកពត៌មានសម្រាប់ស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកមួយ ដើម្បីឲ្យទៅយកសារពត៌មានពីព្រឹត្តិការណ៍នៃជំនួបបងប្អូនប្រុសទាំងពីរនាក់នោះ។ តើលោកអ្នកនឹងមានសំនួរបែបណាសម្រាប់សួរទៅយ៉ាកុប? សំនួរបែបណាសម្រាប់សួរទៅ រ៉ាជែល និង លេអា? បើតាមទស្សនៈរបស់លោកអ្នកផ្ទាល់ តើលោកអ្នកគិតថានឹងត្រូវបរិយាយអំពីតួអង្គយ៉ាកុបដូចម្តេច? ____________________

________________________________________________

________________________________________________

________________________________________________

________________________________________________

តើអ្វីខ្លះដែលជារបាយការណ៍សង្កេតរបស់លោកអ្នក? ______________________________

____________________________________________________________

____________________________________________________________

____________________________________________________________

## ការអនុវត្តន៍ផ្ទាល់ខ្លួន:

ចូររំលឹកឡើងវិញ អំពីស្ថានភាពមួយដែលលោកអ្នកមានមុខងារមួយក្នុងភាពជាអ្នកដឹកនាំ ប៉ុន្តែលោកអ្នកបានទទួលស្គាល់ថាវាមានការលំបាកក្នុងការដឹកនាំ។ តើមានសេចក្តីភ័យខ្លាច និង ការខ្វល់ខ្វាយបែបណាខ្លះដែលមានការប៉ះពាល់ដល់ភាពជាអ្នកដឹកនាំរបស់លោកអ្នកចំពោះស្ថានភាពជាក់លាក់ណាមួយ? ______

____________________________________________________________

____________________________________________________________

____________________________________________________________

មានគំរូបរាជ័យក្នុងការដឹកនាំមួយក្នុងពេលដែលមានមុខដំណែងជាអ្នកដឹកនាំ។ មានពេលខ្លះ ឪពុកម្តាយមានការស្ទាក់ស្ទើរក្នុងការទទួលយកតួនាទីជាអ្នកដឹកនាំ។ កូនចៅត្រូវតែមើលការខុសត្រូវពួកគេដោយការណែនាំ និង ការចង្អុលបង្ហាញ ពួកគេចង់បានការណែនាំពីឪពុកម្តាយរបស់ខ្លួន ដើម្បីនឹងផ្តល់នូវព្រំដែនដែលនៅក្នុងនោះពួកគេអាចធ្វើប្រតិបត្តិការបាន និង បញ្ចូលជាគំរូសម្រាប់ពួកគេទទួលយកបាន។ បើសិនជាឪពុកម្តាយណា មិនបានដឹកនាំ ឬ បរាជ័យក្នុងការឈរឲ្យបានរឹងមាំក្នុងតួនាទីជាអ្នកដឹកនាំនៅក្នុងផ្ទះ នោះពួកគេនឹងបាត់បង់ឱកាស ដើម្បីមានឥទ្ធិពលទៅលើកូនចៅរបស់ពួកគេក្នុងផ្លូវវិជ្ជមានហើយ។ ជាទូទៅក្មេងៗចាប់ផ្តើមធ្វើការសម្រេចចិត្តដោយខ្លួនឯង ដោយគ្មានការចង្អុលបង្ហាញពីឪពុកម្តាយ បើដូច្នោះ គឺពិតជានឹងកើតមានការប៉ះទង្គិចគ្នា ហើយជាលទ្ធផលនឹងទទួលបាននូវការប្រឆាំងតបវិញទាំងងងើរព្រោះតែការដែលមិនស្តាប់បង្គាប់។

ចូរពិចារណាអំពីគំរូរបស់អ្នកដឹកនាំផ្សេងៗទៀត ដែលលោកអ្នកធ្លាប់បានជួបប្រទះ ហើយបានកត់ត្រាទុកក្នុងសៀវភៅរបស់លោកអ្នក។ តើអ្វីទៅដែលជាព្រះពរពីការដឹកនាំយ៉ាងរឹងមាំ? តើភាពជាអ្នកដឹកនាំត្រូវបានបរាជ័យតើជាលទ្ធផលនឹងត្រូវទទួលបានអ្វីខ្លះ?

**កិច្ចការ:** ចូរអានបន្តនៅត្រង់ព្រះគម្ពីរលោកុប្បត្តិ ៣២:២២-៣២!

## សេចក្ដីបង្រៀនៈ

យ៉ាកុបបាននាំប្រពន្ធទាំងពីរ ពួកអ្នកបម្រើ និង កូនៗរបស់គាត់ឆ្លងកាត់ស្ទឹង យ៉ាបុក។ ស្ទឹងនេះក៏អាចរកឃើញនៅក្នុងផែនទីផ្នែកខាងក្រោយនៃព្រះគម្ពីររបស់លោកអ្នក ដែលបង្ហាញអំពីទឹកដីនៃកុលសម្ព័ន្ធទាំង ១២។ ស្ទឹងយ៉ាបុក គឺមានទីតាំងនៅចន្លោះរវាងសមុទ្រកាលីឡេ (សមុទ្រគីណារ៉េត) និង សមុទ្រស្លាប់ (សមុទ្រប្រៃ ឬអំបិល) ស្ទឹងនេះប្រហែលពាក់កណ្ដាលរវាងដងសមុទ្រទាំងនេ និង ទន្លេយ័រដាន់ភាគខាងកើត។ យ៉ាកុបបានចេញដំណើរពីស្រុក ហារ៉ាន ឈ្ពោះសំដៅទៅទិសខាងជើង រួចក៏វិលត្រឡប់មកដល់ភាគខាងត្បូងនៃបៀរសេបា។ ចំណែកឯអេសាវិញគាត់មកពីតំបន់ សៀរ ឬ អេដុម ដែលមានទីតាំងនៅប៉ែកខាងត្បូងនៃសមុទ្រស្លាប់។

## លំហាត់ៈ

បន្ទាប់ពីយ៉ាកុប បាននាំក្រុមគ្រួសាររបស់គាត់ និង បញ្ជូនទ្រព្យសម្បត្តិទាំងអស់ឆ្លងកាត់ស្ទឹង យ៉ាបុក រួចរាល់ហើយ គាត់បាននៅក្រោយតែម្នាក់ឯងរយៈពេលមួយយប់ទៀត (លោកុប្បត្តិ ៣២:២២-២៤)។

- នៅក្នុងខ ២៤-២៦ តើនៅយប់នោះមានអ្វីបានកើតឡើង? ____________________

  ____________________

  ____________________

- តាមបទគម្ពីរបានប្រាប់យើងថា បុរសម្នាក់ដែលបានបោកចំបាប់ជាមួយយ៉ាកុបនៅយប់នៅ គឺជាព្រះជាម្ចាស់។ យ៉ាកុបបញ្ចេញនៅកម្លាំងដ៏អស្ចារ្យ រហូតធ្វើឲ្យបុរសម្នាក់នោះមិនអាចយកឈ្នះលើរូបគាត់បាន។ នៅក្នុងខ ២៥ តើបុរសម្នាក់នោះបានធ្វើអ្វី? ____________________

  ____________________

- យ៉ាកុបបានស្ថិតនៅក្នុស្ថាភាពមួយដ៏អស់សង្ឃឹម បងប្រុសរបស់គាត់បានមកតាមក្រោយ។ នៅក្នុងខ ២៦ តើគាត់បានទូលសូមអ្វីពីព្រះជាម្ចាស់? ____________________

  ____________________

- បុរសម្នាក់នោះបានឆ្លើយតបទៅយ៉ាកុបដោយសួរថា តើគាត់ឈ្មោះអ្វី នៅខណៈនោះបុរសរូបនោះបានប្រាប់ទៅគាត់វិញយ៉ាកុបនឹងមិនមែនជាឈ្មោះរបស់អ្នកតទៅទៀតហើយ ប៉ុន្តែតើគាត់មានឈ្មោះថ្មីដូចម្ដេច? ____________________

  ____________________

  តើឈ្មោះថ្មីរបស់គាត់មានសារៈសំខាន់បែបណា? ____________________

  ____________________

- នៅក្នុងខ ២៩ យើងបានសិក្សាអំពីព្រះជាម្ចាស់បានប្រទានពរដល់យ៉ាកុប។ យ៉ាកុបដាក់ឈ្មោះឲ្យទីកន្លែងនោះ ________________________________________
តើឈ្មោះនៃទីកន្លែងនោះមានអត្ថន័យដូចម្តេច? ________________________________
____________________________________________________________
____________________________________________________________

- តើរឿងមួយដែលគួរឲ្យចាប់អារម្មណ៍អំពីយ៉ាកុបគឺជាអ្វី និង ការអនុវត្តន៍របស់រាស្ត្រអ៊ីស្រាអែល?
____________________________________________________________
____________________________________________________________
____________________________________________________________
____________________________________________________________

## មេរៀនទី ៦ - ផ្នែកទី ៣

## សេចក្តីបង្រៀន:

ព្រះជាម្ចាស់បានប្តូរឈ្មោះថាយ៉ាកុបទៅជា អ៊ីស្រាអែល វិញម្តង។ កាលពីច្រើនឆ្នាំកន្លងមកព្រះជាម្ចាស់ធ្លាប់បានប្តូរឈ្មោះពី អាប់រ៉ាម ទៅជា អប្រាហាំ និង ពីសារ៉ាយ ទៅជា សារ៉ា។ មានសេចក្តីជំនឿមួយបានទទួលស្គាល់ថាកាលណានរណាម្នាក់ត្រូវបានផ្លាស់ប្តូរឈ្មោះ នោះមានន័យថាអ្នកនោះនឹងមានអំណាចលើបុគ្គលនោះ ឬវត្ថុនោះដែលបានដាក់ឈ្មោះថ្មី។ ជាឧទាហរណ៍ស្រាប់ ចូរយើងរំលឹកទៅព្រះគម្ពីរលោកុប្បត្តិជំពូក ២ ដែលមានម្តងនោះលោក អាប់រ៉ាម បានដាក់ឈ្មោះឲ្យសត្វរបស់គាត់។ គាត់បានប្រគល់នូវការទទួលខុសត្រូវ និង អំណាចគ្រប់គ្រងលើពួកគេទាំងនោះ។

ព្រះជាម្ចាស់បានយាងមកឯយ៉ាកុបរបៀបមួយដ៏អស្ចារ្យ! លោកយ៉ាកុប បានទទួលព្រះពរពីព្រះជាម្ចាស់។ ព្រះជាម្ចាស់បានសួរឈ្មោះយ៉ាកុប នៅខណៈនោះទ្រង់មានព្រះបន្ទូលប្រាប់ទៅយ៉ាកុបថាត្រូវប្តូរឈ្មោះហៅថាអ៊ីស្រាអែលវិញម្តង។ ការប្តូរឈ្មោះថ្មីរបស់ព្រះជាម្ចាស់ចំពោះយ៉ាកុប គឺជាការប្រទាននូវអំណាច ឬ ច្បាប់គ្រប់គ្រងលើជីវិតរបស់គាត់ ដែលត្រូវស្ថិតនៅក្រោមភាពជាម្ចាស់ថ្មី និង ការគ្រង់គ្រង់ថ្មី។ ព្រះជាម្ចាស់ គឺជាអ្នកចងសម្ព័ន្ធមេត្រីជាមួយនឹងលោក អប្រាហាំ និង អ៊ីសាក់ ដែលកាលនោះគឺជាមនុស្សប្រកបដោយ សេចក្តីសប្បុរសអស់ពេញមួយជីវិតរបស់គាត់ ហើយថែមទាំងប្រកាសថាគាត់គឺជារាស្ត្ររបស់ទ្រង់ផង។ តែទោះបីជាយ៉ាងណា យ៉ាកុបត្រូវបានទទួលព្រះពរពីព្រះជាម្ចាស់យ៉ាងបរិបូរណ៍។

## ការអនុវត្តន៍ផ្ទាល់ខ្លួនៈ

នៅក្នុងសម័យកាលមួយដ៏ទំនើបបែបសព្វថ្ងៃនេះ វាមិនមែនជាការលំបាកក្នុងការមើលឃើញនូវស្ថានភាពប្រហាក់ប្រហែលនោះទេ។ ចូរពិចារណាអំពីឈ្មោះរបស់លោកអ្នកផ្ទាល់! កាលណាទារកបានកើតមក នោះត្រូវបានឪពុកម្តាយដាក់ឈ្មោះឲ្យ តួយ៉ាងដូចជាឈ្មោះរបស់លោកអ្នក គឺត្រូវបានដាក់ឲ្យតាំងពីមុនពេលកើតមកផងក៏អាចថាបាន ហើយក៏ត្រូវបានកំណត់ជាផ្លូវការ ដោយមានធ្វើសំបុត្រកំណើតជាដើម។

- តើលោកអ្នកមានឈ្មោះអ្វី? ____________________
- តើឈ្មោះរបស់លោកអ្នកមានអត្ថន័យដូចម្តេច? ____________________
- តើឈ្មោះរបស់លោកអ្នកត្រូវបានដាក់តាមនរណាម្នាក់មែនទេ? ____________________
- តើនរណាបានដាក់ឈ្មោះលោកអ្នក ផ្តល់អំណាចឲ្យ និង ការទទួលខុសត្រូវដល់លោកអ្នក? ____

____________________

- តើលោកអ្នកមានប្រតិកម្មយ៉ាងដូចម្តេចចំពោះផ្នត់គំនិតអំពីនរណាម្នាក់ដែលដាក់ច្បាប់ ឬ មានអំណាចលើជីវិតរបស់លោកអ្នក? ____________________

____________________

តើវាគឺជាផ្នត់គំនិតថ្មីមែនទេ? តើឈ្មោះរបស់លោកអ្នកសព្វថ្ងៃគឺជាឈ្មោះតាំងពីដំបូងមកមែនទេ?

____________________

____________________

ឬ ថាឈ្មោះរបស់លោកអ្នកត្រូវបានប្តូរដោយព្រោះតែជាកូនចិញ្ចឹម ឬ ក្រោយពេលរៀបការ ឬក្រោយពេលលែងលះគ្នាហើយទើបលោកអ្នកមានឈ្មោះថ្មី? ____________________

____________________

- នៅពេលព្រះជាម្ចាស់បានប្តូរឈ្មោះរបស់យ៉ាកុប ហើយបានក្លាយទៅជាអ្នកទទួលខុសត្រូវលើជីវិតរបស់គាត់ ដូច្នេះព្រះអង្គបានត្រាស់ហៅយើង និង ទ្រង់សព្វព្រះហឫទ័យចង់ធ្វើជាអ្នកទទួលខុសត្រូវចំពោះជីវិតរបស់យើងដែរ។ ទ្រង់សព្វព្រះហឫទ័យមានអំណាចចេស្តាគ្រប់គ្រប់ជីវិតរបស់យើង។ ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យចង់ឲ្យយើងបានទទួលយកការគ្រប់គ្រងរបស់ទ្រង់ និង ព្រមឲ្យទ្រង់បានសោយរាជ្យនៅក្នុងបល្ល័ង្កចិត្តរបស់យើងម្នាក់ៗផងដែរ។ តើលោកអ្នកផុសចេញនូវគំនិតបែបណាខ្លះ ក្នុងពេលលោកអ្នកគិតដល់ការប្រទានពររបស់ព្រះជាម្ចាស់សម្រាប់ជីវិត តាមរយៈការត្រាស់ហៅយើងគ្រប់គ្នាឲ្យចូលទៅនៅក្រោមការដឹកនាំដោយអំណាចចេស្តារបស់ទ្រង់? __________

____________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! សម្រាប់គំនិតនៃការរស់នៅក្រោមអំណាចចេស្តារបស់ទ្រង់ គឺគ្មានអ្វីបន្តិចណាត្រូវបាននៅសេសសល់នោះឡើយ ដូច្នេះមានន័យថាទូលបង្គំលែងជាម្ចាស់លើខ្លួនឯងតទៅទៀតហើយ គឺព្រះអង្គហើយជាម្ចាស់លើជីវិតរបស់ទូលបង្គំវិញ។ ទូលបង្គំមិនយល់អំពីការនេះច្បាស់នៅឡើយទេ ទូលមិនដឹងថាត្រូវធ្វើការផ្លាស់ប្តូរដោយរបៀបណានោះទេ។ តើទ្រង់សព្វព្រះហឫទ័យចង់កែប្រែទៅជាអ្វី ហើយតទៅតើទូលបង្គំត្រូវរស់នៅដោយរបៀបណា? ទូលបង្គំសូមឲ្យព្រះអង្គបានអោបទូលបង្គំ ដូចជាយ៉ាកុបផងដែរ គឺរហូតទាល់តែព្រះអង្គប្រទានពរដល់ទូលបង្គំ។ សូមអរព្រះគុណទ្រង់សម្រាប់សេចក្តីយ៉ាងខ្ជាប់ខ្ជួន ទាំងស៊ូទ្រាំអត់ធ្មត់គ្រប់យ៉ាងនឹងទូលបង្គំ ________________________________________

________________________________________

________________________________________

________________________________________

________________________________________

## មេរៀនទី ៦ - ផ្នែកទី ៤

**កិច្ចការៈ** ចូរអានព្រះគម្ពីរ លោកុប្បត្តិ ៣៣:១-១៧

## លំហាត់ៈ

ការផ្លាស់ប្តូរមួយបានកើតឡើងចំពោះយ៉ាកុប! ចូរមើល! យ៉ាកុបបានឃើញបងប្រុសរបស់គាត់ធ្វើដំណើរមកដោយមានមនុស្សប្រុស ៤០០ នាក់មកជាមួយផង។ គាត់ចាប់ផ្តើមដំរៀបមនុស្សក្នុងគ្រួសាររបស់គាត់ជាជួរពីតិចទៅច្រើន នៅមុខគេមានពួកអ្នកបម្រើ និង កូនចៅរបស់ពួកគេ បន្ទាប់មកគឺ លេអា ហើយនៅចុងក្រោយគេគឺប្រពន្ធសំណព្វចិត្តរបស់គាត់គឺនាង រ៉ាជែល និងខ្លួនគាត់ផ្ទាល់។

- តើនៅក្នុងខ ៣ បាននិយាយអំពីអ្វីខ្លះ? ________________________________________

  ________________________________________

  ________________________________________

  យ៉ាកុបបាននាំមុខគេ! គាត់បានចេញមុខដឹកនាំ! គឺគាត់បានបន្ទាប់ខ្លួននៅចំពោះមុខបងប្រុសរបស់គាត់ដោយបានលុតជង្គង់ឱនក្រាបក្បាលដល់ដី។ តើអេសាវ បានធ្វើដូចម្តេច នៅពេលដែលគាត់បានឃើញប្អូនប្រុសរបស់គាត់ធ្វើដូច្នេះ? ________________________________________

  ________________________________________

  ________________________________________

អេសាវបានរត់ទៅឯយ៉ាកុប! ហើយគាត់បានអោបយ៉ាកុបជាប់នឹងដើមទ្រូង ទាំងថើប ដោយក្តីនឹករលឹកគ្នាទៅវិញទៅមករហូតស្រក់ទឹកភ្នែក ពេលនោះពួកគេបានជូតទឹកភ្នែកឲ្យគ្នាទៅវិញទៅមក។ បើសិនលោកអ្នកស្ថិតនៅក្នុងហេតុការណ៍នោះ លោកអ្នកប្រាកដជាចូលរួមអបអរសាទរ និង ត្រេកអរជាមួយនឹងពួកគេដែរជាមិនខាន។

- នៅក្នុងខ ៥-៧ យ៉ាកុបបានណែនាំក្រុមគ្រួសាររបស់គាត់ឲ្យអេសាវបានស្គាល់។ យ៉ាកុបបានទទួលស្គាល់បងប្រុសរបស់គាត់ ថាកូនចៅរបស់គាត់ "គឺជាកូនចៅដែលប្រកបដោយទឹកចិត្តសប្បុរសធម៌ត្រូវបានឲ្យមកធ្វើជាអ្នកបម្រើរបស់លោកអ្នកគឺជាការប្រទានពរមកពីព្រះជាម្ចាស់"។ នេះគឺជាក្តីស្រលាញ់មានពេញទៅដោយសេចក្តីសប្បុរសដែលព្រះជាម្ចាស់ទ្រង់បានប្រទានមកយ៉ាកុប។
- ក្នុងខណៈពេលអេសាវសួរនាំអំពីអ្វីៗទាំងអស់ "បានតម្រូវឲ្យខ្ញុំបានជួប" ។ នៅក្នុងខ ៨ តើយ៉ាកុបបានសារភាពដូចម្តេច? ______________________________

______________________________

______________________________

ចូរកត់សំគាល់ដ៏គួរឲ្យចាប់អារម្មណ៍មួយរវាងការទទូចសុំ និង ការបដិសេធន៍របស់បងប្អូនប្រុសទាំងពីរ។ កាលពីដំបូង អេសាវ បានបដិសេធន៍មិនព្រមទទួលយកអំណោយពីយ៉ាកុបឡើយ (ខ៩) តើអេសាវបាននិយាយដូចម្តេចខ្លះ? ______________________________

______________________________

ប៉ុន្តែយ៉ាកុបនៅតែទទូចសុំ! តើយ៉ាកុបបាននិយាយដូចម្តេចខ្លះ?______________________________

______________________________

យ៉ាកុបចង់ទទួលស្គាល់ចំពោះបងប្រុសរបស់គាត់ថា ព្រះជាម្ចាស់មានសេចក្តីសប្បុរសដល់គាត់តាមរយៈការពេញចិត្តរបស់អេសាវចំណោះការទទួលរូបគាត់ជាប្អូនវិញ។ នៅក្នុងខ ១១ បានប្រាប់យើងថាគាត់មានអ្វីៗទាំងអស់ដែលគាត់ត្រូវការ! នៅទីបំផុត យ៉ាកុបបានទទូចសុំរហូតទាល់តែអេសាវព្រមទទួលយកអំណោយរបស់គាត់។

- អេសាវមានបំណងចង់ជូនដំណើរយ៉ាកុបរហូតដល់ទឹកដីនៃតំបន់ សៀរ ប៉ុន្តែយ៉ាកុបមានផែនការណ៍ផ្សេងទៀត។ បើតាមការយល់ឃើញរបស់លោកអ្នក តើយ៉ាកុបនឹងនិយាយប្រាប់បងប្រុសរបស់គាត់ដូចម្តេច? ______________________________

______________________________

- អេសាវមានបំណងចង់ប្រគល់មនុស្សរបស់គាត់មួយចំនួន ដើម្បីជាជំនួយក្នុងការធ្វើដំណើរ ប៉ុន្តែ តើយ៉ាកុបឆ្លើយតបទៅអេសាវវិញយ៉ាងដូចម្ដេច? ______________________________

______________________________
- បើដូច្នេះ នៅក្នុងខ ១៦ បានប្រាប់យើងថា អេសាវបានចាប់ផ្ដើមធ្វើដំណើរត្រឡប់ទៅតំបន់ ស៊ើរ (អេដុម) វិញ។ តើយ៉ាកុបបានធ្វើអ្វី? ______________________________

______________________________

គាត់បានដឹកនាំទៅកាន់ ស៊ុក្កូត ដែលមានទិសដៅផ្ទុយគ្នាពីតំបន់ ស៊ើរ។ ពេលទៅដល់ ស៊ុក្កូត ហើយ គាត់បានរៀបចំទីកន្លែងសម្រាប់រស់នៅដល់គ្រួសាររបស់គាត់ដើ ហើយក៏បានសាងសង់ទីជម្រក សម្រាប់ហ្វូងសត្វរបស់គាត់ផងដែរ។

## ការឆ្លុះបញ្ចាំង:

តើយ៉ាកុបមានសេចក្ដីជំនឿបែបណា នៅពេលដែលគាត់បានឃើញអេសាវរត់សំដៅមករកគាត់ ដោយការអោប ហើយថើប ព្រមទាំងបានជូតទឹកភ្នែកព្រោះតែសេចក្ដីអំណរនៃការស្រុះស្រួលគ្នាវិញ។ អំណោយទាំងប៉ុន្មានដែលយ៉ាកុបបានរៀបចំសម្រាប់ប្ដូរយកសន្តិភាពពីអេសាវ គឺលែងមានសារៈសំខាន់ទៀតហើយ ក៏ប៉ុន្តែ ជំនួសមកវិញដោយសេចក្ដីសប្បុរស ព្រោះបានជួបគ្នាវិញមុខទល់នឹងមុខ។ ទាំងនេះហើយគឺជាកូនភ្លោះទាំងពីរនាក់! គិតទៅហាក់ដូចជាមិនគួរឲ្យជឿថាពួកគ្នាម្នាក់ៗមានគ្រួសារយ៉ាងធំដូច្នេះសោះ ប៉ុន្តែ ពួកគេទាំងពីរនាក់នេះគឺសុទ្ធតែជាកូនប្រុសរបស់អ៊ីសាក់ និង នាង រេបេកា។

វាគឺជារឿងមួយដ៏គួរឲ្យចាប់អារម្មណ៍ដែលត្រូវកត់ចំណាំទុក អំពីការដែលយ៉ាកុបមិនព្រមធ្វើដំណើរទៅកាន់តំបន់ ស៊ើរ ជាមួយនឹងបងប្រុសរបស់គាត់ ក៏ព្រោះតែគាត់បានជឿថាព្រះជាម្ចាស់បានត្រាស់ហៅគាត់ឲ្យវិលត្រឡប់ទៅកាន់ទឹកដីឪពុករបស់គាត់វិញ រួចហើយគាត់នឹងទៅកាន់ទឹកដីដែលព្រះជាម្ចាស់បានសន្យាជាមួយនឹងយ៉ាកុប ព្រមទាំងពូជពង្សកូនចៅជំនាន់ក្រោយទៀតផង។

## ការអនុវត្តន៍ផ្ទាល់ខ្លួន:

ការប៉ះប៉ូវ និង សំណងរបស់កូនប្រុសភ្លោះទាំងពីរនាក់ត្រូវបានធ្វើឡើងចប់សព្វគ្រប់ទាំងអស់។ នៅក្នុងជីវិតរបស់លោកអ្នក តើមានទំនាក់ទំនងបែកបាក់ជាមួយនរណាម្នាក់ដែលត្រូវការជួសជុលឡើងវិញ? ______

______________________________ តើមានពាក្យសម្ដីអ្វីដែលបាននិយាយចេញមក ឬ ទង្វើបែបណាមួយដែលបានប្រព្រឹត្តជាហេតុធ្វើឲ្យមានការឈឺចាប់ដល់គ្នាទៅវិញទៅមក? ______________________________

ព្រះជាម្ចាស់ទ្រង់មានសេចក្តីសប្បុរសយ៉ាងស្មោះស្ម័គ្រចំពោះយ៉ាកុប ហើយទ្រង់ក៏បានផ្សះផ្សាទំនាក់ទំនងដែលបានបែកបាក់រវាងបងប្អូនគេទាំងពីរឲ្យបានស្រុះស្រួលនឹងគ្នាឡើងវិញ ដូច្នេះទ្រង់ក៏អាចធ្វើដូចគ្នានេះចំពោះស្ថានភាពឈឺចាប់នៅក្នុងជីវិតរបស់លោកអ្នកបានដែរ។

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់នៃទូលបង្គំអើយ! ព្រះអង្គមានសេចក្តីសប្បុរសចំពោះយើងខ្ញុំ ដោយបានប្រទាននូវអ្វីៗគ្រប់យ៉ាងដែលទូលបង្គំត្រូវការ តាមពិតទៅយើងខ្ញុំមិនសក្តិសមនឹងទទួលយករបស់អស់ទាំងនេះឡើយ។ មានពេលខ្លះ យើងបានគិតថា យើងត្រូវការច្រើនជាងនេះបន្ថែមទៀត ហើយជួនកាលយើងគិតថាចង់បានច្រើនថែមទៀត ប៉ុន្តែនៅពេលណាយើងមានសេចក្តីស្មោះត្រង់ ដោយបានពិចារណាឃើញថា អ្វីៗទាំងអស់នោះគឺសុទ្ធតែជាការប្រទានពរមកពីព្រះជាម្ចាស់ ដូច្នេះយើងខ្ញុំមានតែថ្លែងការអរព្រះគុណដល់ទ្រង់តែប៉ុណ្ណោះ។ សូមទ្រង់បង្ហាញឲ្យទូលបង្គំបានដឹង ចំពោះអស់អ្នកណាដែលមានការអាក់អន់ចិត្តក្នុងរឿងអ្វីម្យ៉ាងជាមួយនឹងយើង! សូមទ្រង់ប្រទាននូវសេចក្តីក្លាហាដើម្បីទូលបង្គំស្វែងរកការអត់ទោសបាប និង ការទុកចិត្តលើទ្រង់ក្នុងការផ្សះផ្សារទំនាក់ទំនងបែកបាក់រវាងពួកយើង ដ្បិតមានតែទ្រង់ហើយដែលបានស្រលាញ់ពួកយើង ហើយធ្វើឲ្យយើងអាចរស់នៅក្នុងសន្តិភាពជាមួយគ្នាបានឡើងវិញ។

## មេរៀនទី ៦ - ផ្នែកទី ៥

## សេចក្តីបង្រៀនៈ

យើងបានចំណាយពេលវេលាសិក្សានូវមេរៀនជាច្រើននាពេលកន្លងមក ហើយតាមរយៈមេរៀនទាំងអស់នោះត្រូវបានផ្តោតទៅសាច់រឿងរបស់យ៉ាកុបដែលជាកូនប្រុសភ្លោះពេញទៅដោយការបោកបញ្ឆោត ច្រើនជាងគេបង្អស់ ហើយគឺជាកូនសំណព្វចិត្តរបស់រេបេកាត្រូវជាម្តាយ។ គាត់មិនត្រឹមតែបោកបញ្ឆោតយកសិទ្ធិជាកូនច្បងប៉ុណ្ណោះទេ គឺថែមទាំងបញ្ឆោតទទួលយកការប្រទានពរឪពុកគាត់ទៀតផង។ យើងធ្វើដំណើរជាមួយនឹងគាត់ទៅកាន់តំបន់ហារ៉ាន ដែលជាកន្លែងមានសុវត្ថិភាពពីការតាមសម្លាប់អេសាវជាបង។ លុះក្រោយមកទៀត យ៉ាកុបត្រូវបានពូរបស់គាត់បោកបញ្ឆោត តែក្រោយមកទៀត ឡាបាន់បានប្រគល់កូនស្រីទាំងពីរឲ្យទៅធ្វើជាប្រពន្ធរបស់យ៉ាកុប។ ហើយនៅមេរៀនចុងក្រោយនេះ នឹងធ្វើការណែនាំឲ្យពួកយើងបានស្គាល់កូនប្រុសទាំង ១២ នាក់របស់យ៉ាកុប។ នៅពេលក្រោយពីបានប្រាស្រ័យទាក់ទងជាមួយនឹងព្រះជាម្ចាស់ យើងឃើញថាបងប្អូនប្រុសពួកគេទាំងពីរក៏បានជួបជុំគ្នាឡើងវិញ។

នៅក្នុងព្រះគម្ពីរ លោកុប្បត្តិជំពូក ៣៥ យើងបានដឹងថាយ៉ាកុបបានចាកចេញពីផ្ទះ ដើម្បីរត់គេចពីអេសាវ ហើយគាត់បានវិលត្រឡប់ទៅ បេតអែលវិញ ព្រោះថាទីកន្លែងនោះហើយ ដែលគាត់ប្រាស្រ័យជាមួយនឹងព្រះជាម្ចាស់តាមរយៈសុបិន្តមិត្ត (លោកុប្បត្តិ ២៨:១០-១៥)។ លុះក្រោយមកទៀត ព្រះជាម្ចាស់បានលេចមកឯគាត់ជាលើកទី២ ហើយពេលនោះទ្រង់បានប្រទានពរដល់គាត់ និង ដាក់ឈ្មោះថ្មីឲ្យគាត់គឺប្ដូរពីយ៉ាកុបទៅជាឈ្មោះថា អ៊ីស្រាអែល វិញ (លោកុប្បត្តិ ៣៥:៩-១៣)។ ហើយក្រោយមកបន្តិចទៀត នៅក្នុងជំពូកដដែលនោះ យើងបានដឹងថានាងរ៉ាជែលត្រូវបានទទួលមរណៈភាព ក្នុងពេលសម្រាលកូនប្រុសម្នាក់ឲ្យយ៉ាកុប ហើយបានដាក់ឈ្មោះកូនប្រុសនោះថា បេនយ៉ាមីន គឺជាកូនប្រុសពៅនៅក្នុងគ្រួសារ។ បេនយ៉ាមីន ហើយ យ៉ូសែបបងប្រុសបន្ទាប់របស់គាត់ហើយគឺជាកូនសំណព្វចិត្តរបស់ឪពុក ដ្បិតយ៉ាកុបបានស្រលាញ់នាងរ៉ាជែល ជាងស្រលាញ់ លេអា។ នៅក្នុងខ ២៧-២៩ យើងបានដឹងថាយ៉ាកុបបានវិលត្រឡប់ទៅ ទឹកដីហេប្រុន ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំនោះទេ។ អ៊ីសាក់រស់នៅបានអាយុ ១៨០ ឆ្នាំរួចគាត់ក៏ស្លាប់ទៅ ហើយកូនប្រុសភ្លោះទាំងពីរនាក់ (អេសាវ និង យ៉ាកុប) ក៏បានយកសព្វឪពុកទៅបញ្ចុះ។

នៅក្នុងជំពូក ៣៦ គឺជាបញ្ជីរាយនាមពូជពង្សរបស់អេសាវ។ នៅលើទឹកដីនោះ មិនអាចផ្គត់ផ្គង់អាហារគ្រប់គ្រាន់ដល់ហ្វូងសត្វរបស់ពួកគេ ដូច្នេះហើយទើបអេសាវសម្រេចចិត្តតាំងទីលំនៅឯ អេដុម ជាតំបន់ភ្នំសៀរ ហើយអេសាវបានក្លាយទៅឪពុកនៃសាសន៍ អេដុម។ អេសាវបានបែកចេញពីផ្លូវរបស់ព្រះជាម្ចាស់ មិនស្ដាប់បង្គាប់អ៊ីសាក់ជាឪពុកហើយទៅយកប្រពន្ធជាសាសន៍ ហេត និង សាសន៍កាណាន។ ពួកគេទាំងនោះមិនត្រូវបានជ្រើសរើសឲ្យធ្វើសាសន៍អ៊ីស្រាអែលនោះឡើយ។

តើអេសាវ និង យ៉ាកុបបានជួបគ្នាម្ដងទៀតដែរទេ? នៅក្នុងព្រះគម្ពីរមិនបានប្រាប់យើងអំពីការណោះ ប៉ុន្តែអ្វីដែលយើងដឹងតាមរយៈខយោងនៅក្នុងព្រះគម្ពីរ នោះគឺថា អេសាវមិនដែលមានចំណុចវិជ្ជមានណាមួយ។ ពួកសាសន៍ អេដុម គឺឧបសគ្គដ៏ធំជាងគេសម្រាប់រាស្ត្រអ៊ីស្រាអែល នៅពេលដែលអ៊ីស្រាអែលស្រាប់រុងនឹងចូលទៅកាន់កាប់ទឹកដីដែលព្រះជាម្ចាស់ទ្រង់បានសន្យាថានឹងឲ្យ។ សាសន៍អេដុម ត្រូវបានការផ្ទុះបញ្ចាំអំពីណព្រះក្លែងក្លែង ដែលពួកគេមួយចំនួនបានថ្វាយបង្គំ។

វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់អំពីលោក អប្រាហាំមានកូនប្រុសពីរនាក់! កូនប្រុសច្បងបានងាកចេញពីព្រះរបស់ឪពុកខ្លួន ហើយបានចាកចេញទៅនៅប្រទេសអេស៊ីព្ទ ក្នុងពេលដែលកូនប្រុសបន្ទាប់ គឺអ៊ីសាក់បានទទួល យកសេចក្ដីសន្យាបន្តពីឪពុក។ ឥឡូវនេះ អ៊ីសាក់មានកូនប្រុសពីរនាក់ដែរ កូនមួយបានងាកចេញពីផ្លូវព្រះរបស់ឪពុក ហើយបានចាកចេញទៅរស់នៅលើទឹកដី អេដុម ក្នុងខណៈពេលដែលកូនប្រុសម្នាក់ទៀត គឺយ៉ាកុប បានវិលត្រឡប់ទៅកាន់ទឹកដីរបស់ឪពុកនៅតំបន់ ហារ៉ាន វិញដើម្បីទទួលយកសេចក្ដីសន្យាបន្តពីជីតា ហើយបានប្រគល់បន្តមកឪពុករបសគាត់។ ចេញពីគ្រួសារតែមួយពិតមែន តែពួកគេមានផ្នត់

គំនិតផ្សេងៗពីគ្នា គឺម្នាក់បានតាមគំរូរបស់ឪពុក រីឯម្នាក់ទៀតបែរជាបានងាកចេញដាច់ស្រឡះពីផ្លូវរបស់ឪពុកទៅវិញ ដោយសម្រេចចិត្តតាមផ្លូវដែលខ្លួនបានជ្រើសរើស។

**ការអនុវត្តន៍ផ្ទាល់ខ្លួន:** ចូរនឹកគិតដល់គ្រួសាររបស់លោកអ្នកផ្ទាល់វិញម្តង និង ឥរិយាបទរបស់លោកអ្នកសំដៅទៅ គុណតម្លៃ និង ផ្លូវរបស់ឪពុកម្តាយលោកអ្នក។ ជាបឋមលោកអ្នកត្រូវតែទទួលស្គាល់ថាផ្លូវរបស់ឪពុកម្តាយនោះគឺត្រូវបានផ្ទៀតផ្ទាត់ត្រឹមត្រូវរួចរាល់ជាមួយនឹងផ្លូវរបស់ព្រះជាម្ចាស់។ បន្ទាប់មកត្រូវតែពិចារណាអំពីផ្លូវរបស់គេថាតើនឹងទៅជាយ៉ាងណា? ទោះបីជាឪពុកម្តាយ ឬ ជាកូនចៅ ជាចៅកែ ឬ ជាបុគ្គលិក ជាគ្រូបង្រៀន ឬ ជាកូនសិស្ស នោះទេ យើងទាំងអស់គ្នាគង់នឹងមានពេលមួយជួបប្រទះនឹងបញ្ហាដូចៗគ្នា ពីព្រោះពួកយើងទាំងអស់គ្នាសុទ្ធតែជាមនុស្សមានបាប ហើយកំពុងរស់នៅក្នុងអំពើបាបនៃលោកីយ៍នេះ។ ទន្ទឹមនឹងនេះដែរ យើងក៏នៅមានវិធីល្អមួយទៀតដែរ គឺយើងអាចនឹងឮការត្រាស់ហៅរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជាអ្នកអញ្ជើញពួកយើងឲ្យមកដើរតាមទ្រង់។

តើដួងចិត្តរបស់លោកអ្នកធ្លាប់បានងាមកដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ដែលជាអ្នកផ្គត់ផ្គង់ដ៏ស្មោះត្រង់ ក្នុងការប្រទាននូវគ្រប់អ្វីដែលលោកអ្នកត្រូវការដែរឬទេ? តើដួងចិត្តលោកអ្នកធ្លាប់ងាកមកដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ដែលជាអ្នកតែងតែនៅបន្តការត្រាស់ហៅលោកអ្នកឲ្យបានចូលមកក្នុងទំនាក់ទំនងជាមួយនឹងទ្រង់ គឺជាទំនាក់ទំនងក្នុងឋានៈជាកូនស្ងួនភ្ងារបស់ទ្រង់ដែរឬទេ? នៅពេលដែលឪពុកម្តាយដើមរបស់យើងបានធ្លាក់ចូលក្នុងអំពើបាប ព្រះជាម្ចាស់មានបំណងព្រះហឫទ័យ ត្រាស់យើងគ្រប់ៗគ្នាឲ្យវិលត្រឡប់មកធ្វើជាកូនស្ងួនភ្ងារបស់ទ្រង់វិញជានិច្ច (សេផានា ៣:១៧) ដែលបានចែងទុកមកថា ទ្រង់នឹងមានសេចក្តីរីករាយអរសប្បាយចំពោះយើង។

ចូរកត់ត្រាខគម្ពីរនេះចូលក្នុងសៀវភៅរបស់លោកអ្នក។ ______________________________

______________________________

______________________________

______________________________

______________________________

## ការទន្ទេញចងចាំ:

សេផានា ៣:១៧ គឺជាខគម្ពីរមួយដែលលោកអ្នកត្រូវទន្ទេញឲ្យបានចាំ ដ្បិតវាគឺជាសេចក្តីរីករាយយ៉ាងលើសលុបព្រះវរបិតា ចំពោះកូនរបស់ទ្រង់។ ជាការលើកទឹកចិត្តដល់លោកអ្នកម្តងទៀត ឲ្យកត់ត្រានូវបទគម្ពីរនេះទុកក្នុងសៀវភៅរបស់លោកអ្នក ហើយចូរចំណាយពេលវេលាប៉ុន្មានថ្ងៃបន្ទាប់នេះ ធ្វើបទគម្ពីរនេះឲ្យទៅជាភាសាផ្ទាល់ខ្លួនរបស់លោកអ្នកផ្ទាល់។

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់ព្រះវរបិតាអើយ! ព្រះអង្គមានបំណងព្រះហឫទ័យចង់ធ្វើជាព្រះបិតារបស់ពួកយើង។ ជួនកាលសណ្ឋានដើមរបស់យើងត្រូវបានបាត់បង់ ព្រោះតែការប្រព្រឹត្តពេញដោយអំពើបាបនៃឪពុកម្តាយខាងសាច់ឈាមរបស់យើង។ សូមបើកភ្នែកទូលបង្គំឲ្យបានមើលឃើញនូវសេចក្តីស្រលាញ់របស់ទ្រង់កំពុងបំពេញមកក្នុងជីវិតរបស់ទូលបង្គំផង! គឺជាសេចក្តីស្រលាញ់របស់ទ្រង់ដែលបានប្រទាននូវគ្រប់អ្វីៗដែលទូលបង្គំត្រូវការ។ ក្តីស្រលាញ់របស់ព្រះអង្គដែលបានប្រទានមកគឺហួសពីសមត្ថភាពនឹងអាចយល់បានទៅទៀតផង។ ដោយព្រោះតែសេចក្តីស្រលាញ់របស់ទ្រង់នេះហើយ ជាហេតុធ្វើឲ្យទ្រង់មិនដែលបោះបង់ទូលបង្គំចោល តែផ្ទុយទៅវិញនោះគឺទ្រង់តែងតែគង់នៅជាមួយនឹងទូលបង្គំគ្រប់ពេលវេលា ហើយជួយសង្គ្រោះទូលបង្គំឲ្យបានរួចផុតពីអស់ទាំងការឈឺចាប់គ្រប់យ៉ាង ហើយទ្រង់សប្បាយព្រះហឫទ័យនៅក្នុងទូលបង្គំទៀតផង។ វាស្ទើរតែធ្វើឲ្យពិបាកខ្លាំងពេលរហូតដល់មិនអាចនឹងយល់បាន! ជាពិសេសនោះគឺនៅពេលដែលទូលបង្គំបានដឹងថាអំពើបាបកំពុងនៅក្បែរដួងចិត្តទូលបង្គំ។ សូមឲ្យទូលបង្គំបាននៅជាប់ក្នុងសេចក្តីស្រលាញ់របស់ទ្រង់ផង ហើយសូមឲ្យទូលបង្គំមានសេចក្តីអំណរ រីករាយទាំងច្រៀងសរសើរដម្កើងដល់ព្រះនាមទ្រង់។ ទូលបង្គំសូមបានសម្រាក់នៅក្នុងព្រះអង្គជានិច្ចតទៅ។ ________________________________

________________________________________________

________________________________________________

________________________________________________

________________________________________________

________________________________________________

# មេរៀនសារឡើងវិញ

លំហាត់អនុវត្តជាក់ស្តែងទាំងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីស្ទាបស្ទង់ បញ្ជាក់អំពីការរីកចម្រើន និង ចំណេះដឹងរបស់លោកអ្នកចំពោះតួអង្គមួយចំនួននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដូចជា អ៊ីសាក់ រេបេកា អេសាវ និង យ៉ាកុបជាដើម។

1. ចូររៀបរាប់សង្ខេបអំពីចរិតលក្ខណៈរបស់តួអង្គដូចខាងក្រោមនេះ៖

   ក. អ៊ីសាក់: ______________________________

   ______________________________

   ខ. រេបេកា: ______________________________

   ______________________________

   គ. អេសាវ: ______________________________

   ______________________________

   ឃ. យ៉ាកុប: ______________________________

   ______________________________

2. បើយោងទៅតាមសម័យទំនើបបច្ចុប្បន្ននេះ យើងប្រហែលជាអាចនឹងគិតថាគ្រួសារមួយនេះ គឺមានភាពមិនប្រក្រតីជាមិនខាន។ តែទោះបីជាយ៉ាងណាក៏ដោយ តាមលក្ខំណ្ឌរបស់មនុស្សពិភាក្សាទៅលើអត្ថន័យនៃភាពស្មោះត្រង់របស់ព្រះជាម្ចាស់មានន័យយ៉ាងណាចំពោះពួកគេ និង កូនប្រុសទាំងពីររបស់យ៉ាកុប។ ______________________________

   ______________________________

   ______________________________

3. ឥរិយាបទរបស់ព្រះជាម្ចាស់ចំពោះគ្រួសារមួយនេះ គឺមិនមែនជាឥទ្ធិពលដោយឥរិយាបទរបស់ពួកគេនោះទេ។ ពួកគេមិនអាចនឹងធ្វើអ្វីម្យ៉ាង ឬមានអ្វីមួយអាចធ្វើឲ្យបញ្ឈប់សេចក្តីស្រលាញ់របស់ទ្រង់ចំពោះពួកគេបាននោះឡើយ។ នៅក្នុងការសិក្សានេះ តើលោកអ្នបានសិក្សាអ្វីខ្លះអំពីព្រះជាម្ចាស់ ដែលបានប្រទានហេតុផលដើម្បីលោកអ្នកទុកចិត្តលើទ្រង់ និង ប្រកបដោយភាពស្មោះត្រង់ (យ៉ូហាន ៣:៣៣) តែទោះបីជាយ៉ាងណាក៏ដោយ ក៏យើងនៅតែជឿថា ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ (យ៉ូហាន ៣:១៦) ______________

   ______________________________

   ______________________________

4. លោកអ្នកបានសិក្សាអំពីឈ្មោះជាច្រើនរួចមកហើយ ដូចជាឈ្មោះរបស់តួអង្គក្នុងសាច់រឿង ឈ្មោះទីកន្លែងនានាជាដើម។ នេះគ្រាន់តែការល្បែងកំសាន្តប៉ុណ្ណោះ! ចូរលោកអ្នកគូសភ្ជាប់ពាក្យ ឬ ឃ្លាណាដែលជាគូរនឹងគ្នា។

| | |
|---|---|
| 1. ប្រទេសចាស់ | ក. ទឹកដីនៃតំបន់ ស៊ីរ |
| 2. មរតករបស់កូនច្បង | ខ. ហារ៉ាន |
| 3. បុព្វបុរសនៃសាសន៍អ៊ីស្រាអែល | គ. ឡាបាន់ |
| 4. ទីកន្លែងដែលយ៉ាកុបសុបិន្ត | ឃ. បេតអែល |
| 5. ដង្វាយមួយភាគដប់ | ង. អេដុម |
| 6. ព្រះពរ | ច. ឈ្មោះថ្មីរបស់យ៉ាកុប |
| 7. សិទ្ធកូនច្បង | ឆ. មួយភាគក្នុងដប់ពីគ្រប់អ្វីៗដែលព្រះជាម្ចាស់ប្រទាន |
| 8. បុព្វបុរស | ជ. ពាក្យសម្ដីអប់រំប្រដៅកូនប្រុស |
| 9. អ៊ីស្រាអែល | ឈ. បងប្រុសរបស់នាងរេបេកា |

សូមចូលរួមអបអរសារទផង! ពេលនេះលោកអ្នកបានបញ្ចប់ការសិក្សាក្នុងភាគ "ភាពស្មោះត្រង់នៃព្រះជាម្ចាស់ សេចក្ដីសង្ឃឹមរបស់យើង" ។ លោកអ្នកប្រាកដជាបានស៊ាំនឹងសាច់រឿងភាគច្រើននៅក្នុងព្រះគម្ពីរសញ្ញាចាស់ជាមិនខាន។ ឆ្លងតាមការសិក្សាអំពីដំណើរជីវិតរបស់បុគ្គលមួយចំនួននៅក្នុងព្រះគម្ពីរ គឺពួកគេម្នាក់ៗ សុទ្ធតែបានបង្ហាញនូវភស្តុតាងអំពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ក្នុងកាលដែលទ្រង់ជ្រើសរើសពួកគេឲ្យមានទំនាក់ទំនងជាមួយនឹងទ្រង់។ បំណងព្រះហឫទ័យរបស់ទ្រង់គឺចង់ឃើញការរស់នៅរបស់មនុស្សគ្រប់ៗរូបមានទំនាក់ទំនងយ៉ាងជិតស្និទ្ធប្រកបដោយសេចក្ដីស្រលាញ់ជាមួយនឹងយើងម្នាក់ៗ។ ទ្រង់បានត្រាស់ហៅលោកអ្នក ហើយនឹងខ្ញុំ! ព្រះអង្គត្រាស់ហៅយើងគ្រប់ៗគ្នាដើម្បីបានទទួលយកទ្រង់មកធ្វើជាព្រះអម្ចាស់ ហើយព្រះបុត្រារបស់អង្គគឺអង្គព្រះយេស៊ូវគ្រីស្ទធ្វើជាអង្គសង្គ្រោះសម្រាប់យើងឲ្យក្ដីសង្ឃឹមទៅសេចក្ដីសង្គ្រោះ។ ការបង្ហាញតាមរយៈការសិក្សារបស់លោកអ្នក! នេះគឺជាដំណឹងល្អយ៉ាងពិតប្រាកដ។

## សេចក្ដីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ព្រះអង្គគឺជាព្រះវរបិតារបស់ទូលបង្គំ! សូមទ្រង់បន្តបើកសម្ដែងអង្គទ្រង់ផ្ទាល់ដល់ ទូលបង្គំតាមរយៈការសិក្សាព្រះបន្ទូលរបស់ទ្រង់។ សូមទ្រង់បើកចំហរដួងចិត្តទូលបង្គំ ក្នុងពេលដែលទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំ និង អស់អ្នកដែលព្រះអង្គបានជ្រើសតាំងពីយូរលង់ណាស់មកហើយតាមរយៈការសិក្សាសាច់រឿង។ សូមទ្រង់រក្សារចិត្តគំនិតទូលបង្គំ ទោះបីជាអតីតកាលរបស់ទូលបង្គំអាក្រក់យ៉ាងក៏ដោយ សូមទ្រង់ជ្រើសរើសទូលបង្គំ ហើយប្រើទូលបង្គំទៅតាមបំណងព្រះហឫទ័យទ្រង់ចុះ។ ព្រះអង្គបានបំពេញអត្ថន័យសម្រាប់ជីវិតរបស់ទូលបង្គំដោយសេចក្ដីសង្ឃឹម និង គោលបំណងច្បាស់លាស់។ បំណងព្រះហឫទ័យរបស់ទ្រង់គឺចង់ប្រទានពរដល់ទូលបង្គំ ប្រយោជន៍ឲ្យទូលបង្គំធ្វើទីបញ្ចេញព្រះដល់ដទៃទៀត។ នេះគឺជាបំណងព្រះហឫទ័យទ្រង់! បំណងព្រះហឫទ័យរបស់ទ្រង់នឹងបានត្រឡប់ជារបស់ខ្ញុំវិញម្ដង។ នេះក៏ព្រោះតែភាពស្មោះត្រង់របស់ទ្រង់ចំពោះទូលបង្គំដែរ ។